ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Jul-2015, 14:17
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Court Suprême

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងសាទុក្ខ សាធារណៈ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧/អវតក-អជសដ/អជតក

**ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៤នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រ៊ីម ជាប្រធាន

ចៅក្រម យ៉ា ណារិន

ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត
*(Judge Agnieszka KLONOWIECKA-MILART)*

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មន្នីចរិយា

ចៅក្រម ផ្លរិនស៍ ដេផេល វ៉រឈិន-ម៉ុមបា
*(Florence N. MWACHANDE-MUMBA)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

លោក វុលគ័រ នឺលិច
*(Mr. Volker NERLICH)*

លោក ផន ធឿន

លោក ប៉ៅឡូ ឡូបា *(Mr. Paolo LOBBA)*

លោក សីលា ផៃឡេន *(Mr.Sheila PAYLAN)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

កញ្ញា សុង ឆវ័ន្ត

លោក ស្រ៊ា រតនៈ

លោក នីកូឡាស គូមជែន
*(Mr. Nicolas Koumjian)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew Boyle)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គរ៉ូដ៍*(Ms. Marie GUIRAUD)*

លោក ហុង គឹមសួន

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**មេធាវីការពារក្តីលោក នួន ជា**

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

លោក សុន អរុណ

**មេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN )*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម គង់ ស្រ៊ីម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម យ៉ា ណារិន | ខ្មែរ |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត | អង់គ្លេស |
| ចៅក្រម ផ្លូរិនស៍ ម៉ុមបា | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | ខ្មែរ |
| លោក អាកទួរ វ៉ែកគែន | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក សៅ វ៉ន ហៅ សៅ ពត (SCW-4) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សៅ វ៉ន ហៅ សៅ ពត (SCW-4)**


សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ........................................ ទំព័រ ១២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី៖ ........................................ ទំព័រ ១៤

សួរដោយលោក អាកឡូវ វែកគែន ផ្តើមពី៖ ........................................ ទំព័រ ៣៧

សួរដោយលោក វ៉ែន ពៅ ផ្តើមពី៖ ........................................ ទំព័រ ៤៩

សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី៖ ........................................ ទំព័រ ៥៣

សួរដោយចៅក្រម ម៉ុង មុន្នីចរិយា ផ្តើមពី៖ ........................................ ទំព័រ ៩០

សួរដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត ផ្តើមពី៖ ........................................ ទំព័រ ៩៤

# កិច្ចដំណើរការនីតិវិធី

[០៨:៥៤:០០]

**ក្រឡាបញ្ជី៖**

បាទ ថ្ងៃនេះជាថ្ងៃសវនាការទៅលើការពិនិត្យសាក្សី។ ដូច្នេះ ខ្ញុំបាទ ដោយការអនុញ្ញាតពីឯកឧត្តមប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខ្ញុំបាទ ស៊ា ម៉ៅ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក សូមអានទូវបទបញ្ជាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងសាលសវនាការ នៅក្នុងថ្ងៃសវនាការនេះ។

បទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការក្នុងថ្ងៃសវនាការ។ ដើម្បីរក្សានូវសណ្តាប់ធ្នាប់របៀបរៀបរយ សន្តិសុខ និងដំណើរការល្អក្នុងពេលសវនាការ ប្រធានអង្គជំនុំជម្រះតុលាការកំពូលសម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការ ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២ វគ្គមួយ ដូចខាងក្រោម៖

១) អ្នកដែលមានបំណងចូលរួមក្នុងសវនាការទាំងអស់ ត្រូវមានវត្តមានក្នុងសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យមានមុនម៉ោងប្រាំបី និងសាមសិបនាទីព្រឹក និងមុនម៉ោងមួយ និងសាមសិបនាទីល្ងាច។ ២) សាធារណជន និងភាគីទាំងអស់ លើកលែងព្រះសង្ឃ ត្រូវក្រោកឈរនៅពេលដែលក្រឡាបញ្ជីបញ្ជាក់ថា ក្រោកឈរ ហើយត្រូវអង្គុយចុះ នៅពេលដែលប្រធានអង្គជំនុំជម្រះប្រកាសឲ្យអង្គុយចុះ។ ៣) អ្នកចូលរួមក្នុងសាលសវនាការត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ សមរម្យជានិច្ច។ អ្នកចូលរួមត្រូវស្លៀកពាក់សមរម្យ មិនត្រូវបង្ហាញពាក្យស្លោក ការគាំទ្រដល់ភាគីណាមួយនៃដំណើរការនីតិវិធី ឬប្រើពាក្យសម្តីដែលមិនសមរម្យឡើយ។ ៤) ហាមយកម៉ាស៊ីនថតរូបភាព ម៉ាស៊ីនថតវីដេអូ ឧបករណ៍ថតសំឡេង និងឧបករណ៍បំពងសំឡេងគ្រប់ប្រភេទចូលក្នុងសាលសវនាការ។ លើកលែងតែមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះតុលាការកំពូល។ ៥) ហាមជក់បារី ឬយកចំណីអាហារភេសជ្ជៈគ្រប់ប្រភេទចូលក្នុងសាលសវនាការ។ ៦) ហាមយកអាវុធជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែភ្នាក់ងារសន្តិសុខដែលមានសមត្ថកិច្ច។ ៧) ហាមប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទក្នុងសាលសវនាការ។ ហាមថតរូបភាព ឬថតសំឡេងតាម គ្រប់មធ្យោបាយ លើកលែងតែមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះតុលាការកំពូល។ ៨) ហាមប្តូរកន្លែងអង្គុយឬដើររហេតរហូតក្នុងសាលសវនាការ។ ៩) ហាមទះដៃ ឬស្រែកជយឃោស ឬស្រែកឡូឡា ឬការធ្វើឲ្យមានសំឡេងខ្លាំងដែលនាំឲ្យ

រំខានដល់ដំណើរការសវនាការ។ ១០) ហាមដើរចេញចូលដោយអាណាធិបតេយ្យនៅពេលសវនាការ។ ការចេញចូលត្រូវមានការអនុញ្ញាតពីកម្លាំងសន្តិសុខរក្សាសណ្ដាប់ធ្នាប់ក្នុងសាលសវនាការ។ ១) ហាមកុមារដែលមានអាយុតិចជាង១៦ឆ្នាំ ចូលក្នុងសាលសវនាការ។ កុមារដែលមានអាយុចាប់ ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ អាចចូលក្នុងសាលសវនាការបាន ប្រសិនបើគាត់មកជាមួយឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាល លើកលែងកុមារណាដែលត្រូវចូលរួមក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី ឬជាសាក្សី។ ១២) ក្នុងករណីមានបុគ្គលប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុងនេះ ប្រធានអង្គជំនុំជម្រះតុលាការកំពូល នឹងចាត់វិធានការដើម្បីរារាំង ឬទប់ស្កាត់ភ្លាម តាមករណីសមស្របផ្អែកតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥

ប្រធានអង្គជំនុំជម្រះតុលាការកំពូល, គង់ ស្រ៊ឹម។

បាទ, ខ្ញុំសូមបញ្ចប់ការអាន បាទ។

[០៨:៥៩:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

តាំងនាមប្រជារាស្ត្រ -- អង្គការសហប្រជាជាតិ និងតាំងនាមប្រជារាស្ត្រខ្មែរ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាសបើកសវនាការដើម្បីជំនុំជម្រះលើបណ្ដឹងសាទុក្ខរបស់ភាគីប្រឆាំងនឹងសាលក្រមចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿងលេខ០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ដែលមានជនជាប់ចោទ នួន ជា និង ខៀវ សំផន។

សវនាការនាថ្ងៃនេះ ក្រុមប្រឹក្សាជំនុំជម្រះមានខ្ញុំចៅក្រម គង់ ស្រ៊ឹម ជាប្រធាន នៅខាងស្ដាំខ្ញុំមានចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត, ចៅក្រម សោម សិរីវឌ្ឍ, ចៅក្រម ផ្លូរិនស៍ ដេផេល វ័រឈិន ម៉ុមបា, ខាងឆ្វេងខ្ញុំគឺមានចៅក្រម ម៉ុង មុន្នីចរិយា, ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ និង ចៅក្រម យ៉ា ណារិន។ ក្រឡាបញ្ជីសវនាការនាពេលនេះគឺលោក វ៉ុលគ័រ នីលិច, លោក ស៊ា ម៉ៅ, លោក សីលា ហេឡែន, លោក ប៉ៅឡូ ឡូបា និងលោក ផន ធឿន។

លោកក្រឡាបញ្ជី តើភាគីនិងមេធាវីព្រមទាំងសាក្សីមានវត្តមានគ្រប់ចំនួនហើយឬនៅ?

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[០៩:០២:១៥]

**ក្រឡាបញ្ជី៖**

បាទ សូមអភ័យទោស។ បានសូមជម្រាបប្រសាសន៍ឯកឧត្តមប្រធាន អង្គជំនុំជម្រះតុលាការកំពូល សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន បាទ ទាំងលោក នួន ជា ទាំងលោក ខៀវ សំផន និងខាងគ្រប់ភាគីទាំងអស់ ហើយក្នុងនោះដែរក៏មានដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ថ្ងៃនេះចូលរួមមាន ១០រូបគឺទី១៖ អ្នកស្រី យឹម សុវណ្ណ, អ្នកស្រី មុម សំអឿន, លោក មាស សារ៉ាន់, អ្នកស្រី ឱ រី, អ្នកស្រី ទឹង សុខា, លោក អួន ផល្លី, អ្នកស្រី សាំង វ៉ាត់, អ្នកស្រី ចាន់ សុជាតិ, លោក យិន វំដួល និងអ្នកស្រី ប៉ូ ឌីណា បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សុំម្ដងទៀត។ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមក្នុងសំណុំរឿងលេខ០០២/១ ដោយបានរកឃើញថាជនជាប់ចោទ ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមានការសម្លាប់រង្គាល រួមបញ្ចូលការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត រួមមាន៖ ការផ្លាស់ទីលំនៅដោយបង្ខំ, ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបញ្ចប់នៅឆ្នាំ១៩៧៧។

[០៩:០៤:២៤]

ទន្ទឹមនឹងនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចប្រកាសផ្ដន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត។ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដោយ នួន ជា បានលើកទឡ្ហីករណ៍បណ្ដឹងសាទុក្ខចំនួន២២៣ ហើយ ខៀវ សំផន ចំនួន១៤៨ទឡ្ហីករណ៍ និងបានដាក់សំណើជាបន្តបន្ទាប់។

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាក៏បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹង

សាទុក្ខផងដែរ។ បន្ទាប់ពីបានទទួលសំណើរបស់ជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកនៃផ្នែកខ្លះនៃសំណើនោះ ដោយបានអនុញ្ញាតឲ្យ នួន ជា និង ខៀវ សំផន បន្ថែមចំនួនទំព័រ និងរយៈពេលលើសារណាបណ្តឹងសាទុក្ខរបស់ខ្លួនដោយសារទំហំនិងភាពស្មុគស្មាញនៃរឿងក្តីនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបន្ថែមចំនួនទំព័រ និងពេលវេលានៅក្នុងការដាក់សារណាតបរួម ជាភាសាអង់គ្លេសផងដែរ ដែលសារណាតបនេះ បានដាក់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ហើយភាសាខ្មែរនឹងដាក់តាមក្រោយ។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាអង់គ្លេស និងភាសាបារាំង។ សារណាបណ្តឹងសាទុក្ខនេះ ស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល ក្នុងនោះកោះហៅសាក្សីសរុបចំនួនប្រាំបួនរូប រួមទាំងអ្នកដែលត្រូវបានបញ្ជាក់អត្តសញ្ញាណកន្លងមក នៅក្នុងសំណើសុំទី១ និងទី៣ របស់ជនជាប់ចោទ។

[០៩:០៦:២៧]

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ដោយអនុលោមតាមវិធាន១០៨ កថាខណ្ឌ៧ នៃវិធានផ្ទៃក្នុង និងសម្រេចកោះហៅសាក្សីរហស្សនាម SCW-3, SCW-4 និង SCW-5 មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលតាមគំនិតផ្តួចផ្តើមរបស់ខ្លួនដោយអនុវត្តតាមវិធាន១០៤ កថាខណ្ឌ១ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានរក្សាសំណើរបស់ នួន ជា សុំកោះហៅសាក្សីផ្សេងទៀត មាន ហេង សំរិន, រ៉ូប៊ីត ដាំឃីន, អ៊ុក ប៊ុនឈឿន, ថេត សម្បត្តិ, សាក្សីរហស្សនាម SCW-1 និង SCW-2 ទុកសម្រេចនៅពេលក្រោយ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា សវនាការលើបណ្តឹងសាទុក្ខរបស់គូភាគីក្នុងសំណុំរឿងលេខ០០២/០១ ត្រូវបានចាប់ផ្តើម ក៏ប៉ុន្តែសវនាការនាពេលនេះ មានគោលបំណងពិសេសគឺដើម្បីពិនិត្យលើសាក្សីបីរូបដែលត្រូវបានស្នើឡើងនៅក្នុងបណ្តឹងសាទុក្ខ និងក្នុងសំណើទី៣ សុំដាក់ភស្តុតាងបន្ថែមរបស់ នួន ជា។

[០៩:០៧:៥៥]

អង្គជំនុំជម្រះបានសម្រេចថា ចំណុចទី១ គឺដើម្បីផលប្រយោជន៍យុត្តិធម៌ តម្រូវឲ្យស្តាប់សាក្សី SCW-3, SCW-4 ដោយអនុលោមតាមវិធាន១០៤ កថាខណ្ឌនៃវិធានផ្ទៃក្នុង និងចំណុចទី២ សាក្សី SCW-5 ពុំបានផ្តល់សក្ខីកម្មនៅពេលសវនាការឡើយ។ ដូច្នេះសក្ខីកម្មរបស់សាក្សីទាំងនេះ នឹងអាចជាកត្តាកំណត់នាំដល់ការធ្វើសេចក្តីសម្រេចស្របតាមវិធាន១០៨ កថាខណ្ឌ៧ នៃវិធានផ្ទៃក្នុង។ ដោយ

ហេតុថាសវនាការនេះធ្វើឡើងក្នុងគោលបំណងស្តាប់តែសាក្សីបីរូបនេះប៉ុណ្ណោះ ភាគីពុំត្រូវបានអនុញ្ញាតឲ្យធ្វើសារណាផ្ទាល់មាត់ទាក់ទងនឹងបញ្ហានានានៅក្នុងបណ្តឹងសាទុក្ខនេះទេ ហើយសវនាការលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខនេះនឹងត្រូវកំណត់ក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការនៅពេលក្រោយតាមពេលវេលាសមស្រប។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកថា នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីណែនាំស្តីពីកិច្ចនីតិវិធីសវនាការ ហើយកាលពីម្សិលមិញ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចលើសេចក្តីជំទាស់ទៅនឹងការប្រើប្រាស់ឯកសារក្នុងពេលតាំងសំណួរដល់សាក្សី។ ការតាំងសំណួរដល់សាក្សី ត្រូវអនុវត្តតាមសេចក្តីណែនាំ និងសេចក្តីសម្រេចនេះ។

[០៩:០៩:៤៦]

សវនាការក្នុងថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្តាប់សាក្សី SCW-4 ដែលមានឈ្មោះ សៅ វ៉ន។ សវនាការនៅថ្ងៃស្អែកស្តាប់សាក្សី SCW-3 ហើយនៅថ្ងៃច័ន្ទ ទី០៦ ខែកក្កដា ឆ្នាំ២០១៥ នឹងស្តាប់សាក្សី SCW-5។

ជាបន្តសូមអញ្ជើញលោក យ៉ា ណារិន ជាសហចៅក្រមរបាយការណ៍ ជាមួយនឹងលោកស្រីចៅក្រម ម៉ុមបា អានរបាយការណ៍!

**ចៅក្រម យ៉ា ណារិន៖**

របាយការណ៍របស់សហចៅក្រមរបាយការណ៍ សវនាការថ្ងៃទី០២ ទី០៣ និងទី០៦ ខែកក្កដា ឆ្នាំ២០១៥៖

ដូចដែលបានលើកឡើងដោយប្រធានអង្គជំនុំជម្រះតុលាការកំពូលថា គោលបំណងសំខាន់នៃសវនាការនេះ គឺដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី SCW-4, SCW-3 និង SCW-5។ នួន ជា លើកឡើងសក្ខីកម្មទាំងនេះអាចនឹងមានអានុភាពកែតម្រូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ជាពិសេសទាក់ទងទៅនឹងរចនាសម្ព័ន្ធបញ្ជានៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់គោលដៅលើទាហាន និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និងចុងក្រោយការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃ។ អាស្រ័យហេតុនេះ វិសាលភាពនៃរបាយការណ៍នេះកម្រិតត្រឹមតែទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ហាទាំងនេះ។ ទោះជាយ៉ាងនេះក្តី ក្នុងន័យនេះ ពុំមែនមានន័យថាសក្ខីកម្មរបស់សាក្សីទាំងនេះ ពុំត្រូវបានយកទៅពិចារណានៅពេលណាមួយទាក់

ទងនឹងទឡ្ហីករណ៍ដទៃទៀតនៃបណ្តឹងសាទុក្ខនោះឡើយ។

ជាដំបូង ខ្ញុំនឹងលើកនូវសារណាភាគីពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា បន្ទាប់មក ខ្ញុំនឹងប្រគល់ជូនទៅលោកស្រីសហចៅក្រមរបាយការណ៍ ម៉ុមបា ដែលនឹងធ្វើសេចក្តីសង្ខេបលើសារណារបស់ភាគីទាក់ទងនឹងចំណុចផ្សេងៗទៀត។

[០៩:១២:០៦]

១) រចនាសម្ព័ន្ធបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា: អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាគណៈអចិន្ត្រៃយ៍គឺជាអ្នកគ្រប់គ្រងទាំងស្រុងលើបក្សកុម្មុយនីស្តកម្ពុជា។ គណៈអចិន្ត្រៃយ៍នេះមាន សមាជិក ៧រូប ដែលមិនមានចែងនៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ក្នុងនោះមាន នួន ជា ផងដែរ។ ចំពោះ ខៀវ សំផន វិញពុំដែលបានចូលជាសមាជិកនៃគណៈអចិន្ត្រៃយ៍នេះទេ ប៉ុន្តែគាត់ធ្លាប់បាន ចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍មួយចំនួនផងដែរ។ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា បក្សកុម្មុយ-នីស្ត -- មជ្ឈិមបក្សបានផ្អែកក្នុងចំណោមនោះទៅលើភូមិភាគដែលជាតំបន់រដ្ឋបាល ដែលកម្ពុជាប្រជាធិបតេយ្យបានបែងចែកសម្រាប់អនុវត្តនូវសេចក្តីសម្រេចរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា មជ្ឈិមបក្សបង្កើតផែនការ និងសម្របសម្រួលក្នុងការបន្លាស់ទីប្រជាជន រួមទាំងគោលនយោបាយចំពោះសត្រូវ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា សេចក្តីសម្រេចទាំងនេះត្រូវបានបង្កើតឡើងស្របទៅនឹងអ្វីដែលគេហៅថា គោលនយោបាយនៃការធ្វើមជ្ឈការនិយម។ គោល-ការណ៍នេះមួយផ្នែកមានន័យថា សេក្តីសម្រេចរបស់បក្សត្រូវបានបង្កើតឡើងជារួម មិនមែនជាបុគ្គលនោះទេ ហើយមួយផ្នែកទៀត គឺមានន័យថា សេចក្តីសម្រេចនេះត្រូវបានធ្វើឡើងដោយកម្មាភិបាលជាន់ខ្ពស់របស់មជ្ឈិមបក្ស។

[០៩:១៣:៣២]

ជាចុងក្រោយអង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសន្និដ្ឋានពីខ្សែបណ្តាញទំនាក់ទំនងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះបានកំណត់ថា ភូមិភាគ និងតំបន់ស្វយ័តនានា បានរាយការណ៍ទៅមជ្ឈិមបក្ស និងទទួលសេចក្តីណែនាំពីមជ្ឈិមបក្សដោយផ្ទាល់។ ឧទាហរណ៍សារដែលភូមិភាគបានផ្ញើ មានដូចជាសំណើសុំសេចក្តីណែនាំផ្សេង ឬសំណើសុំជួយផ្នែកសម្ភារៈពីមជ្ឈិមបក្ស។ ចំណែកកម្មាភិបាលនៃភូមិភាគវិញ ត្រូវទទួលសេចក្តីណែនាំពីមជ្ឈិមបក្ស ឬពីមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាជាបុគ្គល មានដូចជា នួន ជា និង ខៀវ សំផន។

នៅក្នុងបណ្តឹងសាទុក្ខ នួន ជា លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញភស្តុតាងគាំទ្រដល់ការយល់ឃើញរបស់ខ្លួនទាក់ទងទៅនឹងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលធ្វើសកម្មភាពនៅក្នុងស្ថាប័នមួយ ដែលរួបរួមគ្នាគ្រប់គ្រងយ៉ាងរឹងមាំតាមឋានានុក្រមមានរាងជាសាជី។ នួន ជា បានអះអាងថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំយល់ឃើញឲ្យបានពេញលេញ និងសមហេតុផលទៅលើសិទ្ធិអំណាចរបស់មេដឹកនាំភូមិភាគ ដែលមានអំណាចឯករាជ្យក្នុងការធ្វើសេចក្តីសម្រេច និងបានអនុវត្តសកម្មភាពដែលពុំមែនជាគោលនយោបាយ ឬសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ។ នួន ជា ជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់ចរិតលក្ខណៈលើភស្តុតាងឲ្យបានត្រឹមត្រូវ ដោយហេតុថា មជ្ឈិមបក្សរួមទាំងរូបគាត់ផងដែរពុំសូវធ្វើការទាក់ទងជាមួយភូមិភាគនោះទេ ហើយប្រសិនបើមានក៏ពុំបាននិយាយអំពីការប្រព្រឹត្តអំពើល្មើសនោះឡើយ។ នួន ជា អះអាងទៀតថា អង្គជំនុំជម្រះសាលាដំបូងពុំអើពើចំពោះការប៉ះទង្គិចគ្នារវាងកងទ័ពភូមិភាគនិងភូមិភាគ ដែលជាការផ្ទុយទៅនឹងការកំណត់ចរិតលក្ខណៈរបស់ខ្លួនលើបក្សកុម្មុយនីស្តថា ជាបក្សមួយដែលមានរចនាសម្ព័ន្ធរួបរួមគ្នារឹងមាំ។ បន្ថែមលើនេះទៀត នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានបដិសេធក្នុងការស្តាប់សាក្សីដែលមានទំនាក់ -- ដែលបានធ្វើការទំនាក់ទំនងជាមួយកម្មាភិបាលដែលមានអំណាចនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាល។

[០៩:១៥:៥៧]

ក្នុងបណ្តឹងសាទុក្ខ ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសដោយបានបកស្រាយពុំត្រឹមត្រូវរាល់ភស្តុតាងដែលអាចធ្វើការសន្និដ្ឋានបានថា រូបគាត់ពុំបានចូលរួមក្នុងកិច្ចប្រជុំធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឡើយ។ ខៀវ សំផន អះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានយល់ឃើញថា រូបគាត់មានអំណាចធ្វើសេចក្តីសម្រេចនៅក្នុងគណៈមជ្ឈិម បើទោះជា -- បើទោះបីជារូបគាត់គ្រាន់តែជាសមាជិកបម្រុងក៏ដោយ។ ខៀវ សំផន ជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានលើកឡើងថា តើអ្នកណាខ្លះដែលជាប់ពាក់ព័ន្ធនៅគ្រប់ពេលវេលាដែលអង្គជំនុំជម្រះប្រើពាក្យពេចន៍មជ្ឈិមបក្ស និងអង្គការ ដែលនាំឲ្យការសន្និដ្ឋានពុំត្រឹមត្រូវថារូបគាត់ជាប់ពាក់ព័ន្ធនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ។ ជាចុងក្រោយ ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវិភាគរបស់ខ្លួន ពីរចនាសម្ព័ន្ធបញ្ជាយោធា និងពីទំនាក់ទំនងជាមួយមជ្ឈិមបក្ស។

សហព្រះរាជអាជ្ញាលើកឡើងនៅក្នុងសារណាតបរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងសមហេតុផល លើតួនាទីមេដឹកនាំភូមិភាគក្នុងរចនាសម្ព័ន្ធនៃឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា។ សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈយ៉ាងត្រឹមត្រូវលើភស្តុតាងនៃសេចក្តីណែនាំដែលបានចេញដោយមជ្ឈិមបក្សនោះ ពុំមែនជារឿងកម្រកើតមាន ឬមានកម្រិតឡើយទាក់ទងទៅនឹងវិសាលភាពនិងខ្លឹមសារនេះ។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះដំបូងទាក់ទងទៅនឹងអំណាចរបស់មជ្ឈិម -- របស់គណៈមជ្ឈិម ខ្សែបណ្តាញនៃទំនាក់ទំនង រចនាសម្ព័ន្ធយោធា គោលការណ៍ ការធ្វើមជ្ឈការនិយមប្រជាធិបតេយ្យនិងលាក់ការណ៍ និងការប្រើប្រាស់ពាក្យពេចន៍នានាដូចជាមជ្ឈិមបក្ស និងអង្គការ។

ជាកិច្ចបន្ត ខ្ញុំប្រគល់នាទីនេះជូនលោកស្រីសហចៅក្រមរបាយការណ៍ ម៉ុមបា ដើម្បីធ្វើ -- ដើម្បីបន្តធ្វើ -- ដើម្បីបន្តលើកសារណារបស់ភាគីទាក់ទងនឹងការកំណត់គោលដៅលើទាហាន និងមន្ត្រីរបបសាធារណរដ្ឋខ្មែរ និងការសម្លាប់នៅទួលពោធិ៍ជ្រៃបាទ។

[០៩:១៨:២៩]

**ចៅក្រម ផ្លូរិនស៍ ម៉ុមបាៈ**

ផ្នែកទី២ គឺការកំណត់គោលដៅលើមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ។

អង្គជំនុំជម្រះសាលាដំបូងអះអាងថា បក្សកុម្មុយនីស្តកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តគោលនយោបាយមួយដែលមេដឹកនាំរបស់ខ្លួនបានយល់ព្រមក្នុងការកំណត់គោលដៅដើម្បីចាប់ខ្លួន ធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការសម្លាប់អតីតមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ។ គោលនយោបាយនេះកើតមាននៅមុន ក្នុងអំឡុងពេល និងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥។ អង្គជំនុំជម្រះក៏បានបង្ហាញផងដែរថា ទាហានខ្មែរក្រហមមានបំណងសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរជាទ្រង់ទ្រាយធំ ហើយជាលទ្ធផលបានធ្វើការសម្លាប់យ៉ាងរង្គាល និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ទម្រង់ច្បាស់លាស់មួយនៃការសម្លាប់ជាទ្រង់ទ្រាយធំ ពោលរួមទាំងការសម្លាប់នៅទួលពោធិ៍ជ្រៃ។

នៅក្នុងបណ្តឹងសាទុក្ខ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុក្នុងការវាយតម្លៃលើភស្តុតាង ទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់គោលដៅមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ។

នួន ជា ជំទាស់ថាពុំមានគោលនយោបាយ ឬទម្រង់នៃការសម្លាប់បែបនេះកើតមានមុន ក្នុងអំឡុង ឬក្រោយខែមេសា ឆ្នាំ៧៥ឡើយ។ ជាការគាំទ្រដល់អះអាងរបស់ខ្លួន នួន ជា បានលើកឡើងអង្គជំនុំជម្រះសាលាដំបូងពុំបានវាយតម្លៃឲ្យបានត្រឹមត្រូវលើភស្តុតាង។ គួរកត់សម្គាល់ អង្គជំនុំជម្រះសាលាដំបូងក្នុងនោះបានជ្រើសរើសយកភស្តុតាងមួយចំនួនយកមកប្រើប្រាស់ដោយដកស្រង់ប្រភពមិនគួរឲ្យទុកចិត្តបាន ពុំបានយោងទៅភស្តុតាងឲ្យបានគ្រប់គ្រាន់ទាក់ទងនឹងការសម្លាប់ និងការកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើភស្តុតាងដោះបន្ទុកឡើយ។

[០៩:១៩:៥៨]

ហេតុដូច្នេះ នួន ជា សន្និដ្ឋានថាអង្គជំនុំជម្រះសាលាដំបូងពុំបានពិចារណាទៅលើផ្នែកផ្សេងៗនៃភស្តុតាងដែលជាប់ពាក់ព័ន្ធ ហើយមានកំហុសក្នុងការយល់ឃើញទៅលើឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម។ នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ខៀវ សំផន បានលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានការបង្កើតគោលនយោបាយក្នុងការកំណត់គោលដៅលើទាហានសាធារណរដ្ឋខ្មែរ ពីព្រោះអង្គជំនុំជម្រះពុំបានអើពើទៅលើលក្ខណៈនៃរបបសាធារណរដ្ឋខ្មែរដែលមានការសង្កត់សង្កិន និងសាវតារនៃរបបនេះ ដែលនាំឲ្យមានសង្គ្រាមឆាបឆេះឡើង។ ខៀវ សំផន អះអាងថាចំពោះការដែលយល់ឃើញថា ទាហានសាធារណរដ្ឋខ្មែរត្រូវបានកាប់សម្លាប់នៅឧដុង អង្គជំនុំជម្រះសាលាដំបូងពុំគប្បីបានផ្អែកទៅលើចម្លើយរបស់គាត់នៅក្នុងសុន្ទរកថាមួយ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ៧៤ ថា មានសត្រូវ៥០០០នាក់ត្រូវបានកម្ទេច ពីព្រោះសន្ទរកថានេះគឺជាប្រភពដែលមិនគួរឲ្យទុកចិត្តបាន និងជាការឃោសនាបំផ្លើសមួយប៉ុណ្ណោះ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលបានផ្អែកទៅលើភស្តុតាងគាំទ្រខ្សោយចំពោះការកាប់សម្លាប់ទ្រង់ទ្រាយធំ បានដកស្រង់ទស្សនាវដ្តីដែលពុំបានពិចារណាទៅលើបរិបទ និងធ្វើសេចក្តីសន្និដ្ឋានផ្ទុយទៅវិញ។ ចុងក្រោយ ខៀវ សំផន អះអាងថា អង្គជំនុំជម្រះសាលាដំបូងប្រើប្រាសភស្តុតាងតាមលំដាប់លំដោយយ៉ាងប៉ិនប្រសប់ដែលបានដកស្រង់នូវប្រភពនានា គិតចាប់ពីពេលបញ្ចប់ជម្លោះប្រដាប់អាវុធ។ សហព្រះរាជអាជ្ញាឆ្លើយតបថា អង្គជំនុំជម្រះសាលាដំបូង មានហេតុផលសមស្របក្នុងការយល់ឃើញថាមានការបង្កើតគោលនយោបាយមួយ ដើម្បីកំណត់គោលដៅចាប់ខ្លួន ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការកាប់សម្លាប់ចំពោះមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ។ សហព្រះរាជអាជ្ញាក៏បានអះអាងផងដែរថា ទម្រង់នៃការកាប់សម្លាប់នេះមានទ្រង់ទ្រាយធំទូទាំងប្រទេស។

ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើការសម្រេចរបស់ខ្លួនទៅលើការពិចារណាយ៉ាងយកចិត្តទុកដាក់ចំពោះភស្តុតាងទាំងមូល និងផ្នែកខ្លះនៃទម្រង់នេះដែលមានលក្ខណៈស៊ីចង្វាក់គ្នាក្នុងគោលដៅ កំណត់លើទាហានទាំងនោះ។ សហព្រះរាជអាជ្ញាក៏បានជំទាស់ផងទៅនឹងភាពចំបាច់ក្នុងការពិចារណាលើការបកស្រាយនីមួយៗជាមួយចំពោះភស្តុតាងទាំងនោះ។ ចំពោះ ខៀវ សំផន សហព្រះរាជអាជ្ញាបានលើកឡើងថា ខៀវ សំផន ធ្វើអំណះអំណាងជាលក្ខណៈទូទៅ និងគ្មានមូលដ្ឋានត្រឹមត្រូវក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស។ ទី៣ ទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នៅក្នុងថ្ងៃប្រហែលជា ២៥ ឬ ២៦ ខែមេសា ឆ្នាំ៧៥ មានអតីតនិងទាហានសាធារណរដ្ឋខ្មែរយ៉ាងតិច២៥០ នាក់ត្រូវបានដឹកតាមឡានទៅទួលពោធិ៍ជ្រៃ ក្រោយមកត្រូវបានសម្លាប់នៅទីនោះ ដែលជាផ្នែកមួយនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ក្នុងការកំណត់គោលដៅដើម្បីកាប់សម្លាប់អតីតសមាជិកនៃរបបលន់នល់។ អង្គជំនុំជម្រះបានបង្ហាញថា ការកាប់សម្លាប់នោះកើតឡើងនៅទួលពោធិ៍ជ្រៃជាចម្បងផ្អែកលើភស្តុតាងដែលបានផ្តលដោយសាក្សីបីរូប ដែលសាក្សីនោះត្រូវបានគេជឿថា អាចជឿជាក់បាន។ អង្គជំនុំជម្រះសាលាដំបូងអះអាងថា បើទោះបីជាសាក្សីទាំងនោះពុំមានវត្តមាននៅកន្លែងកើតហេតុទួលពោធិ៍ជ្រៃក៏ដោយ ក៏ខ្ញុំបានស្តាប់នូវភស្តុតាងសំខាន់ជាច្រើន ដែលបានធ្វើសេចក្តីសន្និដ្ឋានបានយ៉ាងច្បាស់លាស់។ ក្នុងបណ្តឹងសាទុក្ខ នួន ជា បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសពុំបានពិនិត្យឲ្យបានល្អិតល្អន់លើភស្តុតាងរបស់សាក្សីទាំងបីរូបនេះ ដែលបានផ្តល់សក្ខីកម្មអំពីទួលពោធិ៍ជ្រៃ។ ជាពិសេសបើទោះបីជាសាក្សីទាំងនោះពុំបាននៅជិតកន្លែងកើតហេតុ និងបានផ្តល់ភស្តុតាងផ្ទុយក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់ថា ភស្តុតាងទាំងនោះមានលក្ខណៈស៊ីចង្វាក់គ្នា និងគួរឲ្យទុកចិត្តបាន។ នួន ជា អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ក្នុងការកំណត់គោលដៅលើអតីតមន្ត្រីនិងទាហានសាធារណរដ្ឋខ្មែរ គឺជាប់ពាក់ព័ន្ធទៅនឹងការកាប់សម្លាប់លើអតីតមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ ចុងក្រោយ នួន ជា បានជំទាស់ថាការយល់ឃើញផ្អែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ គឺគ្រាន់តែយើងមកប្រើប្រាស់លើការយល់ឃើញរបស់ខ្លួនស្តីអំពីការទទួលខុសត្រូវរបស់ នួន ជា ចំពោះការប្រព្រឹត្តនៅក្នុងសហឧក្រិដ្ឋកម្មរួម ដែល នួន ជា បានលើកឡើងរួមមកហើយថាពុំមានលក្ខណៈត្រឹមត្រូវឡើយ។ នៅក្នុង

បណ្តឹងសាទុក្ខ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ ពីព្រោះវាពុំបានបង្ហាញឲ្យហួសពីវិមតិសង្ស័យ ដែលថា គាត់បានដឹងអំពីទម្រង់នៃការកំណត់គោលដៅលើមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ។ ខៀវ សំផន បានជំទាស់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងការយល់ឃើញមួយចំនួនទៅលើអង្គហេតុ នៅក្រោមយុត្តាធិការពេលារបស់ អ.វ.ត.ក។ ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដែលពុំបានកំណត់វិសាលភាពច្បាស់លាស់ ស្តីពីកិច្ចដំណើរការនីតិវិធីរបស់ដល់ពេលបញ្ចប់ការជំនុំជម្រះ។ ហេតុនេះបានរារាំងដល់ការការពារខ្លួនឲ្យមានប្រសិទ្ធភាពដោយសារគាត់តែងតែចាត់ទុកទួលពោធិ៍ជ្រៃពុំមែនជាចំណុចសំខាន់នៃវិធានការស្តីពីកំណត់គោលដៅទៅលើក្រុមជាក់លាក់ដែលពុំមែនជាសត្រូវនោះឡើយ។ ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានយល់ឃើញថា ការគ្រាន់តែបង្ហាញពីចេតនាក្នុងការចូលរួមក្នុងគោលបំណងរួម គឺគ្រប់គ្រាន់ក្នុងការបង្ហាញពីធាតុអត្តនោម័តិ ចំពោះការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃ។

[០៩:២៥:០០]

ចុងក្រោយ ខៀវ សំផន អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថាគាត់បានដឹងថា ឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ និងថា វត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំមួយចំនួនរបស់ថ្នាក់ដឹកនាំខ្មែរក្រហម បង្កើតបានជាកត្តារួមចំណែកក្នុងការសម្រេចលើឧក្រិដ្ឋកម្មនោះហើយថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ គឺអាចទាញចេញពីការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមដែលរងការចោទប្រកាន់នោះ។ សហព្រះរាជអាជ្ញាឆ្លើយតបថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធ ទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃមានលក្ខណៈសមហេតុផល និងបានសំអាងទៅលើភស្តុតាងទាំងមូល។ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះបានផ្អែកយ៉ាងសមហេតុផល ទៅលើសក្ខីកម្មកម្មរបស់សាក្សីបីរូប ដែលបានលើកឡើងខាងលើ ហើយមានលក្ខណៈស៊ីចង្វាក់គ្នាជាមួយភស្តុតាងដទៃ។ សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញដោយសមហេតុផលថា មានការបង្កើតឡើងនូវគោលនយោបាយក្នុងការកំណត់គោលដៅលើអតីតមន្ត្រីនៃទាហានសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ ទីបញ្ចប់ សហព្រះរាជអាជ្ញាអះអាងថា ខៀវ សំផន ពុំបានធ្វើការយោងទៅលើលក្ខខណ្ឌតម្រូវស្តីពីការដឹង ឬចេតនា ហើយពុំបានបង្ហាញថាតើកំហុសពាក់ព័ន្ធនឹងបញ្ហានេះ អាចមោឃៈសេចក្តីសម្រេចដោយរបៀបណានោះឡើយ។

សូមបញ្ចប់របាយការណ៍។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីរហស្សនាម SCW-4 មកចំពោះមុខតុលាការ។

[០៩:២៧:១៦]

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំសូមកត់សម្គាល់លើនីតិវិធីរបស់លោកប្រធានអម្បាញ់មិញ។ ជាភាសាខ្មែរស្តាប់ទៅដូចជាលឿនពេក ពិបាកស្តាប់បន្តិច បើសិនជាអាច សូមឲ្យពន្យឺត ការធ្វើទាំងអាន ទាំងការសួរ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមជម្រាបដែរថា សូមឲ្យការអានក៏ដោយ ការនិយាយក៏ដោយ គឺសូមឲ្យយឺតជាងនេះបន្តិច។

សាក្សី លោកត្រូវបានតុលាការកំពូលកោះហៅមកដើម្បីស្តាប់សំណួរ និងឲ្យឆ្លើយចំពោះសំណួរដែលបន្តិចទៀត យើងនឹងធ្វើដោយសហមេធាវីការពារក្តីរបស់ជនជាប់ចោទ និងភាគីផ្សេងទៀត។

[០៩:២៨:៥១]

**ការតាំងសំណួរដោយចៅក្រម**

**ប្រធានអង្គជំនុំ៖**

**ស៖** លោកឈ្មោះអីទៅ?

**លោក សៅ វ៉ន៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** ឈ្មោះហៅក្រៅ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កើតនៅថ្ងៃ ខែ ឆ្នាំណា?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** អ៊ីចេះលោកសាក្សី នៅពេលដែលលោកឆ្លើយ លោកចាំពិនិត្យមើលនៅក្នុងក្បាលមីក្រូរបស់លោកហ្នឹង បើសិនជាមានភ្លើងលោតហើយ សឹមលោកនិយាយ តែអ៊ីចឹងអត់ចូលទៅក្នុង -- គេស្តាប់អត់បានទេ។ អ៊ីចឹងម្តងទៀត។ លោកឈ្មោះអី?

**ឆ៖** ខ្ញុំឈ្មោះ សៅ វ៉ន។

**ស៖** ឈ្មោះ ហៅក្រៅ?

**ឆ៖** សៅ ពត។

**ស៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ឆ៖** កើតនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៤១។

[០៩:៣០:០០]

**ស៖** នៅភូមិ ឃុំ ស្រុក ខេត្តណា?

**ឆ៖** នៅភូមិស្រែខ្វាវ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** លោកមានសញ្ជាតិជាអ្វី?

**ឆ៖** ខ្ញុំមានសញ្ជាតិជាខ្មែរ។

**ស៖** មុខរបរបច្ចុប្បន្ន?

**ឆ៖** មុខរបរបច្ចុប្បន្ន ធ្វើស្រែ និងជាសមាជិកក្រុមប្រឹក្សាឃុំជាងទង។

**ស៖** ឪពុកលោកឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ សៅ មី (ស្លាប់)។

**ស៖** ម្តាយលោក?

**ឆ៖** ម្តាយខ្ញុំឈ្មោះ សុខ ប៉េង (ស្លាប់)។

**ស៖** ប្រពន្ធលោក?

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ ញឹម អ៊ីន។

**ស៖** រស់ ឬក៏ស្លាប់?

**ឆ៖** នៅរស់សព្វថ្ងៃ។

**ស៖** មានកូនប៉ុន្មាននាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

**ឆ៖** មានកូនប្រាំបួននាក់ ប្រុសប្រាំ ស្រីបួន។

**ស៖** ទីលំនៅបច្ចុប្បន្នរបស់លោកនៅទីណា?

**ឆ៖** ទីលំនៅបច្ចុប្បន្ននៅភូមិស្រែខ្វាវ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។

[០៩:៣២:១៣]

**សះ** សាក្សីលោកមានទំនាក់ទំណងញាតិជាមួយជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

**ឆះ** ខ្ញុំអត់មានទាក់ទងជាមួយជាមួយនឹងចុងចោទ ឬជាអ្នកដើមបណ្តឹងទេ។

**សះ** លោកបានស្បថហើយឬនៅ?

**ឆះ** ខ្ញុំបានស្បថរួចហើយ។

**សះ** សាក្សីលោកមានសិទ្ធិមិនឆ្លើយនឹងសំណួរ ឬក៏ធ្វើការអំណះអំណាងណាមួយដែលនាំឲ្យមានពិរុទ្ធទៅលើលោក។ ប៉ុន្តែលោកត្រូវឆ្លើយនឹងសំណួរទាំងឡាយលើកលែងតែសំណួរ ឬក៏ការធ្វើអំណះអំណាងណាដែលនាំឲ្យលោកមានពិរុទ្ធភាព។ លោកត្រូវឆ្លើយនូវអ្វីដែលជាការពិត តាមការដឹងការឮ បានឃើញ ចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ ឬបានសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុ-ការណ៍ពាក់ព័ន្ធនឹងសំណួរ។ លោកធ្លាប់បានឆ្លើយនៅពីមុនមកទេ នៅចំពោះមុខ អ.វ.ត.ក យើងនេះ?

**ឆះ** ពីពេលមុនខ្ញុំបានឆ្លើយនៅចំពោះមុខ តុលាការ អ.វ.ត.ក។

**សះ** នៅចំពោះមុខសវនាការ ឬក៏នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត?

**ឆះ** នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត សាលាដំបូង។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញសហមេធាវីការពារក្តីជនជាប់ចោទ នួន ជា តាំងសំណួរដល់សាក្សី!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញា មេធាវីការពារក្តីទាំងអស់។

[០៩:៣៥:០០]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**សះ** លោកសាក្សី ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ ជាមេធាវី សហមេធាវីអន្តរជាតិរបស់លោក នួន ជា។ ហើយខ្ញុំសូមសួរសំណួរខ្លះទៅលោកនៅព្រឹកនេះ។ លោកទើបតែបានឆ្លើយសំណួររបស់លោកប្រធានអំពីកំណត់ហេតុស្តាប់ចម្លើយរបស់លោកដោយសចៅក្រមស៊ើបអង្កេត។ តើលោកមានបានផ្តល់ចម្លើយនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** នៅឆ្នាំ២០១៣ ខ្ញុំបានឆ្លើយសំណួរស៊ើបអង្កេត បាទ។

**ស៖** ហើយនៅពេលលោកឆ្លើយទៅនឹងកិច្ចសម្ភាសន៍ហ្នឹង តើកិច្ចសម្ភាសន៍នេះ ធ្វើឡើងនៅសាលាឃុំជាងទង មែនទេ?

**ឆ៖** បាទ ខ្ញុំបានសម្ភាសនៅសាលាជាងទង។

**ស៖** លោកសាក្សី តើលោកបានឆ្លើយទៅនឹងមន្ត្រីស៊ើបអង្កេតរបស់អង្គការមួយ ហៅថា មជ្ឈ-មណ្ឌលឯកសារកម្ពុជា (ឌី.ស៊ី.ខេម) ដែរឬទេ?

**ឆ៖** ខ្ញុំបានឆ្លើយ ប៉ុន្តែមិនបាន -- ស៊ើបអង្កេតហ្នឹង គឺកាលពេលហ្នឹង មានអង្គការស៊ើបអង្កេតទៅសួរនៅផ្ទះខ្ញុំ។ ប៉ុន្តែឆ្នាំ ខ្ញុំភ្លេចទៅហើយ។

**ស៖** លោកសាក្សី ប្រហែលជាខ្ញុំអាចនឹងជួយលោកបាន។ តើកិច្ចសម្ភាសន៍ហ្នឹងប្រហែលជាធ្វើឡើងនៅឆ្នាំ២០១១ ខែមេសា ឆ្នាំ២០១១ មែនទេ?

[០៩:៣៧:២៧]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន។ លោក លោកស្រីចៅក្រម តាមដែលខ្ញុំយល់ថា ការសម្រេចរបស់អង្គជំនុំជម្រះកាលពីយប់មិញនោះ គឺថាកិច្ចសម្ភាសន៍ដែលមេធាវីកំពុងសួរនេះ ហើយកាលដែលផ្តល់កាលបរិច្ឆេទទៅដល់សាក្សីនេះ គឺមិនអនុញ្ញាតឲ្យធ្វើបែបហ្នឹង នៅក្នុងកថាខណ្ឌ៤ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលគឺថាមិនអាចត្រូវតាំងសំណួរបែបនេះបានទេ។ តើការតាំងសំណួរបែបនេះ អង្គជំនុំជម្រះអនុញ្ញាត ឬក៏យ៉ាងណា?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន តាមជាការពិត ខ្ញុំក៏បានដឹងអំពីសេចក្តីសម្រេចរបស់តុលាការកំពូលកាលពីយប់មិញនេះដែរ។ ខ្ញុំសួរតែអ្វីទាក់ទងទៅនឹងខ្លឹមសារនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយដែលគាត់បានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាតែប៉ុណ្ណោះ។ គឺបានឆ្លើយជូនទៅខាង ដាប់បាយូ.អ័រ.អាយ នោះផងដែរ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

យើងសុំឲ្យភាគីទាំងអស់ គឺមេត្តាកុំសួរសំណួរនាំមុខ។ យើងយល់ថាជាអង្គហេតុដែលបានដាក់

នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលហើយ ក៏ប៉ុន្តែដើម្បីប្រតិចារឹកសម្រាប់នាថ្ងៃមុខនោះ គ្រាន់តែសួរថា ធ្វើឡើងនៅពេលណា? ធ្វើឡើងនៅកន្លែងណា? វាជា -- នោះវានឹងស្របទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះហើយ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកស្រីចៅក្រម អាកនីស្កា។ ខ្ញុំនឹងព្យាយាមជៀសវាងសួរនូវសំណួរនាំមុខ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកសាក្សី តើលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងពេលថ្មីៗនេះដែរឬទេ?

[០៩:៣៩:២៧]

**លោក សៅ វ៉ន៖**

**ឆ៖** ខ្ញុំបានឆ្លើយ។ ជម្រាប ស៊ើបអង្កេតពីថ្ងៃមុននេះ ប៉ុន្មានខែមុននេះ ខ្ញុំមិនចាំទេ បាទ។

**ស៖** ហើយតើមន្ត្រីស៊ើបអង្កេតសម្ភាសលោកនៅឯណាដែរ? សម្ភាសនៅទីតាំងកន្លែងណាដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ចម្លើយនេះខ្ញុំឆ្លើយ ទោះបីពេលខ្ញុំឆ្លើយ ថាសម្ភាសនៅសាលាឃុំម្តង ជាងទងហើយថ្ងៃនេះ ខែមុននេះ សម្ភាសនៅកន្លែង កន្លែងហ្នឹងសាលានេះតែម្តង។

**ប្រធានអង្គជំនុំ៖**

លោកបញ្ជាក់ម្តងទៀតមើល៍ អំមិញហ្នឹង គឺតើលោកបានសម្ភាសហ្នឹងនៅកន្លែងណានៅពេលលើកក្រោយនេះ?

លោកកុំអាលឆ្លើយ អត់ទាន់មានភ្លើងក្រហមផង។

**លោក សៅ វ៉ន៖**

**ឆ៖** បាទ ខ្ញុំសុំឆ្លើយ ខ្ញុំបានសម្ភាសដែលថ្ងៃមុននេះ នៅខែមុននៅកន្លែងតុលាការដំបូងទៅអញ្ជើញខ្ញុំមកបាទ ប៉ុន្តែខ្ញុំអត់បានចាំថ្ងៃ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** តើវាប្រហែលជាពីរបីខែមុន បីបួនខែមុន? លោកអាចផ្តល់ពេលវេលានេះឲ្យបានច្បាស់លាស់បន្តិចបានទេ?

**ឆ៖** សូមជម្រាបលោកម្ចាស់សួរសំណួរ បាទ ខ្ញុំមិនបានចាំទេ តែឯកសារខ្ញុំបានសម្ភាសរួច

ហើយ ឯកសារប្រហែលនឹងនៅដៃរបស់លោកហើយបាទ។ សុំអស់យោបល់។

**ស៖** លោកសាក្សី លោកចាំថាតើអ្នកស៊ើបអង្កេតមានជម្រាបទៅលោកថា ហេតុអ្វីបានជាពួកគាត់ទៅសម្ភាសលោកសាជាថ្មីម្តងទៀតទេ?

**ឆ៖** អត់មានបានប្រាប់ទេ។

[០៩:៤២:៣០]

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីប្រតិចារឹក លោកប្រធាន យើងខ្ញុំយល់ឃើញថា ខ្ញុំនឹងបន្តសំណួរតទៅមុខ ប៉ុន្តែចំពោះកំណត់ហេតុស្តាប់ចម្លើយនេះដូចជាមិនដំណើរការទៅមុខទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកមានបងប្អូនស្រីប្រុសដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** ខ្ញុំមានបងប្អូនស្រីប្រុស។ សុំអស់យោបល់ហើយបាទ។

**ស៖** លោកសាក្សីលោកមានបងប្អូនប្រុសប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានបងប្អូនប្រាំបីនាក់, ប្រុសបី ស្រីប្រាំ។ បាទ សូមជម្រាបលោកការពិតអស់ហើយ។

**ស៖** លោកសាក្សីលោកអាចជម្រាបឈ្មោះបងប្អូនប្រុស ពីរនាក់របស់លោកបានទេ?

**ឆ៖** ខ្ញុំអាចជម្រាបលោកបាន។ ១) បងប្រុសរបស់ខ្ញុំឈ្មោះ សៅ ជ្រុន, ២) ប្អូនប្រុសរបស់ខ្ញុំឈ្មោះ សៅ ចំរើន។ បច្ចុប្បន្ន សៅ ចំរើន នៅទីក្រុងភ្នំពេញ ឯបងប្រុសឈ្មោះ សៅ ជ្រុន បច្ចុប្បន្ននៅឃុំរកា ស្រុកទ្រាំង ខេត្តតាកែវ បច្ចុប្បន្ន។

**ស៖** តើបង និងប្អូនប្រុសរបស់លោក សព្វថ្ងៃនេះមានមុខងារអ្វីដែរ? ធ្វើការអ្វីដែរ?

**ឆ៖** បើបងប្រុសរបស់ខ្ញុំអត់មានធ្វើការអីទេ គាត់ចាស់ហើយ គាត់នៅជាមួយក្នុងបន្ទុកកូន។ ឯប្អូនប្រុសរបស់ខ្ញុំរកស៊ីប្រពន្ធ -- រស់នៅក្នុងបន្ទុកជាមួយកូនដែរបាទ។

[០៩:៤៥:០០]

**ស៖** ចុះលោកវិញ សព្វថ្ងៃតើលោកធ្វើអ្វីដែរ?

**ឆ៖** សូមជម្រាបថាខ្ញុំបច្ចុប្បន្នជាកសិករ ប៉ុនតួនាទីប្រចាំថ្ងៃ គឺខ្ញុំបាទធ្វើជាសមាជិកក្រុមប្រឹក្សាឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** តើលោកជាសមាជិកក្រុមប្រឹក្សាឃុំឱ្យគណបក្សនយោបាយណាមួយដែរ?

**ឆ៖** ខ្ញុំសូមធ្វើការជម្រាប ខ្ញុំឱ្យគណបក្សសមរង្ស៊ី។ តែបច្ចុប្បន្ន គណបក្សសមរង្ស៊ី និងសិទ្ធិមនុស្សចូលរួមជាមួយគ្នាមានឈ្មោះថា "គណបក្សសង្គ្រោះជាតិ" សូមជ្រាប។

**ស៖** ចុះប្អូនស្រីរបស់លោកឈ្មោះ សៅ វ៉ន -- ឈ្មោះសៅ វ៉ាន់ នេះ តើគាត់ធ្វើអ្វីដែរ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** ខ្ញុំសូមធ្វើការជម្រាបចំពោះប្អូនស្រីរបស់ខ្ញុំ ឈ្មោះ សៅ វ៉ាន់ បច្ចុប្បន្ននៅឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង អត់មានធ្វើការអីទេ គឺធ្វើចម្ការដើម្បីចិញ្ចឹមជីវិតជាប្រក្រតីបាទ។ សូមអស់យោបល់។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនឹងនិយាយសួរអំពីបងប្អូនប្រុស-ស្រី របស់លោកនៅពេលក្រោយ។ ខ្ញុំសួរលោក -- និងសួរលោកទៅពីឆ្នាំ១៩៧០ ទៅ៧៥ សូមលោកមេត្តារៀបរាប់តួនាទី មុខងាររបស់លោកនៅក្នុងអំឡុងពេលនោះជូនអង្គជំនុំជម្រះបានទេ គឺពី១៩៧០ ទៅ៧៥?

**ឆ៖** ខ្ញុំសូមធ្វើការជម្រាបចំពោះលោកម្ចាស់សំណួរ។ អំពីប្រវត្តិ និងសកម្មភាពរបស់ខ្ញុំពីឆ្នាំ៧០ ទល់គ្នានឹង៧៥ ក្នុងនោះ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ខ្ញុំជាកសិករសាមញ្ញធម្មតា ប៉ុន្តែដល់ថ្ងៃ៣០ ខែ៩ ឆ្នាំ៧១ អង្គការឱ្យខ្ញុំទទួលខុសត្រូវជាប្រធានរណសិរ្សឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ រហូតមកទល់ក្នុងឆ្នាំ៧៥។ ចប់សង្គ្រាម អង្គការក៏សម្រេចឱ្យខ្ញុំមករស់នៅតំបន់២៥។ បាទ សូមចប់អស់យោបល់ បាទ ប៉ុណ្ណឹង។

[០៩:៤៩:00]

**ស៖** តើលោកអាចរៀបរាប់អំពីតួនាទីរបស់លោកនៅពេលដែលលោកធ្វើជាប្រធានរណសិរ្សនោះនៅឃុំជាងទង ជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** ខ្ញុំអាចជម្រាបបាននៅចំណុចណាដែលខ្ញុំអាចចាំបាទ។ ក្នុងនោះ ក្នុងឋានៈខ្ញុំជាប្រធានរណសិរ្សឃុំជាងទង បើនិយាយពីទស្សនៈស្មារតី ពេលនោះលោកទង់រណសិរ្សរួបរួមជាតិកម្ពុជាប្រមូលនូវរាល់ស្មារតីស្នេហាជាតិទាំងអស់ មានកសិករ កម្មករ អនុធន សិស្ស ឥស្សរជនស្នេហាជាតិ និងនាយទុនជាតិរួមកម្លាំងប្រឆាំងនឹងលោក លន់ នល់ ដែលពេលនោះតាមរយៈការយល់ដឹងដែលខ្ញុំចេះចាំដែលអង្គការណែនាំប្រាប់ថា ដើម្បីរួមកម្លាំងវាយចក្រពត្តិដែលចូលមករុករាន ទន្ទ្រានជួយលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ បាទ។ សូមមានការចងចាំតែប៉ុណ្ណោះ បាទ សូមអស់យោបល់។

**សៈ** សូមអរគុណលោកសាក្សី។ តើលោកមានតួនាទី ឬមុខងារដទៃទៀតទេចន្លោះពីឆ្នាំ១៩៧០ ដល់១៩៧៥?

**ឆៈ** សូមឆ្លើយ ខ្ញុំអត់មានតួនាទីអីក្រៅពីប្រធានរណសិរ្សឃុំជាងទងហ្នឹងទេ បាទ សូមជ្រាប។

**សៈ** តើលោកមានបានចូលរួមពាក់ព័ន្ធនៅក្នុងចលនាបដិវត្តន៍នៅក្នុងឃុំពពេល ដែរឬទេ?

**ឆៈ** ចលនា -- សូមឆ្លើយ ឆ្នាំ៧១ ខែ០១ អង្គការបានចាត់តាំងខ្ញុំឲ្យមកធ្វើជាគណៈកៀងគរប្រជាជននៅក្នុងឃុំពពេល ជាមួយនឹងមិត្តខឿន (ប្រុស) ដល់ឆ្នាំមួយពាន់-- ដល់ថ្ងៃ៣០ ខែ៩ ឆ្នាំ៧១ បានអង្គការដកខ្ញុំពីឃុំពពេល ឲ្យទៅទទួលតួនាទីជាមេឃុំ -- រណសិរ្សឃុំជាងទង។

[០៩:៥២:២២]

**សៈ** នៅពេលដែលគេដកលោកចេញពីមេឃុំពពេល តើគេមានឲ្យលោកបំពេញតួនាទីអ្វីទៀតដែរទេ?

**ឆៈ** សូមឆ្លើយ កាលដែលខ្ញុំមកនៅឃុំពពេល គឺគ្មានតួនាទីជាមេឃុំទេ បាទគ្រាន់តែជា គេហៅថាគណៈអប់រំប្រជាជន ក្នុងនោះអ្នកដែលទទួលខុសត្រូវរួម គឺលោក ខឿន – ឈ្មោះ ខឿន ។ បាទ សូមជ្រាប។

**សៈ** លោកសាក្សី ការបកប្រែជាភាសាអង់គ្លេស ខ្ញុំឮសូរពាក្យថាគណៈកម្មាធិការអប់រំកែប្រែនិយាយអំពីភាសាអង់គ្លេសវិញ តើយើងអាចប្រើពាក្យថា គណៈកម្មាធិការកៀងគរ ឬក៏ហៅថាយ៉ាងម៉េច ឬក៏គណៈកម្មាធិការអប់រំ ជាពាក្យអង់គ្លេសថា *ម៉ូប៊ីឡាយហ្សីង ខំមីតធី* នេះ? ប្រហែលជាសំណួរខ្ញុំមិនច្បាស់លាស់ហើយមើលទៅ។ ខ្ញុំសូមបន្តទៅមុខទៀតទៅចុះ។ លោកសាក្សី តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា បង និងប្អូនប្រុសរបស់លោក សៅ ជ្រុន និង សៅ ចំរើន និងប្អូនស្រីរបស់លោក សៅ វ៉ាន់ មានតួនាទីមុខងារអ្វីទេចន្លោះពីឆ្នាំ១៩៧០ ដល់១៩៧៥?

**ឆៈ** សូមឆ្លើយជម្រាប ចំពោះប្អូនស្រីរបស់ខ្ញុំ ឈ្មោះ សៅ វ៉ាន់ គឺពេលនោះបានទៅចូលរួមក្នុងគេហៅថា គណៈអប់រំនារីឃុំពពេល។ ដល់តែចប់សង្គ្រាមឆ្នាំ៧៥ បានអង្គការចាត់តាំងឲ្យទៅនៅស្រែអំបិល នេះតាមរយៈដែលខ្ញុំដឹង។ ឯដោយឡែកចំពោះប្អូនប្រុសខ្ញុំឈ្មោះ សៅ ចំរើន គ្មានតួនាទីអីដែរទេ បាទ ព្រោះជាកសិករនៅក្នុងភូមិស្រែខ្វាវ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងរយៈកាលឆ្នាំ៧០ ទល់ ៧៥ បាទ។

[០៩:៥៥:១០]

**សៈ** ចុះបងប្រុសរបស់លោកវិញ ឈ្មោះ សៅ ជ្រុន នោះមានតួនាទីអ្វីដែរទេចន្លោះពីឆ្នាំ១៩៧០ ដល់ ១៩៧៥?

**ឆៈ** បាទ សូមឆ្លើយ។ សូមធ្វើការជម្រាបចំពោះបងប្រុសរបស់ខ្ញុំឈ្មោះ សៅ ជ្រុន បច្ចុប្បន្ន ប៉ុន្តែពីឆ្នាំ៧០ ទល់ ៧៥ គាត់មានឈ្មោះថា សៅ ស៊ុំ ធ្វើជំទប់លេខ៣ នៅសង្កាត់លេខ៦ ក្រុងភ្នំពេញ នៅភ្នំពេញបាទ។ នៅរួមការងារជាមួយលោក លន់ នល់។

**សៈ** តើគាត់ធ្វើអ្វីដែរនៅក្នុងរដ្ឋបាលលន់ នល់ នៅក្នុងរបបលន់ នល់ តើគាត់មានភារកិច្ចធ្វើជាអ្វីដែរ?

**ឆៈ** សូមជម្រាប កាលក្នុងរបប លន់ នល់ ខ្ញុំជម្រាបហើយថាគាត់មានតួនាទីជាជំទប់លេខ៣ ក្នុងសង្កាត់លេខ៦ ក្រុងភ្នំពេញ។

**សៈ** តើលោកដឹងថា គាត់មានភារកិច្ចធ្វើអ្វីៗ -- ធ្វើអ្វីដែរក្នុងឋានៈគាត់ជាជំទប់លេខ៣ហ្នឹង?

**ឆៈ** ខ្ញុំអត់បានដឹងទេ។

**សៈ** បាទ ខ្ញុំនឹងសួរលោកអំពីបងប្រុសរបស់លោកនៅពេលក្រោយបន្តិចទៀតនេះ ខ្ញុំសូមបន្តសំណួរទៅមុខទៀត។ ទាក់ទងទៅនឹងអំឡុងពេល ពីថ្ងៃ១៧ មេសា ១៩៧៥ គឺថ្ងៃរំដោះ តើលោកមានតួនាទីមុខងារធ្វើអ្វីដែរចាប់ពីថ្ងៃ១៧ មេសា ១៩៧៥ និងបន្តទៅមុខទៀត?

**ឆៈ** សូមឆ្លើយសំណួរដែលលោកបានសួរអម្បាញ់មិញថា ក្រោយថ្ងៃ១៧ មេសា ៧៥ រហូតមកហ្នឹង ចំពោះតួនាទីរបស់ខ្ញុំ គឺខ្ញុំធ្វើលេខាឃុំកំពង់ស្វាយ នៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល។ ពេលនោះ គេហៅថាតំបន់២៥ សូមលោកជ្រាប។

[០៩:៥៨:២៣]

**សៈ** លោករៀបរាប់តួនាទីរបស់លោកក្នុងតំបន់មួយផ្សេង។ ឥឡូវនេះ ប៉ុន្តែតើ -- ឥឡូវសូមឱ្យលោករៀបរាប់ពីតួនាទីរបស់លោកក្នុងឋានៈជាលេខាឃុំកំពង់ស្វាយជូនអង្គជំនុំជម្រះបានឬទេ?

**ឆៈ** ខ្ញុំសូមធ្វើការបញ្ជាក់ និងស្នើបញ្ជាក់ម្តងទៀត តើលោកសួរ -- ចង់សួរថាតួនាទីហ្នឹងយ៉ាងម៉េច? ខ្ញុំមិនទាន់ស្ទួរយល់ពីសំណួរលោកសួរ។

**សៈ** បាទ លោកសាក្សី ខ្ញុំនឹងបញ្ជាក់ជូន។ លោកបានជម្រាបថា លោកគឺជាមេឃុំជាងទង ហើយក្រោយថ្ងៃ១៧ មេសា ១៩៧៥ លោកក៏បានធ្វើជាមេឃុំ ឬក៏លេខាឃុំកំពង់ស្វាយតំបន់២៥។ តើនៅពេលណាដែលលោកបានទទួលតំណែងបន្ទាប់មកនេះ ជាលេខាឃុំកំពង់ស្វាយនៅថ្ងៃខែឆ្នាំណា?

**ឆ៖** សូមឆ្លើយ ខ្ញុំមិនបានចងចាំទេ ក៏ប៉ុន្តែក្រោយពីថ្ងៃ១៧ បានប្រហែល៣ខែ ក៏តំបន់២៥ ចាត់ចូលក្នុងភូមិភាគនិរតី អ៊ីចឹងក៏ខាងអង្គការក៏បានបញ្ជូនខ្ញុំមកនៅស្រុកកៀនស្វាយហ្នឹងតែម្តង។ ដូច្នេះនៅក្នុងឆ្នាំ៧៦នោះដដែលទេ ប៉ុន្តែមិនបានចាំខែ ថ្ងៃ ពិតប្រាកដ បាទ។

**ស៖** ខ្ញុំយល់លោកសាក្សី អត់បញ្ហាទេ។ តើលោកចាំទេនៅពេលដែលលោកនៅជាជាមេឃុំជាងទង? តើឃុំជាងទងហ្នឹងស្ថិតនៅក្នុងស្រុកអ្វី? តំបន់អ្វី? ហើយនិងភូមិភាគអ្វីដែរ?

**ឆ៖** បាទសូមឆ្លើយ។ ឃុំជាងទង ស្ថិននៅក្នុងស្រុកត្រាំកក់ ក៏ប៉ុន្តែពេលនោះស្ថិនៅក្នុងស្រុក១០៥ តំបន់១៣ បាទ។ បច្ចុប្បន្នហៅថា ខេត្តតាកែវ នៅក្នុងភូមិភាគនិរតី។ បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន ការពិតបាទ ប៉ុណ្ណឹង។

[១០:០១:២៧]

**ស៖** មុនពេលដែលលោកផ្ទេរទៅតំបន់ផ្សេង គឺតំបន់២៥ គឺលោកនៅក្នុងតំបន់១០៥។ តើលោកចាំទេ? តើលោកចាំសមាជិកគណៈកម្មាធិការ ១០៥ ដែរឬទេ? តើលោកចាំអ្នកណាខ្លះដែលគេបានចាត់តាំងឲ្យទៅធ្វើការនៅក្នុងស្រុក ១០៥ ដែរឬទេ?

**ឆ៖** បាទ សូមឆ្លើយ។ ក្នុងស្រុក១០៥ ខ្ញុំនៅចងចាំតែលោកយាយ ខុម, លោកតាគាវ, និងលោកតាញ៉ៀវ។ ដោយឡែកក្រោយពីនោះ ឃើញនៅរួមការងារ បាទ ប៉ុន្តែក្នុងឋានៈជាអ្វី ខ្ញុំមិនបានច្បាស់ទេ គឺ ពេជ្រ ជឹម មួយផងដែរ បាទ។ សូមអស់យោបល់។

**ស៖** តើលោកចាំអ្វីខ្លះដែលទាក់ទងនឹងអ្នកដែលលោកទើបរៀបរាប់ដូចជា ខុម, ដូចជា គាវ, ញ៉ៀវ ជាដើមហ្នឹង។ តើលោកចាំអ្វីខ្លះពីពួកគាត់?

**ឆ៖** បាទ ខ្ញុំសូមធ្វើការបញ្ជាក់ជម្រាបជូន។ យាយខុមហ្នឹង កូនតាម៉ុក ទទួលជាប្រធានស្រុកត្រាំកក់ ស្រុក១០៥ បាទ១០៥ ពេលនោះ។ ហើយ តាញ៉ៀវ ហ្នឹងគាត់ៗចូលរួមជាសមាជិក។ តាគាវក៏ជាសមាជិកនៅក្នុងស្រុក ១០៥ ហ្នឹងផងដែរបាទ។ សូមអស់យោបល់។

**ស៖** ចុះ ពេជ្រ ជឹម វិញ លោកចាំអ្វីខ្លះទាក់ទងនឹង ពេជ្រ ជឹម?

**ឆ៖** សូមធ្វើការជម្រាប។ ពេជ្រ ជឹម ពេលនោះ ក្នុងឋានៈគាត់ជាគ្រូបង្រៀន។ ហើយក៏គាត់ស្ថិតក្នុង គេហៅថា អនុធន -- អនុធនកណ្តាលថ្នាក់ក្រោម។ អ៊ីចឹងជាតួនាទី គឺគេអត់ ខ្ញុំជឿថាគេគ្មានប្រគល់តួនាទីអីទេ គឺគាត់សម្របខ្លួនដើម្បីរស់ រួមបម្រើការងារក្នុងចលនាបដិវត្តន៍ វែសត្រូវរួមគឺពេលនៅគេហៅថា លន់ នល់ ចក្រពត្តិអាមេរិកតែប៉ុណ្ណឹង។ សូមអស់យោបល់។

**ស៖** នៅពេលដែលគេសម្ភាសលោកនៅតុលាការហ្នឹង តើគេមានសួរសំណួរទៅលោកទាក់ទងទៅនឹង ពេជ្រ ជឹម ដែរឬទេ?

**ឆ៖** បាទ បានសួរពីរឿងលោក ពេជ្រ ជឹមហ្នឹង។ តែខ្ញុំក៏បានឆ្លើយហើយថា គាត់គ្រាន់តែជាអ្នកដើរប្រមូលនូវសេដ្ឋកិច្ចតាមរយៈឃុំមួយៗ ដែលលោកមេឃុំធ្វើមីទ្ទិង ប្រជាជនបានឧបត្ថម្ភសមរភូមិមុខក្នុងនោះ មានអង្ករ មានបន្លែបង្កា ល្ពុង ចេក ត្រប់ យកមកបម្រើសមរភូមិបាទ។ មានតួនាទីប៉ុណ្ណឹងខ្ញុំប្រាកដសម្រាប់ខ្លួនខ្ញុំ ដែលចាំហើយនិងឃើញសកម្មភាពរបស់គាត់។

**ស៖** លោកសាក្សី ខ្ញុំសូមបន្តទៅកម្រិតខ្ពស់លើស្រុក១០៥ គឺតំបន់១៣។ តើលោកចាំអំពីអ្នកដឹកនាំនៅតំបន់១៣ នៅឆ្នាំ៧៥, ៧៦ ដែរទេ?

**ឆ៖** សូមធ្វើការជម្រាប ពី៧៥ មកទល់ ៧៦ ខ្ញុំមិនបានដឹងលោកណាទទួលតំបន់១៣ ហ្នឹងទេបាទ អត់ទេ ព្រោះខ្ញុំចេញផុតមក។ សូមអស់យោបល់។

[១០:០៦:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីរំឭកដល់ការចងចាំរបស់សាក្សី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកចាំឈ្មោះ សុង ឬក៏ មាស មុត ដែរឬទេ? តើលោកនឹកឃើញឈ្មោះទាំងពីរនេះ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ ខ្ញុំនៅចាំ មាស មុត និង តាសោម។ បាទ ពេលនោះ គេនិយមហៅ តាសោម តាមុត និងតាផែន ដែលអ្នកទទួលខុសត្រូវក្នុងតំបន់១៣ ពេលនោះ បាទ សូមអស់យោបល់។

**ស៖** តើលោកចាំអ្វីខ្លះអំពីតាសោម តាមុត ហើយតាពេញហ្នឹង តើលោកចាំអីអំពីពួកគាត់ទេ?

**ឆ៖** ខ្ញុំសូមធ្វើការជម្រាបនិងឆ្លើយបញ្ជាក់លោកម្ចាស់សំណួរ។ ពេលនោះ ខ្ញុំនៅចងចាំតាមរយៈដែលគាត់អប់រំខ្ញុំ។ តាសោម តាមុត និង តាផែន ក្នុងពេលដែល មួយឆ្នាំហៅទៅអប់រំម្តង។ អ៊ីចឹងគាត់លើកគោលការណ៍ពីជំហរសាមគ្គី ឯកភាពផ្ទៃក្នុងបក្ស។ គឺបានន័យថា សាមគ្គីឯកភាពរវាងបណ្តាថ្នាក់ដឹកនាំគ្នា ហើយបម្រើប្រជាជនដោយស្មោះ បាទ។ សូមអស់ប៉ុណ្ណោះ ហើយក៏បានលើកឡើងបញ្ជាក់ជាខ្លឹមសារថា រាល់សារាចរ មតិណែនាំតូចធំ ដែលដាក់ឱ្យទៅពីខាងលើទៅដល់មូលដ្ឋាន ទោះបីយល់ឬមិនយល់ ត្រូវតែអនុវត្ត ហើយចាំមានមតិស្នើខាងក្រោយ។ ក្នុងនោះ ដែលខ្ញុំនៅចាំថា បុគ្គលគោរព

សមូហភាព ភាគតិចគោរពភាគច្រើន ថ្នាក់ក្រោមគោរពថ្នាក់លើ បុគ្គលគោរពសមូហភាព។ បាទ ខ្ញុំនៅចងចាំប៉ុណ្ណេះរហូតដល់ថ្ងៃនេះ។ បាទ សូមអស់យោបល់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមបន្តទៅភូមិភាគបន្តិច ថាតើលោកចាំទេថា មេដឹកនាំភូមិភាគនីរតីឆ្នាំ៧៥, ៧៦ នោះមានឈ្មោះអីខ្លះដែរ?

[១០:០៩:១០]

**ឆ៖** សូមជម្រាប ខ្ញុំឆ្លើយនូវសំណួរ។ ខ្ញុំមិនបានដឹងច្រើនទេ។ ខ្ញុំបានដឹងថា មានតែ តាម៉ុក នៅក្នុងគណៈភូមិភាគនីរតី ក្នុងភូមិភាគនីរតី តែអ្នកក្រៅពីនោះមិនបានដឹងទេ ហើយតួនាទីរបស់ខ្ញុំគឺ ខ្ញុំបានចងចាំថា ការងារគេ គេដឹង ការងារយើង យើងដឹង។ ហើយជួន -- ដូច្នេះ ខ្ញុំមិនប៊ានខ្សឹបខ្សៀវ ឬសួរអ្នកណាថា អ្នកណាគណៈភូមិភាគ អត់ទេ ស្គាល់តែ តាម៉ុកមួយ គណៈភូមិភាគនីរតី។

**ស៖** តើលោកនឹកឃើញទេ ឈ្មោះ ជូ ជេត?

**ឆ៖** ជូ ជេត ខ្ញុំបាទនឹកឃើញ ខ្ញុំបានដឹង ប៉ុន្តែលោកសំណួរសួរថាពី ៧៥-៧៦ បានខ្ញុំឆ្លើយថា អត់ដឹង។ ប៉ុន្តែបើពី ៧១-៧៥ ខ្ញុំដឹង គាត់នៅក្នុងនិរតីជាមួយ តាម៉ុក ប៉ុន្តែតួនាទីគាត់កម្រិតណាខ្ញុំមិនបានដឹងទេ។ បាទ ពីព្រោះគាត់ -- ខ្ញុំដឹងនេះ ពីព្រោះគាត់សន្និបាតជាមួយព្រះសង្ឃ ហើយក្នុងនោះ ខ្ញុំក៏មានតួនាទីប្រមូល និងអញ្ជើញប្រជាពលរដ្ឋធ្វើចង្ហាន់ទៅប្រគេនលោក នៅពេលនុំងបានខ្ញុំស្គាល់លោកតា ជូ ជេត ហ្នឹង។ បានត្រឹមតែស្គាល់និងឃើញ តែខ្លឹមសារនិយាយសំណេះសំណាលក្រៅពីអី អត់ទេបាទ។ សូមអស់យោបល់។

**ស៖** សូមអរគុណលោកសាក្សី។ មុនពេលដែលខ្ញុំសួរលោកបន្ថែមអំពី តាម៉ុក ហើយនិងតាសោម ហ្នឹង ឥឡូវនេះ ខ្ញុំចង់សួរលោកបន្តិចអំពីបងប្អូនរបស់លោក។ ខ្ញុំចង់ដឹងថា តើបងប្អូនប្រុសរបស់លោកទាំងពីរនាក់ហ្នឹង មានបញ្ហាអីកើតឡើង ឬក៏មានហេតុការណ៍អីដែរនៅថ្ងៃរំដោះភ្នំពេញនោះ?

[១០:១១:៣៨]

**ឆ៖** សូមឆ្លើយ ចំពោះប្អូនប្រុសរបស់ខ្ញុំឈ្មោះ សៅ ចំរើន ហ្នឹង គឺអត់មានបញ្ហាអីទេ ព្រោះពី ៧០ ទល់៧៥ រស់នៅក្នុងភូមិស្រែខ្វាវ ជាកសិករសាមញ្ញ។ តែដោយឡែកបងប្រុសរបស់ខ្ញុំឈ្មោះ សៅ ស៊ុំ ហៅ ជួន បច្ចុប្បន្ននេះ គាត់ចេញពីក្រុងភ្នំពេញទៅ គឺគាត់បានរៀបរាប់ប្រាប់ឪពុកខ្ញុំ និងម្តាយខ្ញុំថា ពេលចេញទៅៗជើង ទៅដល់ខេត្តកំពង់ធំ ហើយកំពង់ត្រង់ណាទេ ហើយបានបីខែក្រោយមកបានគាត់ចេះធ្វើដំណើរមករហូតៗទៅដល់ផ្ទះ ដល់ទៅដល់ផ្ទះគាត់មានតួនាទីអីចឹង ក៏បានទៅរស់នៅរៀនសូត្រ

ក្នុងមន្ទីរ២៤ ក្នុងតំបន់១៣ហ្នឹងបាទ។ មានមន្ទីរអប់រំមួយឈ្មោះថា "មន្ទីរ២៤" បាទ។ ហើយខ្ញុំក៏បានដឹងប៉ុណ្ណឹងចំពោះការរស់នៅរបស់គាត់។

**ស៖** តើលោកដឹងទេថា គាត់ត្រូវបានគេចាប់ខ្លួន ហើយបន្ទាប់មកទៀត ឃុំខ្លួននៅមន្ទីរ២០៤ តើលោកដឹងទេ?

**ឆ៖** ពេលនុ៎ង ខ្ញុំដឹងដែរ បាទ។

**ស៖** លោកដឹងទេថា គេឃុំខ្លួនគាត់នៅមន្ទីរ២០៤ហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** សូមឆ្លើយជម្រាប ពេលនុ៎ង គាត់ទៅ២០៤ គាត់ទៅទាំងគ្រួសារ ទៅរួមរស់ធ្វើ នៅក្នុងក្របខ័ណ្ឌ២០៤ហ្នឹង ហើយខ្ញុំ ៧៦ហ្នឹងក៏ចេញមកតំបន់២៥មក។ ដូច្នេះ ការទំនាក់ទំនងអត់ដែលបានទាក់ទងអីទាំងអស់បាទ។ សូមធ្វើការបញ្ជាក់បាទ ការពិតមានប៉ុណ្ណឹង។

**ស៖** ដោយសារតែមានពេលវេលាតិច ដូច្នេះ ខ្ញុំសូមបន្តទៅសួរអំពី តាម៉ុក បន្តសិន។ តើលោកចាំទេថា លោកធ្លាប់ចូលរួមកិច្ចប្រជុំរបស់កម្មាភិបាល ឬក៏ពួកកងទ័ព ហើយនិងអ្នកមកពីស្រុក ហើយនៅក្នុងការប្រជុំហ្នឹង គឺមានការចូលរួមរបស់ តាម៉ុក ហើយនិងអ្នកដទៃទៀត ថាតើលោកចាំទេ លោកធ្លាប់ចូលរួមការប្រជុំដែលដឹកនាំ តាម៉ុក តើលោកនៅចាំទេ?

[១០:១៤:៤២]

**ឆ៖** បាទ សូមឆ្លើយ ខ្ញុំបានចូលរួម បាទក្នុងតំបន់១៣ហ្នឹង មួយឆ្នាំធ្វើម្តង ហៅថាសន្និបាតបូកសរុប ហើយពេលនោះ តាម៉ុក ក៏បានចូលរួមរយៈពេលមួយម៉ោង។ ឯខ្លឹមសារ តាម៉ុក ដែលបានលើកឡើងប្រាប់រាល់កម្មាភិបាល រាល់កងទ័ពទាំងអស់ និងកម្មាភិបាលមានមុខក្នុងមន្ទីរគ្រប់ជំនាញ។ គាត់ថា៖ "សុំឲ្យសាមគ្គី ហើយបង្កបង្កើនផលដើម្បីបម្រើសមរភូមិមុខ។ ឯចំពោះអាយុជីវិតរបស់មនុស្សឋានៈមេភូមិ មេឃុំ មេស្រុក ចៅហ្វាយខេត្ត គ្មានសិទ្ធិសម្រេច និងវិនិច្ឆ័យចំពោះជីវិតមនុស្សទេ ដាច់ខាតបើអ្នកណាប៉ានប្រព្រឹត្ត អ្នកណាប៉ានអនុវត្ត អ្នកនោះទទួលខុសត្រូវខ្លួនឯង ជីករណ្តៅកប់ខ្លួនឯង"។

ដូច្នេះ ចំពោះសម្តីរបស់គាត់បានលើកឡើងបញ្ជាក់ថា ចំពោះជីវិតមនុស្ស គឺមានតែគណៈភូមិភាគ និងមជ្ឈិមទេដែលមានសិទ្ធិវិនិច្ឆ័យ បាទ។ នេះគាត់លើកឡើងប៉ុណ្ណឹង។ សុំអស់យោបល់។

[១០:១៦:២៨]

សុំបន្តទៀត ហ្នឹងដល់ទៅថ្ងៃ ឆ្នាំ៧៦ ដាច់ឆ្នាំ៧៦ តាម៉ុក ក៏បានលើកឡើង។ ហ្នឹងពេលដែលហៅកម្មាភិបាលទាំងអស់គ្រប់ភូមិភាគនិរតី ទាំងពីខេត្តកំពង់ស្ពឺ ខេត្តកំពត ទៅរៀននៅតាកែវ។ អ៊ូ!

សុំទោស មិនមែនទេ ក្នុងឆ្នាំ៧៣, សម្តីតាម៉ុក បានលើកឡើងបន្ថែមទៀតថា៖ “ពេលនេះ យើងត្រូវទទួលការងារពីនៅពេលតែមួយ”។ ហើយគាត់បានបញ្ជាក់ថា៖ “ថ្ងៃពេលនេះ វៀតណាមនឹងចក្រពត្តិអាមេរិកបានចរចាគ្នាសម្រុះសម្រួលឈប់បាញ់នៅសមរភូមិព្រៃនគរ ដើម្បីទុកឱកាសឲ្យចក្រពត្តិអាមេរិកប្រមូលសម្ភារៈ បេ៥២ មិច ស្ពាបកាត់ កាំភ្លើងតូចធំ មកកម្ទេចនៅកម្ពុជា។ ហើយវៀតណាមក៏គេចាប់បង្ខំឲ្យយើងលុតជង្គង់អង្វរគេដើម្បីពឹងគេឲ្យនៅចូលរួមវ៉ៃចក្រពត្តិ”។ ប៉ុន្តែពេលនោះ តាម៉ុក គាត់លើកឡើងថា៖ “ពេលនេះ ត្រូវដឹងថាចក្រពត្តិ ហើយនិងកុម្មុយនីស្តវ៉ៃយើងហើយ។ សុំយើងទាំងអស់គ្នាប្រឹងប្រែងប្រាប់ប្រជារាស្ត្រកុំឲ្យលក់អង្ករឲ្យវៀតណាម ហើយបើរកទិញអង្ករ ឬទិញមាន់ជ្រូកប្រាប់ថាស្រុកអ្នកឯងសន្តិភាពហើយ ទៅស្រុកអ្នកឯងវិញទៅ”។ បាទ នេះ ទាំងទស្សនៈ ទាំងសកម្មភាព គាត់បានបញ្ជាក់ប្រាប់ថា៖ “យើងប្រឈម ដូចនេះកុម្មុយនីស្ត និងសេរី ព្រួតគ្នាវ៉ៃយើងហើយ យើងឃើញហើយសូវៀត ជាកុម្មុយនីស្តមួយ ប៉ុន្តែគេនៅដាក់ទូតជាមួយ លន់ នល់ ដើម្បីធ្វើបាបយើង”។

បាទ ពេលនោះ គាត់និយាយអ៊ីចឹង នៅក្នុងសន្និបាត។ សុំអស់យោបល់។

[១០:១៩:១៤]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកចាំទេថានៅក្នុងកិច្ចប្រជុំហ្នឹង ឬក៏កិច្ចប្រជុំផ្សេងៗទៀតនៅមុនពេលរំដោះហ្នឹង តាម៉ុក គាត់ធ្លាប់និយាយអំពីកងទ័ព ឬក៏និយាយអំពីទាហានរបស់របប លន់ នល់ ដែរឬទេ? តើតាម៉ុក គាត់ធ្លាប់និយាយឬក៏បញ្ចេញមតិយោបល់ទាក់ទងទៅនឹងយោធា លន់ នល់ ថា តើ -- និយាយឲ្យខ្លីទៅ តើលោកធ្លាប់ឮ តាម៉ុក និយាយអំពីទាហាន លន់ នល់ ដែរឬទេ?

**ឆ៖** សូមឆ្លើយ គាត់ប្រាប់ អត់ដែលនិយាយទេ គាត់ ប៉ុន្តែការ-- គាត់គ្រាន់តែថា ប្រមូលកម្លាំងដើម្បីវ៉ៃរំដោះទីក្រុងភ្នំពេញ។ អ៊ីចឹងទោះបីគាត់និយាយយ៉ាងនេះ ក៏យើងត្រូវដឹងដែរ ពីព្រោះពេលហ្នឹងរវាងអំណាចខាងក្នុង និងខាងក្រៅប្រកួតប្រណាំងគ្នា។ ដូច្នេះចំពោះយោធាលន់ នល់ ក៏គាត់អត់មានបាននិយាយអី គាត់ថានាំគ្នារំដោះប្រទេស រំដោះក្រុងភ្នំពេញ។ បាទ សូមអស់យោបល់។

**ស៖** តើគាត់ធ្លាប់និយាយអំពីអ្វីដែលកើតឡើង ដែលគួរធ្វើចំពោះអ្នករដ្ឋការ ឬក៏យោធាមានបណ្តាស័ក្តិ លន់ នល់ ដែរឬទេ?

**លោក នីកូឡាស គូមជែន៖**

សូមអភ័យទោសឯកឧត្តមប្រធាន ខ្ញុំសូមអភ័យទោស។ ខ្ញុំសូមបញ្ជាក់ថានេះគឺជាសំណួរនាំមុខសាក្សីអាចត្រូវបានសាកសួរថា អំពីអ្វីទាក់ទងទៅនឹង តាម៉ុក ប៉ុន្តែមេធាវីមិនគួរសួរនាំមុខដោយបញ្ជាក់

ថាតើ តាម៉ុក និយាយអំពីអ្វីនោះឡើយ។ ដូច្នេះ ខ្ញុំគិតថាសាក្សីគាត់បាននិយាយថាតាម៉ុក អត់បាននិយាយអីរួចទៅហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោក -- ឯកឧត្តមប្រធាន ខ្ញុំមិនចាំមិនច្បាស់ថាតើការជំទាស់ហ្នឹងអំពីអ្វីទេ ប៉ុន្តែខ្ញុំនឹងសួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះលោកសាក្សី តើលោកចាំទេថាមុនពេលរំដោះនៅខែមេសា ៧៥ហ្នឹង ថាតើ តាម៉ុក គាត់ធ្លាប់និយាយអ្វី ឬក៏ប្រាប់អ្វីថាតើមានគួរអនុវត្តបែបណាចំពោះទាហាន លន់ នល់ ដែលមានបណ្តាស័ក្តិដែរឬទេ?

[១០:២១:៥៦]

**លោក សៅ វ៉ន៖**

**ឆ៖** សូមធ្វើការជម្រាប មុនរំដោះ គឺអត់មានបាននិយាយអីទេបាទ តែបើក្រោយរំដោះបានបីខែមាន តាសោម គាត់អញ្ជើញកម្មាភិបាលក្នុងក្របខណ្ឌតំបន់១៣ហ្នឹង ទៅប្រាប់ថាចំពោះទាហានតាំងពីកូនទាហាន រហូតទល់គ្នានឹងស័ក្តិ៥ ដាច់ខាត អត់មានធ្វើអ្វីឲ្យគេប៉ះពាល់ខាងផ្លូវចិត្ត ផ្លូវអារម្មណ៍ទេ ពីព្រោះគេទាំងឡាយ ទាំងអស់ ទាំងមូល គឺស្ថិតពិត -- គឺស្ថិតក្នុងឋានៈដែលគេមានបងគេ ប្អូនគេ ម្តាយគេនៅជនបទ នៅតំបន់រំដោះ បានរួមចំណែកជាមួយនឹងយើងរំដោះប្រទេសជាតិ។ ដូច្នេះ យើងដាច់ខាតអត់មានធ្វើអ្វីឲ្យប៉ះពាល់ទេបាទ។ នេះសូមអស់យោបល់។

**ស៖** លោកសាក្សី ខ្ញុំនឹងនិយាយអំពីកិច្ចប្រជុំនេះបន្តិច។ តើកិច្ចប្រជុំហ្នឹងធ្វើនៅកន្លែងណា? ហើយនៅពេលណា ពេលដែលតាសោម ហើយនិង តាម៉ុក និយាយអំពីចំណុចទាំងអស់នេះ?

**ឆ៖** សូមធ្វើបញ្ជាក់--

**កញ្ញា សុង ឆវ័ន្ត៖**

សូមជំទាស់លោកប្រធាន សូម--

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរឡើងវិញ។ តើលោកចាំទេថាកិច្ចប្រជុំហ្នឹង ធ្វើឡើងនៅកន្លែងណានៅពេលដែលតាសោម និយាយអំពីចំណុចទាំងនេះ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមឆ្លើយ ពេលហ្នឹងតាម៉ុក អត់មានមុខនៅហ្នឹងទេ។ ចំពោះ តាសោម គាត់និយាយដែលអញ្ជើញកម្មាភិបាលទៅប្រជុំនៅភ្នំត្រែល ស្រុក១០៦ បច្ចុប្បន្នគេហៅថាស្រុកអង្គរជ័យ នៅលើភ្នំត្រែលបាទ សូមជ្រាប។

**ស៖** តើលោកចាំអ្វីផ្សេងទៀតអំពីការប្រជុំហ្នឹង? តើលោកចាំថាអ្នកណាខ្លះចូលរួម ហើយមានមនុស្សចូលរួមប៉ុន្មាននាក់អីប៉ុន្មាននាក់ដែរ លោកចាំទេ?

**ឆ៖** សូមធ្វើការជម្រាប មិនបានចាំទាំងអស់ទេ ប៉ុន្តែគ្រាន់តែចាំដែលពេលនិយាយនោះ ពេលដែលរៀនសូត្រនោះ គឺមានយោធា ពេលមានកម្មាភិបាលឃុំ និងគណៈមន្ទីរបាទ តែត្រង់ឈ្មោះ ខ្ញុំអត់ចាំ ហើយមិនស្គាល់ទេ ពីព្រោះស្រុក ហើយខេត្ត ស្រុកដោយឡែកៗ។ បាទសូមអស់យោបល់ហើយ។

[១០:២៥:00]

**ស៖** តើលោកចាំទេនៅពេលដែលលោកចូលរួមការប្រជុំហ្នឹង តើមាគ៌ាបក្សហ្នឹងគេនិយាយយ៉ាងម៉េចដែរ តើមានការនិយាយអ្វីអំពីមាគ៌ាបក្សទាក់ទងទៅនឹងអ្នករដ្ឋការ ឬក៏យោធាលន់នល់ ដែរឬទេ? តើលោកចាំទេថា មាគ៌ាបក្សសម្រាប់ស្រុករបស់លោកហ្នឹងត្រូវធ្វើយ៉ាងដូចម្តេចចំពោះអ្នករដ្ឋការនិងទាហានលន់នល់ នោះ?

**ឆ៖** ចំពោះមាគ៌ា ដែលការលើកឡើងជាទ្រឹស្តី ហើយនិងការ -- ខ្ញុំបានបញ្ជាក់ហើយអម្បាញ់មិញ ក៏ប៉ុន្តែអ្វីក្រៅពីនោះ ខ្ញុំបើនិយាយអំពីមាគ៌ាដែលបានអប់រំ គឺបុគ្គលគោរពសហមូភាព ភាគតិចគោរពភាគច្រើន ថ្នាក់ក្រោមគោរពថ្នាក់លើ ហើយបើនិយាយពីមាគ៌ាបក្ស ពេលហ្នឹងគឺ បីនាក់មានឈ្មោះថាជាអនុសាខា។ ដល់បីអនុសាខាបានមានមួយសាខា ហើយបាននិយាយថាបើទោះបីមតិណែនាំសារាចរតូចធំ ដែលដាក់ពីលើ -- ទោះបីជាយល់ ឬមិនយល់ ត្រូវតែអនុវត្ត ហើយចាំស្នើឡើង។ បាទគ្រាន់តែបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សី ប៉ុន្តែខ្ញុំសួរលោកជាក់ច្បាស់បន្តិចថា តើលោកចាំអំពីមាគ៌ាបក្សនៅអំឡុងពេលរំដោះ គឺថ្ងៃ១៧ មេសា ៧៥ តើមានមាគ៌ាបក្សនិយាយអំពីជោគវាសនារបស់អ្នករដ្ឋការនិងទាហានលន់នល់ ដែរឬទេ? តើលោកចាំទេថា តើជោគវាសនាទាហាន និងអ្នករដ្ឋការហ្នឹងយ៉ាងម៉េចដែរ ត្រូវគេសម្លាប់ ឬមួយក៏គេដោះលែង គេទុកឲ្យមានសេរីភាព តើលោកចាំទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំអត់ ទោះចាំ ខ្ញុំបានចាំថា ត្រឹមតែកូនទាហាន រហូតទាល់ស័ក្តិ៥ គ្មានសិទ្ធិអី

ទៅធ្វើឲ្យប៉ះពាល់ដូចខ្ញុំបានជម្រាបរួចហើយ។ ដូច្នេះក្រោយពីរំដោះ ខ្ញុំអត់មានដឹងបាតុភូត ឬបាតុភាពអី ចំពោះអ្នករដ្ឋការអស់ហ្នឹងទេបាទ។ សូមអស់យោបល់។

[១០:២៨:១២]

**ស៖** តើលោកចង់មានន័យដូចម្តេចដែរ ដែលថាមិនអាចប៉ះពាល់នោះ?

**ឆ៖** សូមឆ្លើយ ខ្ញុំសប្បាយចិត្តព្រោះថា ខ្មែរនិងខ្មែរបានជោគជ័យហើយ ឈ្នះហើយ ជួបជុំបងប្អូនហើយបាទ។ អ្វីដែលខ្ញុំនិយាយថាខ្ញុំសប្បាយ ត្រង់ពាក្យថា អ្នករដ្ឋការ បើទាហានវិញ តាំងពីកូនទាហាន ទាល់ស័ក្តិ៥នេះ អត់ឲ្យប៉ះពាល់អាយុជីវិត។ ហើយរឿងពិត គឺចំពោះសកម្មភាព ចំពោះខ្ញុំផ្ទាល់ គឺគ្មានជំហរវិះគន់ ឬក៏អីទេ គឺគ្រាន់តែសប្បាយបាទ ដឹងតែសប្បាយ។ សូមអស់យោបល់។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺនៅពេលរំដោះ គឺថ្ងៃ១៧ មេសា ៧៥នោះ មាគ៌ាបក្ស ឬក៏គោលនយោបាយរបស់បក្ស គឺមិនឲ្យប៉ះពាល់ដល់យោធា គឺចាប់ពីថ្នាក់ទាប រហូតទៅដល់ថ្នាក់ស័ក្តិ៥។ គឺបានន័យថា មិនឲ្យសម្លាប់ តើអ៊ីចឹងមែនទេ?

**កញ្ញា សុង ឆវ័ន្តៈ**

ខ្ញុំសូមបញ្ជាក់ថា មាគ៌ាបក្សដែលមេធាវីបានសួរទៅដល់សាក្សីនោះ គាត់បានបញ្ជាក់ថា ជាការដែលគាត់បានចូលរួមនៅក្នុងអង្គប្រជុំមួយនៅក្នុងភ្នំត្រែង ហើយកំពុងតែនិយាយអំពីមាគ៌ាបក្សដែលគាត់យល់នៅក្នុងអង្គប្រជុំនោះ។ ប៉ុន្តែពេលនេះ មេធាវីព្យាយាមសង្ខេបសរុបទៅនឹងមាគ៌ាបក្សនៅក្នុងរបបទាំងមូល។ អ៊ីចឹងសូមឲ្យមេធាវីបញ្ជាក់នៅស្ថានភាពនេះឲ្យបានច្បាស់។

[១០:៣០:០០]

**ប្រធានអង្គជំនុំ៖**

បញ្ជាក់ថា អំមិញហ្នឹងគឺជាសំណួរដឹកមុខហើយលោកមេធាវី សូមអញ្ជើញផ្លាស់ប្តូរសំណួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំមិនច្បាស់ ថាតើខ្ញុំអាចយល់ការវិះគន់ហ្នឹងមានលក្ខណៈយ៉ាងម៉េចនោះទេ។ ដូច្នេះ ខ្ញុំសូមសួរឡើងវិញ គឺលោកនិយាយអំពីការប្រជុំមុនថ្ងៃរំដោះ ហើយនិងក្រោយថ្ងៃរំដោះ។ តើនៅពេលនោះលោកយល់យ៉ាងដូចម្តេចដែរ? ថាតើលោកយល់ថាអតីតអ្នករដ្ឋការ និងទាហានលន់ នល់ ចាប់ពីថ្នាក់ទាបរហូតទៅដល់ថ្នាក់ -- រហូតទៅដល់ស័ក្តិ៥ គឺថាគេមិនឲ្យប៉ះពាល់ ឬក៏មិនឲ្យសម្លាប់។ តើអ៊ីចឹងមែនទេ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមជំទាស់ដូចគ្នា គឺយើងអាចសួរសាក្សីអំពីសំណួរផ្សេង ហើយឥឡូវនេះមេធាវីគាត់ទៅធ្វើ កែសំណួរ ប៉ុន្តែសួរដដែល។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំគិតថា អ្វីដែលលោកសង្ខេប ហើយនិងការជំទាស់គឺវា -- ការសង្ខេបនេះ គឺវាដូចជាការសង្ខេបដដែលៗ។ ដូច្នេះវាៗគ្រាន់តែជាការទាញសន្និដ្ឋានទៅលើសំណួរចម្លើយ។ ដូច្នេះ យើងអាចបន្តទៅមុខទៀតបានដោយមិនចាំបាច់សួរ។ យើងយល់ថា សាក្សីគាត់បានឆ្លើយរួចហើយអំពីមុនពេលរំដោះ ហើយនិងក្រោយពេលរំដោះ។ ហើយយើងក៏យល់ថា គឺវានៅក្នុងអំឡុងឆ្នាំ៧៥ ប៉ុន្តែយ៉ាងណាវានៅអំឡុងឆ្នាំ៧៥ ដដែលទេ។ ប្រសិនបើការយល់ហ្នឹងវាមិនត្រឹមត្រូវ យើងអាចបន្តទៅមុខទៀត ប្រសិនបើមិនដូច្នេះទេ បន្តទៅមុខ។

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណចៅក្រម មីឡាត។ ខ្ញុំសូមបន្តទៅមុខទៀត។

[១០:៣២:០៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបាននិយាយអំពីការប្រជុំ ដែលគេពិភាក្សាអំពីបញ្ហាមួយនេះ។ គឺនៅភ្នំត្រែង។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកចាំមានការប្រជុំដទៃទៀតដែលគេពិភាក្សាអំពីបញ្ហាប្រហែលគ្នា ឬក៏ប្រហាក់ប្រហែលគ្នានៅកន្លែងផ្សេង។ ឧទាហរណ៍ដូចជានៅសាលាស្រុកតាគារ ឬក៏នៅទីរួមខេត្តតាកែវ អីជាដើមទេ លោកចាំទេ?

**លោកស្រី ម៉ារី ហ្គ័រ្វដ៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមើលទៅសំណួរហ្នឹងដូចជាសំណួរនាំមុខហើយ។ ចម្លើយនោះគាត់ផ្តល់ហើយស្រេចហើយនៅក្នុងសំណួរគាត់នោះ។ អ៊ីចឹងសូមឲ្យមេធាវីកែ រៀបរាប់សំណួរឡើងវិញ ឲ្យសំណួរហ្នឹងមានលក្ខណៈអព្យាក្រឹតជាងហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំនឹងកែសម្រួល ប៉ុន្តែខ្ញុំមើលទៅនាឡិកាទៅ ខ្ញុំឃើញថា ខ្ញុំមានពេលពីត្រឹមតែ ៥នាទី ហេតុដូច្នេះ ខ្ញុំសូមសួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកចាំទេថា មានការប្រជុំដែលនិយាយអំពីបញ្ហាប្រហាក់ប្រហែលគ្នានេះ។ ឧទាហរណ៍ដូចជាកិច្ចប្រជុំនៅភ្នំត្រែងជាដើមនោះ លោកចាំទេថាមានការប្រជុំបែបនេះ?

[១០:៣៣:៣៤]

**លោក សៅ វ៉ាន៖**

**ឆ៖** ខ្ញុំអត់បានយល់ពីសំណួរបាទ មិនដឹងចង់ឲ្យខ្ញុំបញ្ជាក់ត្រង់ចំណុចណាទៀត បើខ្ញុំប្រាប់ -- ខ្ញុំជម្រាបហើយនោះ។ សូមអស់យោបល់។

**ស៖** លោកបាននិយាយអំពីការប្រជុំ ដែលនិយាយអំពីជោគវាសនារបស់ទាហាន និងអ្នករដ្ឋការលន់ នល់។ ដូច្នេះ ខ្ញុំចង់ដឹងថាមានការប្រជុំដទៃទៀតនៅកន្លែងផ្សេងៗទៀតដែលគេពិភាក្សាអំពីបញ្ហាដូចគ្នាហ្នឹង អាចថាជាការប្រជុំនៅក្នុងស្រុករបស់លោក ឬក៏នៅក្នុងភូមិភាគរបស់លោកដែលគេនិយាយអំពីបញ្ហាដូចគ្នា ឬក៏ប្រហាក់ប្រហែលគ្នាហ្នឹង ថាលោកចាំទេ?

**ឆ៖** សូមធ្វើការបញ្ជាក់ ក្រោយពី -- រាល់កម្មាភិបាល ខ្ញុំចង់និយាយថាពីត្រឹមថ្នាក់ឃុំអី ស្រុក បើកាលណាបានមតិណែនាំហ្នឹងមកហើយ គឺមកដល់មូលដ្ឋានឃុំ គឺអញ្ជើញមេឃុំក្រោមថ្នាក់របស់ខ្លួនមកអប់រំ ប្រាប់ត្រង់អំពីសកម្មភាពទាំងអស់ហ្នឹង ពីសីលធម៌ ដើម្បីអប់រំ។ ក្នុងនោះគឺមានអប់ -- ពេលនោះអញ្ជើញមេភូមិគ្រប់ភូមិមកអប់រំ ប្រាប់ថាកុំប៉ះពាល់គេ ហើយនិយាយភាសា ធ្វើយ៉ាងណាកុំឲ្យគេភ័យ គេភិតបាទ។ ត្រូវតែ ហើយបង្កើតស្មារតី រកស្បៀងដោះស្រាយជីវភាព ទាំងទីជម្រក ឲ្យអ្នកទាំងអស់នោះ។ បាទ នេះជាសកម្មភាពដែលបានធ្វើពេលនោះបាទ។ សូមអស់យោបល់។ ហើយគេនិយាយគឺគ្រប់ឃុំហើយ មេឃុំគេយក -- គ្រប់ឃុំគេយកមកផ្សព្វផ្សាយតាមហ្នឹង។ នេះសូមជម្រាបទៅលោកម្ចាស់សំណួរ។

[១០:៣៥:៣៨]

**ស៖** ប្រហែលខ្ញុំសួរមិនច្បាស់។ ខ្ញុំចង់សួរថា លោកចាំអំពីការប្រជុំដទៃទៀត គឺនៅកន្លែងផ្សេងទៀតក្នុងឆ្នាំ៧៥ ដែលនៅក្នុងការប្រជុំហ្នឹងគេពិភាក្សាអំពីបញ្ហាទាហានរហូតទៅដល់ស័ក្តិ៥ហ្នឹង គឺថាមិនឲ្យប៉ះពាល់ ឬក៏មិនឲ្យសម្លាប់។ ដូច្នេះ តើលោកចាំថាមានការប្រជុំនៅកន្លែងផ្សេងៗទៀតក្រៅពីការប្រជុំមួយដែលលោកនិយាយមុនហ្នឹង? តើមានការប្រជុំផ្សេងៗទៀត និយាយអំពីបញ្ហាហ្នឹងទេ?

**ឆ៖** បានអត់ទេ បាទ។

**ស៖** ឯឧត្តមប្រធាន ខ្ញុំគិតថាឥឡូវនេះ ខ្ញុំបានសួរសាក្សីអំពីការប្រជុំដែលសាក្សីរូបមួយទៀតបាននិយាយ គឺ ពេជ្រ ជឹម។ គាត់បាននិយាយអំពីការប្រជុំនៅទីរួមខេត្តតាកែវ។ ដូច្នេះខ្ញុំហ្នឹងសួរដេញដោលសាក្សីនេះទៅលើកិច្ចប្រជុំដែល ពេជ្រ ជឹម បានលើកឡើង។ លោកសាក្សី តើលោកចាំថា មានការប្រជុំនៅទីរួមខេត្តតាកែវ គឺនៅក្នុងអគារមួយនៅខាងក្រោយអគារបក្ស -- មន្ទីរបក្ស ដែលនៅក្នុងការប្រជុំនៅអគារក្រោយមន្ទីរហ្នឹង គឺគេលើកយកបញ្ហាដដែលហ្នឹងមកពិភាក្សា? តើលោកចាំទេ?

**ឆ៖** សូមជម្រាប ខ្ញុំបានចេញពីស្រុកត្រាំកក់ ចេញពីតំបន់១៣ មកនៅតំបន់២៥ ហើយ ហើយទៅចូលរួមរៀនសូត្រនៅទីក្រុងតាកែវ ក្នុងផ្សារ -- ត្រង់ពេលហ្នឹងនៅផ្សារ ផ្សារចាស់ ប៉ុន្តែអត់មានប្រជាជនទេ គឺកម្មាភិបាលទាំងអស់ទៅរៀននៅហ្នឹង។ បាទ ដូច្នេះ ខ្ញុំដូចជាមិន -- អត់មានបានដឹងប្រជុំយ៉ាងម៉េច -- ប្រជុំពេលហ្នឹងរៀនសូត្រធ្វើជីវទស្សន៍។ គ្រាន់តែពង្រឹងជំហរ បង្កបង្កើនផលតែប៉ុណ្ណឹងបាទ។ សូមអស់យោបល់ប៉ុណ្ណឹង។

[១០:៣៧:៥៤]

**ស៖** ខ្ញុំសូមរំឭកអំពីចម្លើយរបស់លោកកន្លងមក គឺលោកសាក្សី។ ឯឧត្តមប្រធាន ខ្ញុំយោងទៅលើឯកសារមួយ គឺឯកសារ E -- គឺឯកសារ E127/7.1--, 00090906, ខ្មែរមានលេខ 00893277, និងបារាំងមានលេខ 00978649។ ខ្ញុំសូមសួរសំណួរទី៩។ លោកសាក្សីខ្ញុំសូមអានឲ្យលោកស្ដាប់ ហើយខ្ញុំគិតថាប្រហែលជាលោកអាចចាំ។ លោកបាននិយាយតទៅនេះ។ សំណួរសួរថា "តើ តាម៉ុក ធ្វើការប្រកាសនេះនៅពេលណា?"

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសូមផ្អាកមួយនាទី ដើម្បីទុកពេលឲ្យប្ដូរ ឌី.វី.ឌី ហើយសឹមបន្តទៅទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឯកឧត្តមប្រធាន កូនក្ដីរបស់ខ្ញុំសូមអនុញ្ញាតទៅសម្រាកនៅបន្ទប់ឃុំខ្លួននៅជាន់ខាងក្រោមសាលសវនាការ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

លោក អរុណ អំមិញគឺខ្ញុំឃើញមានលិខិតបញ្ជាក់អំពីសុខភាពរបស់ខាងពេទ្យ។ អ៊ីចឹងមានទេ?

អ៊ីចឹង ទាក់ទងនឹងបញ្ហាសំណើរបស់ជនជាប់ចោទលោក នួន ជា ដែលគាត់សុំទៅនៅខាងក្រោមបន្ទប់ឃុំខ្លួនខាងក្រោមដើម្បីតាមដានកិច្ចដំណើរសវនាការ ដោយយោងទៅតាមកំណត់ហេតុពិនិត្យ

សុខភាព ដែលបញ្ជាក់ដោយវេជ្ជបណ្ឌិត ឈាង គុន្ធាវី គឺបានបញ្ជាក់ថា គាត់ហ្នឹង វាមានអាការៈលំបាកក្នុងការអង្គុយ ដោយឈឺចង្កេះ។ អ៊ីចឹងហើយ គឺតុលាការ -- អង្គជំនុំជម្រះហ្នឹងគឺអនុញ្ញាតឱ្យគាត់តាមដានសវនាការហ្នឹងនៅបន្ទប់ឃុំខ្លួនខាងក្រោម។ អ៊ីចឹង គឺសូមលោកមន្ត្រីពន្ធនាគារសូមនាំជនជាប់ចោទចុះទៅក្រោមចុះ ហើយសូមឱ្យលោកខាងសោតទស្សន៍ គឺភ្ជាប់ឧបករណ៍សោតទស្សន៍ដើម្បីគាត់ចូលរួមបាន។

បាទ អ៊ីចឹង សូមអញ្ជើញលោកមេធាវីបន្តសំណួរ ហើយពេលវេលារបស់លោកហ្នឹង គឺត្រូវបានបញ្ចប់ហើយ ប៉ុន្តែគឺអាចបន្ថែមបន្តិច ដោយសារមានបញ្ហាខាងផ្នែក ឌីវីឌី អំមិញនេះ។ សូមអញ្ជើញបន្ថែមបន្តិចបាទ!

[១០:៤២:២៩]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំសូមអាននូវចម្លើយរបស់សាក្សី "សំណួរ៖ តើតាម៉ុក ធ្វើការប្រកាសនេះនៅពេលណា? ហើយលោកឆ្លើយថា៖ តាម៉ុក បានធ្វើការប្រកាសនេះ នៅមុនឆ្នាំ១៩៧៥ នៅពេលមានកិច្ចប្រជុំបូកសរុបដែលបានធ្វើឡើងនៅក្នុងពេលមួយឆ្នាំម្តង ដែលមានការចូលរួមពីគណៈឃុំ ស្រុក ខេត្ត និងកងវរៈ។ ក្រោយឆ្នាំ១៩៧៥ មានការប្រជុំម្តងទៀត នៅទីរួមខេត្តតាកែវ ដែលមានតាម៉ុក ចូលរួម ហើយឈ្មោះសោម ដែលជាគណៈតំបន់១៣ បានធ្វើការប្រកាសថា ហាមប៉ះពាល់ទាហានរបប លន់ នល់ ពីស័ក្តិ១ ដល់ស័ក្តិ៥ មិនត្រូវប៉ះពាល់"។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកចាំទេថាលោកបានឆ្លើយនៅចម្លើយនេះ? ហើយប្រសិនបើលោកឆ្លើយថា លោកបានឆ្លើយមែន តើវាធ្វើឱ្យលោកនឹកឃើញដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ ខ្ញុំនឹកឃើញ។ បាទ ហើយកាលហ្នឹងនៅតាកែវមែន រៀននៅតាកែវ។ ប៉ុន្តែអម្បាញ់មិញនេះ ខ្ញុំស្តាប់សំណួររបស់លោក លោកថា តាជឹម បានជាខ្ញុំថាអត់នេះ អត់ដឹង។ បើតាសោមហើយតាម៉ុក គឺពិតជានៅតាកែវមែន។ ខ្ញុំបានទៅចូលរួមមែន។ បាទ សូមអស់យោបល់។

[១០:៤៣:៥៩]

**ស៖** ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរថា តើលោកចាំថា លោកបានចូលរួមការប្រជុំចំនួនពីរដែរឬទេ

ដែលទី១ នៅភ្នំត្រែង ហើយទី២ នៅទីរួមខេត្តតាកែវ ដែលនៅក្នុងការប្រជុំទាំងពីរនោះ គេបាននិយាយអំពីជោគវាសនារបស់ទាហាន លន់ នល់។ តើវាជាការត្រឹមត្រូវដែរឬទេ ដែលថានៅក្នុងការប្រជុំចំនួនពីរ គឺគេណែនាំដល់អ្នកចូលរួមមិនឲ្យប៉ះពាល់ដល់ទាហានចាប់ពីស័ក្តិ១ ដល់ស័ក្តិ៥? តើលោកចាំថានេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមឆ្លើយ បាទ ត្រឹមត្រូវបាទ ទាំងពីរហ្នឹង គឺត្រឹមត្រូវហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំគិតថា ខ្ញុំអស់ម៉ោងហើយ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបញ្ចប់។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងតាមកម្មវិធីរបស់យើងនេះ គឺយើងដល់ម៉ោងដប់សែសិបប្រាំពីរហើយ។ ដូច្នេះយើងសូមសម្រាក។ តុលាការប្រកាសសម្រាក ហើយរហូតទៅដល់ម៉ោងដប់មួយ គឺយើងនឹងចូលមកបន្តសវនាការវិញ។

បាទ សូមអញ្ជើញ!

*(សវនាការសម្រាកពីម៉ោង ១០:៤៥ នាទី ដល់ម៉ោង ១១:០៣ នាទី)*

[១១:០៣:០០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញអង្គុយ!

តុលាការប្រកាសបន្តសវនាការ។ អំមិញនេះ ដោយមានការពិភាក្សារបស់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលពេលសម្រាកនេះ គឺឃើញថា ខាងមេធាវីការពារក្តីជនជាប់ចោទហ្នឹង គឺបានមានសំណួរច្រើនទាក់ទងទៅនឹងបញ្ហាសួរទៅលើសាក្សី។ ហើយសំណួរអំមិញហ្នឹងគឺ អង្គជំនុំជម្រះយល់ថាមិនទាន់បានធ្វើនៅចប់នៅឡើយទេ។ អ៊ីចឹង សួរថាតើខាងមេធាវីហ្នឹងមាន អាចត្រូវការពេលវេលាប្រហែលជា ១០នាទីអីទៀតបានទេ? ត្រឹម១០ នាទីទៀត អាចធ្វើបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ អរគុណជាច្រើនដែលបានផ្តល់ពេលវេលាបន្ថែម ១០នាទី ឲ្យសួរសាក្សីបន្ថែមទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាកមុននេះ យើងនិយាយអំពីកិច្ចប្រជុំនានា។ ឥឡូវនេះ រយៈពេល ១០នាទីរបស់ខ្ញុំនេះ គឺខ្ញុំឱ្យលោកផ្តោតទៅលើកិច្ចប្រជុំដទៃទៀត នៅទីរួមខេត្តតាកែវ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះឱ្យបានលម្អិតបន្តិច អំពីពេលដែលគេរៀបចំសម្រាប់ការប្រជុំនេះ ឬក៏ទីកន្លែងណាមួយនៅក្នុងទីរួមខេត្តតាកែវ ដែលគេបានរៀបចំកិច្ចប្រជុំទាំងនេះដែរឬទេ?

**ឆ៖** សូមឆ្លើយជម្រាបលោកម្ចាស់សំណួរ ពេលដែលប្រជុំនៅខេត្តតាកែវហ្នឹង សូមជម្រាបថា ប្រជុំនៅកន្លែងផ្សារចាស់បច្ចុប្បន្ននៅទេបាទ។ ផ្សារដល់ -- ពេលហ្នឹងគឺគ្រប់កម្មាភិបាល និងកងទ័ព នៅក្នុងភូមិភាគនីរតីហ្នឹងទៅប្រជុំនៅកន្លែងហ្នឹង។ ហើយខ្លឹមសារប្រជុំពេលនោះ ខ្ញុំសូមធ្វើការឆ្លើយតបតែម្តងបាទ។ ទី១ ឯកសារជំហរសាមគ្គីឯកភាពផ្ទៃក្នុង។ ២) ខ្លឹមសារពង្រឹងពង្រីកសហករណ៍ ដើម្បីបង្កបង្កើតផល ឧបត្ថម្ភខ្លួនទីពឹងខ្លួន។ ហើយចំណុចទី៣ តាម៉ុក គាត់បានលើកឡើងថា និយាយថា យើងអាចនៅមានកើតជម្លោះ ឈ្លោះជជែក ពីនគរអាណាំកុក គឺយួន។ អ៊ីចឹងសុំវាល់កម្មាភិបាលទាំងអស់ពង្រឹងសមត្ថភាពដឹកនាំសហករណ៍ឱ្យបង្កបង្កើនផលឱ្យបាន ១ហិកតា ៣តោន បើយើងបានប្រជាជនយើងហូបឆ្អែត គ្រប់គ្រាន់នោះ គេលេបមិនរួចទេ។ បាទ នេះចំណុចដែលខ្ញុំចងចាំ។ ហើយក៏ខ្លឹមសារគឺមានតែបីហ្នឹង។ ហើយក៏ផ្នែកយោធា ក៏អត់មានអីទេ គាត់និយាយបីចំណុចហ្នឹង ខ្លឹមសារហ្នឹង តាម៉ុកលើកឡើង។ ហើយក៏នេះទៅ រយៈបីថ្ងៃហ្នឹង គឺរំសាយទៅ។ ហើយខ្លឹមសារគាត់ បង្រៀនហ្នឹងមួយថ្ងៃមួយថ្ងៃធ្វើជីវទស្សន៍។ បាទសូមអស់យោបល់ បាទ។

[១០:០៧:០៥]

**ស៖** តើលោកនៅចាំថា មានវត្តមានអ្នកណាខ្លះ នៅក្នុងកិច្ចប្រជុំនៅទីរួមខេត្តតាកែវ? តើលោកចាំអ្នកដែល ចាំមនុស្សជាក់លាក់ណាខ្លះដែលទេ ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនៅក្នុងទីរួមខេត្តតាកែវនេះ?

**ឆ៖** សូមឆ្លើយ ខ្ញុំនៅចាំ គឺមានតាសោម គណៈតំបន់ គាត់លើកបទឧទ្ទេសនាម ហើយនិងតាប៊ិត ផ្នែកកងទ័ព ក៏ចូលរួមដែរ។ ហើយក្រៅពីហ្នឹងមានតែគណៈស្រុក ហើយពេលហ្នឹងខ្ញុំនៅតំបន់២៥ទេ ដូច្នេះទៅ គឺនៅក្របខ័ណ្ឌតំបន់២៥ អត់មានពីណាទៅទេ មានតែកម្មាភិបាលឃុំ។ បាទ ហើយចំពោះនៅក្នុងខេត្តហ្នឹង គឺខ្ញុំមិនបានចាំឈ្មោះទេ ចាំតែត្រឹម បងសោម ហើយនិង តាប៊ិត។ សូមអស់យោបល់។

**ស៖** និយាយអំពីអ្វីដែលគេបាននិយាយនៅក្នុងកិច្ចប្រជុំនេះ ក៏ដូចជាកិច្ចប្រជុំដទៃទៀត ទាក់ទងទៅនឹងអ្វីគួរតែកើតឡើងចំពោះអតីតមន្ត្រីរបបលន់នល់ តើលោកនៅចាំថាមានការណែនាំណាមួយពាក់ព័ន្ធទៅនឹងបញ្ហានៃមន្ត្រីរបបលន់ នល់ នេះដែរឬទេ? សូមលោកបញ្ជាក់ដើម្បីឱ្យអ្នកដទៃទៀត យល់ឱ្យបានច្បាស់។ តើគោលនយោបាយពាក់ព័ន្ធទៅនឹងមន្ត្រីរដ្ឋការរបប លន់ នល់ វាយ៉ាងណាដែរ?

**លោក នីកូឡាស គូមជែន៖**

មេធាវីការពារក្តីកំពុងតែសួរនាំមុខសាក្សីរូបនេះហើយ។ ទី២ គាត់សុំឱ្យសាក្សីឆ្លើយស្ទាន១ទៅលើចំណុចទាំងនេះ។

[១១:០៩:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ទាក់ទងទៅនឹង ការជំទាស់ចុងក្រោយនេះ លោកប្រធាន ខ្ញុំគ្រាន់តែសួរសាក្សីថាតើ គាត់មានចាំថាធ្លាប់បាននិយាយទៅអ្នកចូលរួមនៅក្នុងកិច្ចប្រជុំដើម្បីចង់ដឹងថាតើគាត់យល់អំពីគោលនយោបាយនេះដែរឬក៏អត់ទេ? ដូច្នេះ ខ្ញុំយល់ឃើញថា អង្គជំនុំជម្រះគួរអនុញ្ញាតឱ្យខ្ញុំសួរសំណួរនេះ។ បាទ ខ្ញុំនឹងរៀបចំសំណួរខ្ញុំឡើងវិញ ដើម្បីកុំឱ្យសាក្សីឆ្លើយស្ទាន១។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកនៅចាំថា លោកបាននិយាយជាមួយអ្នកចូលរួមក្នុងកិច្ចប្រជុំទាំងនេះអំពីសេចក្តីណែនាំទាក់ទងទៅនឹងអតីតទាហានរបប លន់ នល់ ដែរឬទេ? តើលោកយល់ច្បាស់អំពីសេចក្តីណែនាំនេះដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សុំឆ្លើយនូវសំណួររបស់លោក។ ខ្ញុំបាទនៅចាំ ហើយខ្ញុំសប្បាយចិត្តដោយមានមតិណែនាំថា ចាប់តាំងពីកូនទាហានមកទល់ស័ក្តិ៥ កុំធ្វើបាបគេ ហ្នឹងទី១។ ឯមួយទៀត លោកបញ្ជាក់ខ្ញុំថាតើលោកចាំអីខ្លះ? អឺចឹង ខ្ញុំសុំធ្វើការជម្រាបជូន ក្នុងរយៈកាលក្នុងសង្គ្រាម ខ្ញុំបានទទួលខ្លឹមសារមុនរំដោះទូទាំងប្រទេស។ ពេលនោះ លោក ខៀវ សំផន គាត់បានប្រកាសតាមវិទ្យុថា នាយទាហាន ពលទាហាន អ្នករដ្ឋការស៊ីវិល អនុធន សិស្ស អ្នកស្នេហាជាតិទាំងអស់ ឱ្យតែចូលក្នុងរណសិរ្សរួបរួមជាតិកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជាលើកលែងទោស ហើយរណសិរ្សរួបរួមជាតិកម្ពុជាវិនិច្ឆ័យ និងកាត់ទោសប្រហារជីវិតតែមនុស្សប្រាំពីររូបទេ តាមដែលខ្ញុំចាំដល់ថ្ងៃនេះ ទី១ លន់ នល់, សិរិមតៈ, សឺង

ង៉ុកថាញ់, អ៊ិន តាំ, សុស្តែន, ឡុង បូរ៉េត និង ចេង ហេង។ សុំជម្រាបលោកម្ចាស់សំណួរដែលបញ្ជាក់ថា ឲ្យខ្ញុំចាំគឺចាំអ៊ីចឹង សូមជ្រាប សូមអស់យោបល់។

**ស៖** តើលោកចាំថា តើនៅពេលដែលលោកឮសួរសេចក្តី មានការណែនាំនេះ ដោយសារថា អ៊ីចេះ! លោកមានបងប្អូនប្រុសធ្វើការនៅក្នុងរបបសាធារណរដ្ឋខ្មែរ។ អ៊ីចឹង តើគេយល់យ៉ាងម៉េចដែរ?

[១១:១២:០៦]

**លោក នីកូឡាស គូមជែន៖**

សុំជំទាស់ ការដែលមេធាវីការពារក្តីណែនាំឲ្យសាក្សីឆ្លើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របវាជាសំណួរនាំមុខបន្តិចដែរ លោកប្រធាន ប៉ុន្តែខ្ញុំសួរសាក្សី ដោយសារនេះវាពាក់ព័ន្ធទៅនឹងអារម្មណ៍ជាក់លាក់ណាមួយដែលសួរទៅលើសាក្សីរូបនេះ ដោយសារវាមានការពាក់ព័ន្ធទៅនឹងបងប្រុសរបស់គាត់។ ប៉ុន្តែ ខ្ញុំអាចរៀបចំសំណួរឲ្យមានលក្ខណៈអព្យាក្រឹតបន្តិចក៏បានដែរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកដឹងទេថាលោកក៏ត្រូវបានគេតាមដានដោយសារតែលោកមានមូល-ហេតុផ្ទាល់ខ្លួន? លោកដឹងទេ?

**លោក សៅ វ៉ន៖**

**ឆ៖** សូមឆ្លើយ នៅចំពោះមុខ ក្នុងសង្គមគ្រួសាររបស់ខ្ញុំ ខ្ញុំទទួលស្គាល់មិនបដិសេធទេគឺមានបងមួយ សៅ ស៊ុំ ហៅ ជ្រុន បាទ។ គាត់នៅបម្រើការក្នុងរដ្ឋការលន់ នល់ ឋានៈជាតួនាទីជំទប់លេខ៣ ប៉ុន្តែអ្វីដែលគាត់ត្រឡប់ទៅវិញ ហើយគេបានអញ្ជើញគាត់ទៅអប់រំក្នុងមន្ទីរ២០៤ នេះជារឿងមួយធម្មតា ខ្ញុំឈរលើកត្តាអត្តនោម័តិ បាទ។ អត្តនោម័តិបានន័យថា បើដើរកាត់ភ្លាមវាតែងតែទទឹក ដូច្នេះគេទាំងឡាយក៏អ៊ីចឹងដែរ។ អ៊ីចឹង ខ្ញុំអត់មានការអីថ្នាំងថ្នាក់ទេបាទ ព្រោះពេលហ្នឹងអារម្មណ៍របស់ខ្ញុំ ខ្ញុំគ្រាន់តែប្រាប់បងខ្ញុំថា ខំសម្របសម្រួលធ្វើការខ្លួនដោយផ្អែកលើលទ្ធិប្រជាធិបតេយ្យ ភាគច្រើនកសិករ ៩៥ភាគរយ គេធ្វើស្រែ។ ដូចនេះពេលនេះ គឺខ្លឹមសារក្រោយពីរំដោះហើយ ត្រូវអនុវត្តពីសហករណ៍គឺយកមុខការកសិករជាមូលដ្ឋាន។ អ៊ីចឹង ខ្ញុំបានប្រាប់បងខ្ញុំអ៊ីចឹង ហើយខ្ញុំជ្រះស្រឡះ និងពេញចិត្ត ដែលមតិណែនាំចង្អុលបង្ហាញឲ្យខ្ញុំអប់រំបងខ្ញុំអ៊ីចឹងបាទ សុំអស់យោបល់។

[១១:១៤:៤៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។

លោកប្រធានសូមអរគុណចំពោះការបន្ថែមពេលវេលា។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តគឺសូមអញ្ជើញលោកសហមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន តាំងសំណួរដល់សាក្សី។

[១១:១៥:០៧]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទជម្រាបសួរអស់លោក លោកស្រីចៅក្រម និងភាគីទាំងអស់ ហើយនិងសាធារណជន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អាកទួរ វែកគែន ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ខ្ញុំមានរយៈពេលកន្លះម៉ោងដើម្បីចោទសំណួរទៅលោក។ បាទ ជាបឋម ខ្ញុំសូមសួរលោកថា តើនៅពេលណាដែលតំបន់របស់លោកត្រូវបានរំដោះដោយកងទ័ពបដិវត្ត?

**លោក សៅ វ៉ន៖**

**ឆ៖** សូមឆ្លើយ នៅតំបន់រំដោះបាននៅថ្ងៃ -- នៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ បាទ តំបន់១៣។

**ស៖** នៅពេលដែលលោកជាមេឃុំជាងទងនៅក្នុងឆ្នាំ១៩៧១ តើលោកនៅក្នុងតំបន់រំដោះ ឬក៏នៅក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លន់ នល់?

**ឆ៖** សូមធ្វើការជម្រាបគឺឆ្នាំ១៩៧១ គឺឃុំជាងទងស្ថិតនៅក្នុងតំបន់រំដោះបាទ។

**ស៖** អ៊ីចឹងកន្លែងដែលលោកនៅហ្នឹង ឃុំជាងទងហ្នឹង ត្រូវបានរំដោះនៅពេលណាដែរអ៊ីចឹង?

**ឆ៖** សូមធ្វើការជម្រាប។ ក្រោយពីធ្វើរដ្ឋប្រហារហើយ ក្នុងឃុំជាងទង ពេលនោះគឺស្ថិតក្នុង -- មាន២៦ភូមិ ហើយក៏បានរំដោះបានជាទូទៅ ការចាត់តាមភូមិ គឺបានគ្រប់ភូមិ អ៊ីចឹងនៅក្នុង៧០ -- ពេលនោះ ៧៥ -- នែក្រោយ១៨មេសា -- ក្រោយ១៨មីនាមក ទល់គ្នានឹង៧៥ គឺស្ថិតនៅក្នុងតំបន់រំដោះបាទ សូមជ្រាប។

[១១:១៨:០៩]

**ស៖** ការបកប្រែ -- ក្នុងការបកប្រែជាភាសាបារាំងនោះ បកប្រែថាថ្ងៃទី០៨ មីនា ឆ្នាំ១៩៧៥។ អ៊ីចឹងលោកចង់និយាយអំពីរដ្ឋប្រហារថ្ងៃទី១៨មីនា ឆ្នាំ១៩៧០ ឬក៏៧៥?

**ឆ៖** បាទ សូមធ្វើការជម្រាបបាទ ថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ បាទ សូមលោកម្ចាស់សំណួរជ្រាបបាទ។

**ស៖** បាទ ខ្ញុំសូមទោសពីព្រោះខ្ញុំស្តាប់ជាភាសាបារាំងអ៊ីចឹង ខ្ញុំស្តាប់តាមរយៈការបកប្រែនោះទេ អ៊ីចឹងខ្ញុំមិនបានស្តាប់ឮអ្វីដែលលោកនិយាយជាភាសាខ្មែរនោះទេ។ បាទមិនបញ្ហាអ្វីទេ ខ្ញុំចោទសំណួរបន្តទៀត។ ខ្ញុំចង់សួរលោកថា បើតាមរូបលោកផ្ទាល់នោះ តើលោកបានឆ្លងកាត់ការទម្លាក់គ្រាប់បែកអាមេរិកាំងដែរឬទេនៅកន្លែងដែលលោកនៅនោះ កាលសម័យនោះ?

**ឆ៖** បាទ សូមឆ្លើយគឺបានទទួលរងទម្ងន់មួយគ្រាប់បែកដែលសហរដ្ឋអាមេរិកបានទម្លាក់ ប៉ុន្តែស្លាកស្នាមទាំងអស់នោះដែលបានធ្លាក់ទៅជាៗថ្លុក ទៅជាអូរ ទៅជាត្រពាំងនោះ គឺវារលុបអស់ហើយឥឡូវនេះបាទ។ តែជម្រាបថាពេលហ្នឹង គឺពេញអំណាចទទួល តាំងពីប្រជាជនក្នុងឃុំជាងទងទាំងមូលហ្នឹង ខ្លះឆេះផ្ទះ ខ្លះដួលផ្ទះ ខ្លះស្លាប់ អាខ្លះងាប់គោ ងាប់ក្របី បាទ សូមជ្រាប។

**ស៖** តើបើតាមការសង្កេតរបស់លោកនេះ យើងអាចនិយាយបានដែរឬទេ ថាតើទម្លាក់គ្រាប់បែកនោះ គឺជំរុញឱ្យមានការចូលរួមក្នុងចលនាបដិវត្តន៍កាន់តែខ្លាំងជាងមុន?

**ឆ៖** សំណួរលោកសួរហ្នឹង គឺពិតជាត្រឹមត្រូវហើយ ពេលនោះ គឺកម្លាំងចលនាប្រជាពលរដ្ឋចូលរួមខ្លាំងក្លា។ សូមអស់យោបល់។

[១១:២១:១៣]

**ស៖** តើលោកចង់និយាយអំពីការចូលរួមក្នុងចលនាបដិវត្តន៍ ឬក៏យ៉ាងណា?

**ឆ៖** សូមធ្វើការជម្រាបជូន ពេលនោះ ជាស្មារតី ការយល់ដឹងរបស់ខ្ញុំ គឺមិនដឹងពាក្យថាបដិវត្តន៍យ៉ាងម៉េចទេ តែដោយលន់ នល់ ធ្វើរដ្ឋប្រហារសម្តេច នរោត្តម សីហនុ ទៅ។ ក្នុងនាម ក៏មានអង្គការមួយឈ្មោះថា "អង្គការរណសិរ្សរួបរួមជាតិកម្ពុជា" ដែលមានសម្តេច សីហនុ ជាប្រធាន។ អ៊ីចឹងក៏ប្រជារាស្ត្រទាំងអស់ ទាំងខ្ញុំក៏ចូលរួម ដើម្បីរំដោះប្រទេស រំដោះទឹកដីពេលហ្នឹង។ បាទ សូមអស់យោបល់។

**ស៖** អម្បាញ់មិញនេះ នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់មេធាវីលោក នួន ជា សម្តីដែលគាត់សួរទាក់ទងទៅនឹងការប្រព្រឹត្តទៅលើអតីតមន្ត្រីរដ្ឋការ ហើយនិងអតីតទាហាននល់ នល់លោក

បានរំឭកអំពីសុន្ទរកថា ដែលលោក ខៀវ សំផន បានថ្លែង ដែលគេហៅផងដែរ គេហៅថា ជាសុន្ទរកថាទាក់ទងទៅនឹងជនក្បត់ទាំងប្រាំពីរនាក់ ហើយសុន្ទរកថានេះត្រូវបានផ្សព្វផ្សាយនៅក្នុងរយៈពេលសង្គ្រាម ក្នុងពេលសង្គ្រាម គឺនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយ-- មុន៧៥ ហើយបន្ទាប់មកទៀត លោកបាននិយាយអំពីកិច្ចប្រជុំពីរដែលបានប្រព្រឹត្តឡើងក្រោយជ័យជម្នះ ឆ្នាំ១៩៧៥ ដែលនៅក្នុងកិច្ចប្រជុំនោះ ការប្រព្រឹត្តទៅលើអតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ត្រូវបានបញ្ជាក់។ ទោះយ៉ាងណាក្តី គេបាននិយាយនៅក្នុងកិច្ចប្រជុំនោះថា ត្រូវ -- មិនត្រូវប៉ះពាល់ទៅលើនាយទាហាន ឬក៏ស័ក្តិ៥អ្វីនោះទេ។ តើបើតាមការបកស្រាយរបស់លោកផ្ទាល់នោះ តើនេះវាជាគោលនយោបាយមួយដែលមានជាបន្ត ដែលបន្តមកពីរយៈពេលមុនសង្គ្រាម ហើយក្រោយពេលសង្គ្រាម ឬក៏យ៉ាងណា?

[១១:២៣:៤៨]

**ផៈ** ខ្ញុំបាទសូមធ្វើការឆ្លើយនូវសំណួរដែលលោកបានបញ្ជាក់ និងសួរអម្បាញ់មិញនេះ។ បាទ ពេលនោះ គឺឱកាសដែលពេលយប់សង្គ្រាម ខ្ញុំទទួលយក ហើយរីករាយ។ មកទាល់ថ្ងៃនេះ ពេលនោះ គឺសភាពការណ៍ ប្រជាជនពីក្នុង ខាងក្នុងតំបន់ ទីក្រុង ហើយនិងជនបទ ដែលមានជាបង ជាប្អូន ជាកូនជាចៅ ទៅដល់មូលដ្ឋាន ហើយបានលើកគោលការណ៍នេះ គឺពិតជាត្រឹមត្រូវ។ រឿងអីដែលត្រឹមត្រូវធ្វើនេះដើម្បីពង្រឹងសាមគ្គីនៅក្នុងមូលដ្ឋាន កុំឲ្យមានការបែងចែកអ្នកថ្មី អ្នកចាស់ អ្នកទៅពីក្រុង និងនៅជនបទ។ ខ្ញុំសូមលម្អិតបន្តិចចុះ សូមបញ្ជាក់ថាអ្នកនៅជនបទ ជាឪពុក ជាម្តាយ ជាបង ជាប្អូន គឺមានកូន មានក្មួយ មានចៅ មករៀនសូត្រសិក្សានៅភ្នំពេញ។ ហេតុដូច្នេះ គ្នាវិលត្រឡប់ទៅផ្ទះមិនរួច ក៏រួមប្រកប រកមុខរបរនៅទីក្រុងភ្នំពេញ ដើម្បីចិញ្ចឹមជីវិត។ ដល់តែពេលចប់សង្គ្រាមទៅ បានវិលត្រឡប់ទៅវិញ។ ដូច្នេះ គឺទាំងអស់គ្នាអត់មានធ្វើការរើសអើងទេ។ អ៊ីចឹងហើយបានមានមតិលើកឡើងហ្នឹង គឺនៅពេលដែលចប់សង្គ្រាមហ្នឹង។ មតិដែលផ្សាយទៅប្រកាសនៅភ្នំត្រែល គឺនិយាយគឺអ៊ីចឹង។ ហ្នឹងសូមជម្រាបអ៊ីចឹង។ ហើយអ្វីដែលខ្ញុំសប្បាយ ហើយអ្វីដែលជាក់ស្តែង ខ្ញុំបានរួមការងារពេលនោះ សូមលើកបញ្ជាក់អស់លោក -- ជម្រាបអស់លោកដែលថា អ្នកនៅខាងក្រៅ នៅតំបន់រំដោះនេះមានឪពុកមានម្តាយ គេរួមចំណែកបម្រើចលនាឲ្យជាបាយ ជាអង្ករ ជាសម្ភារៈ សម្រាប់បម្រើសមរភូមិ ប៉ុន្តែអ្នកទាំងអស់នោះក៏មានកូននៅទីក្រុងភ្នំពេញដែរ។ អ៊ីចឹងអ្វីដែលគោលការណ៍នយោបាយពេលនោះ ខ្ញុំទទួលស្គាល់ថា សាច់នៅជាមួយឈាម ឈាមនៅជាមួយសាច់ ខ្ញុំសប្បាយនឹងអនុវត្តបាទ។ គឺខ្ញុំអនុវត្តខ្ញុំអប់រំរាល់កម្មាភិបាលភូមិក្រោមថ្នាក់របស់ខ្ញុំ និងប្រជាជនទាំងមូលដ្ឋាន ទាំងអ្នកថ្មី។ បាទ សូមអស់

យោបល់ ហ្នឹងសកម្មភាពដែលខ្ញុំបានអនុវត្តនៅពេលនោះ ហើយនិងពេញចិត្តដែលខ្ញុំបានធ្វើពេលនោះ។ បាទ សូម -- រហូតមកដល់ថ្ងៃនេះបាទ សូមអស់យោបល់។

[១១:២៦:៤២]

**ស៖** តើយើងអាចនិយាយបានដែរឬទេថា លោកសប្បាយចិត្តដែលគេបានកាន់ -- ប្រកាន់ពាក្យសន្យារបស់ខ្លួន គឺថានៅពេលដែល ខៀវ សំផន និយាយក្នុងសុន្ទរកថារបស់គាត់នោះ សន្យានៅក្នុងសុន្ទរកថានោះត្រូវ -- ដែលបានប្រកាន់យកថា សន្យាតាមសុន្ទរកថា ហើយក្រោយមកប្រកាន់ពាក្យសន្យារបស់ខ្លួន--

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមឱ្យតុលាការប្រាប់ទៅគាត់ថាឱ្យគាត់សួរសំណួរ មិនមែនលើក ឬក៏ស្នើជាចំណុចអ្វីមួយនោះទេ។

**លោក អាកឡូរ វែកគែន៖**

លោកប្រធាន ខ្ញុំមិនៗនាំអ្វីទេ ខ្ញុំសួរគាត់តែប៉ុណ្ណោះទេ សួរថាតើគាត់យល់ឃើញយ៉ាងណាដែរ ព្រោះគាត់ឃើញថា ខៀវ សំផន បានថ្លែងសុន្ទរកថា គាត់បាននិយាយថា កុំឱ្យប៉ះពាល់ដល់មនុស្សមួយចំនួន។ អ៊ីចឹង--

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្ត!

[១១:២៧:៥១]

**លោក អាកឡូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរម្តងទៀត តើលោកមានអារម្មណ៍យ៉ាងណាដែរ លោកបាននិយាយថា លោកសប្បាយហ្នឹងគឺថា ដោយសារតែលោកសង្កេតឃើញថា លោកខៀវ សំផន បានសន្យា ហើយនិងបទបញ្ជាដែលលោកបានទទួលពីមជ្ឈិមនោះ គឺថាសន្យាហើយមានការប្រកាន់ពាក្យសន្យារបស់ខ្លួន។ អ៊ីចឹងហើយឬដែលធ្វើឱ្យលោកសប្បាយចិត្តនៅពេលនោះ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមឆ្លើយបាទ ខ្ញុំសប្បាយនៅពេលគាត់ប្រកាសហើយៗ ដល់ពេលសង្គ្រាមគឺមានសារាចរអ៊ីចឹងទៀតបាទ។ មិនមែនជាសារាចរទេ សម្តីផ្ទាល់មាត់ហ្នឹង។ បាទ អាហ្នឹងអ៊ីចឹង។ បាទ សូមអស់យោបល់។

**ស៖** បើតាមការសង្កេតរបស់លោក នៅពេលដែលលោកទទួលបាន ឬក៏ឮការបង្គាប់ហ្នឹងក្រោយពេលសង្គ្រាមមកហើយហ្នឹង តើលោកមានដឹងដែរឬទេថា ហេតុអ្វីបានជាគេធ្វើការរំឭកហ្នឹងដល់ថ្នាក់មូលដ្ឋាន? ឧទាហរណ៍ដូចជា ការរំឭកឡើងវិញថាកុំឲ្យប៉ះពាល់ដល់អតីតមន្ត្រីរដ្ឋការ ឬក៏យោធាលន់ នល់ ជាដើមហ្នឹង។ តើលោកមានដឹងទេថា ហេតុអ្វីបានគេរំឭកថា កុំឲ្យប៉ះពាល់អតីតមន្ត្រីរដ្ឋការហើយនិងអតីតយោធានេះក្រោយពេលចប់សង្គ្រាមហើយហ្នឹង?

**ឆ៖** សូមឆ្លើយ ការយល់របស់ខ្ញុំ គឺខ្លឹមសារដែលរំឭកនេះគឺដើម្បីឲ្យប្រជាជនកម្ពុជាទាំងមូលឯកភាពគ្នាជួបជុំវង្សថៅត្រកូលរបស់ខ្លួនគ្រប់និន្នាការនយោបាយបាទ គ្រប់ទាំងអស់ហ្នឹងដើម្បីសុខដើម្បីកសាងប្រទេស ដោយពេលនោះទន្ទឹមនឹងចប់សង្គ្រាមក៏លើកគោលការណ៍ថា កសាងប្រទេស ការពារប្រទេស។ បាទ សូមអស់យោបល់។

[១១:៣០:០០]

**ស៖** រហូតដល់ពេលនេះ លោកមិនបាននិយាយចំណុចមួយ ក៏ប៉ុន្តែខ្ញុំចង់សួរលោកថាតើលោកនៅតែនៅក្នុងគណៈឃុំកំពង់ស្វាយនៅក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏យ៉ាងណា ឬក៏លោកត្រូវបានគេចាត់តាំងឲ្យធ្វើអ្វីផ្សេងទៀត នៅក្នុងអំឡុងឆ្នាំ ចន្លោះឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩ នោះ?

**ឆ៖** សូមឆ្លើយ ខ្ញុំសូមជម្រាបការពិត ពេលដែលតំបន់២៥ ចាត់ចូលក្នុងភូមិភាគនិរតី។ អ៊ីចឹងអង្គការថ្នាក់ -- មិនដឹងខាងថ្នាក់ណាទេ គឺពាក្យប្រើអង្គការ ក៏ចាត់តាំងខ្ញុំឲ្យទៅនៅតំបន់២៥ ក្នុងស្រុកកៀនស្វាយ ទទួលខុសត្រូវក្នុងឃុំកំពង់ស្វាយ មានតួនាទី និងឋានៈជាប្រធានឃុំ។ ពេលនោះឆ្នាំ១៩៧៦ បាទ ដល់តែចូលក្នុងខែមួយ បានអង្គការបានបញ្ជូនមកនៅស្រុកកណ្តាលស្ទឹង មកនៅឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលបាទ។ បាទសូមអស់យោបល់។

**ស៖** តើលោកនៅតែជាកម្មាភិបាលដដែលឬ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នេះ?

**ឆ៖** សូមធ្វើការជម្រាបជូន គឺខ្ញុំ ពេលដែលអង្គការឲ្យមកនៅឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង តំបន់២៥។ ពេលនោះស្ថិតក្នុងឋានៈជាអនុឃុំ ពីរ-- បានបីខែ បាទ រួចហើយក៏អង្គការដកសិទ្ធិឲ្យមក

ជាសមាជិកសាខា បាទ នៅក្នុងឃុំបឹងខ្យាងហ្នឹង រហូតទល់ ៧៨ បាទ។ សូមអស់យោបល់បាទ។

**ស៖** ដោយអំមិញនិយាយអំពីការលម្អិតទាក់ទងនឹងការចាត់តាំងរបស់លោកផ្សេងៗហ្នឹង អ៊ីចឹង ខ្ញុំគ្រាន់តែចង់សួរថាលោកនៅតែជាកម្មាភិបាលដដែល ឬក៏យ៉ាងណា ឬក៏ពេលណាមួយនោះ លោកត្រូវបានកែប្រែវណ្ណៈ ឬគេទម្លាក់ឋានន្តរសក្តិ ឬក៏ចាត់តាំងឲ្យលោកធ្វើអ្វីផ្សេងវិញ ទៅវិញនោះ?

[១១:៣៣:៣៣]

**ផ៖** បាទ ខ្ញុំឆ្លើយហើយ។ អម្បាញ់មិញ ដោយខ្ញុំមិន -- បាទ មិនសូវយល់ពីសំណួរ បានខ្ញុំបាទឆ្លើយរហូតដល់តួនាទីរបស់ខ្ញុំ ហើយមកពីកំពង់ស្វាយ មកនៅកណ្ដាលស្ទឹង ឃុំបឹងខ្យាង។ ឋានៈខ្ញុំជាសមាជិកសាខា ក្នុងឃុំកំពង់ -- ក្នុងឃុំបឹងខ្យាងបាទ សូមជ្រាប។ សូមអស់យោបល់។

**ស៖** តើនៅពេលណាមួយនោះ លោកធ្លាក់ខ្លួន មកត្រឹមតែជាអ្នកធ្វើការសាមញ្ញធម្មតាទេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ផ៖** បាទ សូមធ្វើការជម្រាបឆ្លើយជូន នៅក្នុងឆ្នាំ១៩៧៧ បាទ រហូតដល់ដាច់ឆ្នាំ១៩៧៨ ហ្នឹង បាទ។ នៅធ្លាក់ខ្លួនជាសមាជិក សាមញ្ញៗហ្នឹងបាទ។ បាទ សូមអស់យោបល់បាទ។

**ស៖** សូមអរគុណបាទ។ ខ្ញុំចង់អំពីរឿងហ្នឹងហើយអម្បាញ់មិញហ្នឹង។ លោកជាកម្មាភិបាលផង ហើយនិងជាប្រជាពលរដ្ឋសាមញ្ញធម្មតាផងនៅក្នុងរបបខ្មែរក្រហមហ្នឹង។ អ៊ីចឹងខ្ញុំចង់បានការកត់សម្គាល់ពីលោកទាក់ទងទៅនឹង ជាដំបូងហ្នឹងជា -- ទាក់ទងទៅនឹងការកង្វះស្បៀងនៅសម័យខ្មែរក្រហមហ្នឹង។ តើហេតុអ្វីក៏គេទាំងអស់គ្នាយល់ស្របថា ប្រជាជនហ្នឹងហូបចុកមិនគ្រប់គ្រាន់ទេនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង? តើរូបលោកផ្ទាល់ហ្នឹង លោកមានកត់សម្គាល់ឃើញថា មានកង្វះអាហារហ្នឹងទេ? ហើយលោកឃើញស្ថានភាពជាក់ស្ដែងហ្នឹងយ៉ាងណាដែរ?

[១១:៣៦:០២]

**ផ៖** បាទ ខ្ញុំសូមធ្វើការជម្រាបជូន។ កាលឆ្នាំ៧៦ នៅបឹង -- នៅកំពង់ស្វាយ គឺប្រជាជនមានការហូបអង្ករពីរខាំ រួមជាមួយនឹងពោត ហ្នឹងនៅឆ្នាំ៧៦ៗ នៅឃុំកំពង់ស្វាយ។ តែមកដល់ឆ្នាំ១៩៧៧ និងរហូតដល់ឆ្នាំ១៩៧៨-៧៩ នេះ នៅឃុំកំពង់ស្វាយ គឺហូបបាយ។ អត់មានហូបបបរ ហើយអត់ខ្វះខាតទេបាទ។ សូមជម្រាប។ មិនត្រឹមតែប៉ុណ្ណោះ គេបានឧបត្ថម្ភដល់អង្គការ។ បាទមួយរដូវៗ គឺស្រូវដឹកទៅដឹកតាមរយៈគណៈតំបន់ឲ្យសេដ្ឋកិច្ចទៅដឹក បាទ។ សូមជម្រាប។ សូមអស់យោបល់។

**ស៖** បាទ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយនៅពេលក្រោយវិញតែម្តង ទាក់ទងទៅនឹងការបង្កើត

សហករណ៍។ មុនថ្ងៃជ័យជម្នះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ បើតាមលោកដឹងនោះ តើមានប្រភេទសហករណ៍អ្វីខ្លះនៅក្នុងតំបន់ដែលលោកនៅហ្នឹង?

**ឆ៖** បាទ សូមឆ្លើយ មុនហ្នឹងបង្កើតសហករណ៍ដំបូង គឺក្រុមប្រវាស់ដៃ។ ហើយឆ្លងក្រុមប្រវាស់ដៃ មកចូលជាសហករណ៍ ប្រមូលកម្លាំងគ្នា បាទ។ ហ្នឹងនៅក្នុងតំបន់ដែលខ្ញុំគ្រប់គ្រង នៅឃុំជាងទងហ្នឹងបាទ។ ដល់ចប់សង្គ្រាម បានមានសហករណ៍មួយ គឺហៅថាសហករណ៍កម្រិតខ្ពស់ ប្រើភាសាជំនាន់ហ្នឹង។ បានន័យថា សមូហភាព។ ធ្វើបាន ហូបរួមបាទ។ បង្កើតជាចង្ក្រានរួម -- ចង្ក្រានបាយរួមបាទ។ សូមជម្រាប។ សូមអស់យោបល់។

[១១:៣៨:១៤]

**ស៖** តើរហូតដល់ពេលណាកសិករដែលគេប្រមូលឲ្យក្នុងក្រុមប្រវាស់ដៃ ឬនៅក្នុងសហករណ៍ហ្នឹង គាត់មានសិទ្ធិអាចរក្សាកម្មសិទ្ធិផ្ទាល់ខ្លួនបានមួយចំនួន? តើដល់ឆ្នាំណាដែរ? ដល់ពេលណាដែរ?

**ឆ៖** សូមធ្វើការជម្រាប ពេលគាត់រក្សាកម្មសិទ្ធិរបស់គាត់ គឺឆ្នាំ៧០ មកទល់គ្នានឹង៧២។ អាហ្នឹងគឺក្រុមប្រវាស់ដៃ។ បាទ អាហ្នឹងគាត់គឺនៅមានកម្មសិទ្ធិរបស់គាត់រៀងៗខ្លួន។ ដែលចូលមកដល់ឆ្នាំ៧៣ -- ចុង៧២ ដើម៧៣ មក៧៤ ហ្នឹងគឺ បានបង្កើតកម្មសិទ្ធិសមូហភាពបាទ។ សហករណ៍ហ្នឹងគឺនៅ ស្ថិតនៅក្នុងក្របខ័ណ្ឌធ្វើការរួម ប៉ុន្តែចែកផលឲ្យទៅតាមផ្ទះរៀងខ្លួន។ ហើយដល់ក្រោយមក ចប់សង្គ្រាមបានហូបបាយរួម បាទ។ ជង្រុករួម បាទ។ សូមអស់យោបល់។

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយអំពីបញ្ហាស្បៀងអាហារវិញម្តង។ តើនៅពេលដែលលោកជាកម្មាភិបាលហ្នឹង?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ខ្ញុំសូមជំទាស់។ ខ្ញុំមិនដឹងថាត្រូវជំទាស់ឥឡូវ ឬក៏ចាំឲ្យគាត់ចោទសំណួរចប់ទេ។ ខ្ញុំគិតថា វិសាលភាពនៃសំណួរដែលសួរហ្នឹង ត្រូវតែគោរពទៅតាមការរំឮករបស់អង្គជំនុំជម្រះ ថាមានប្រភេទសំណួរដែលអាចសួរទៅបាន ហើយសំណួរមួយចំនួនមិនអាចសួរបានទេ។ ហើយអ៊ីចឹងរយៈពេល៥នាទីហើយ ដែលគាត់សួរសំណួរទៅគាត់ហ្នឹងទាក់ទងទៅនឹងស្ថានភាពអាហារនៅរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់មានសិទ្ធិសួរសំណួរទាំងអស់នេះ នៅក្នុងសំណុំរឿង០០២/២ គឺថាវិសាលភាពទូលាយ។ អ៊ីចឹង ខ្ញុំសូមឲ្យអង្គជំនុំជម្រះរំឮកទៅមេធាវីឲ្យបានច្បាស់លាស់ អំពីវិសាលភាពនៃការចោទសំណួរទៅលើសាក្សីនេះ តើគាត់មានសិទ្ធិសួរក្នុងវិសាលភាពណា។

[១១:៤០:៤៨]

**លោក អាកឡូវ វែកគែន៖**

បាទ ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ការណែនាំរបស់អង្គជំនុំជម្រះ គឺថាត្រូវនិយាយហៅថា អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ យើងនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០២/០២ ដែលគេបង្គាប់ប្រាប់យើងថា សហករណ៍ហ្នឹងត្រូវបានបង្កើតឡើង --អ៎! ០២/១ ហើយ គឺថាការបង្កើតសហករណ៍ហ្នឹងវាអាស្រ័យទៅតាមចលនាប្រជាជន។ អ៊ីចឹងខ្ញុំយល់ឃើញថា ខ្ញុំស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះទេ។ ខ្ញុំចោទសំណួរ ខ្ញុំសួរទៅគាត់នោះ ដើម្បីចង់ដឹងថាគេបង្កើតសហករណ៍ហ្នឹងវាមានលំដាប់លំដោយរបៀបណាដែរ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមយោងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ គឺថាជាសេចក្តីសម្រេច S2/5 គឺថាតុលាការបានចេញសេចក្តីណែនាំឲ្យផ្តោតទៅលើតែចំណុចមួយចំនួន នៃសាលក្រម ០២/១ តែប៉ុណ្ណោះ។ បើសិនជាអង្គជំនុំជម្រះ គិតអំពីភាពពាក់ព័ន្ធនៃសំណួរ ការចោទសំណួរនៃសំណុំរឿង ០០២/០២ តែម្តងនោះ យើងនឹងសម្របសម្រួលតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះមេត្តាបំភ្លឺឲ្យបានច្បាស់អំពីវិសាលភាពនៃការបើកសវនាការនេះ។

[១១:៤២:១៤]

**ប្រធានអង្គជំនុំ៖**

អ៊ីចេះ គឺទាក់ទងវិសាលភាពនៃការជំនុំជម្រះ នៅលើបណ្តឹងសាទុក្ខរបស់យើងក្នុងសំណុំរឿងលេខ០០២/០១ហ្នឹង គឺពាក់ព័ន្ធនឹងបញ្ហាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ការដឹកនាំ និងការចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហាផ្សេងៗទាក់ទងការជម្លៀស ដំណាក់កាលទី១ ដំណាក់កាលទី២។ អ៊ីចឹងហើយ ប៉ុន្តែដល់សំណួរនេះ គឺខ្ញុំពិនិត្យទៅឃើញថា វាចាកឆ្ងាយពីវិសាលភាពហ្នឹងហើយ។ អ៊ីចឹងសូមឲ្យលោកមេធាវីហ្នឹង គឺធ្វើការផ្លាស់ប្តូរសំណួរទៅ បាទ។

**លោក អាកឡូវ វែកគែន៖**

បាទ ខ្ញុំធ្វើតាមលោកប្រធាន។ ខ្ញុំគ្រាន់តែសូមរំឭកថា ខ្ញុំមិនទាន់បានចោទសំណួរខ្ញុំទេ ហើយតុលាការមានសិទ្ធិសម្រេចថាៗ ខ្ញុំហ្នឹងសួរក្រៅវិសាលភាពទៅហើយ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ឥឡូវខ្ញុំសូមសួរសំណួរបន្តទៅទៀត ខ្ញុំគ្រាន់តែចង់ថាតើចន្លោះថ្ងៃជ័យជម្នះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយនិងថ្ងៃដែលគាត់បានបាត់បង់ឋានៈជាកម្មាភិបាលរបស់គាត់នោះ តើគាត់មានធ្លាប់បានទទួលបទបញ្ជា ឬក៏សេចក្តីណែនាំពីថ្នាក់លើ ពីមជ្ឈិមមក ឲ្យបង្អត់អាហារប្រជាជនដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមឆ្លើយ។ បទបញ្ជាពីថ្នាក់មជ្ឈិមមកគឺគ្មានទេ បាទ។ មិនឲ្យកម្មាភិបាលបង្អត់បាយប្រជាជនទេ មានតែថា បើកម្មាភិបាលណាមិនដោះស្រាយជីវភាពប្រជាជន គឺកម្មាភិបាលនោះ ត្រូវរងទម្ងន់ទោសហើយ។ អាហ្នឹង គឺមានប៉ុណ្ណឹងបាទ។ សូមអស់យោបល់។

[១១:៤៥:២៩]

**ស៖** បាទ រូបលោកផ្ទាល់នៅពេលដែលលោកជាកម្មាភិបាល តើលោកមានសិទ្ធិអំណាចសម្រេចអ្វីមួយ ឧទាហរណ៍នៅពេលដែលមានបញ្ហាហ្នឹង លោកមានកាតព្វកិច្ចត្រូវតែរាយការណ៍ទៅថ្នាក់លើ ឬក៏លោកមានសិទ្ធិអំណាចខ្លះដែរក្នុងការសម្រេចថា តើត្រូវធ្វើរបាយការណ៍ទៅថ្នាក់លើ ឬក៏មិនចាំបាច់ទេ?

**ឆ៖** សូមធ្វើការជម្រាបនិងសូមឆ្លើយ។ ខ្ញុំគ្មានសិទ្ធិសម្រេចនូវរាល់កិច្ចការទាំងឡាយ តូចក៏ដោយធំក៏ដោយ គឺមានតែសេចក្តីស្នើទៅខាងថ្នាក់លើបាទ។ មានថ្នាក់ស្រុកបាទ។ អ៊ីចឹង រាល់កិច្ចការទាំងអស់ គឺសុទ្ធតែអ្នកបានស្នើ តែត្រង់សម្រេចវិនិច្ឆ័យ ម្នាក់ឯងគឺអត់ទេបាទ។

**ស៖** តើលោកអាចមិនប្រាប់ថ្នាក់លើដែរឬទេ តើលោកធ្លាប់មិនរាយការណ៍ទៅថ្នាក់លើដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ដែរ ចំពោះកិច្ចការណា ការខុសឆ្គងបន្តិចបន្តួច នៅក្នុងសហករណ៍ នៅក្នុងមូលដ្ឋាន គឺអត់រាយការណ៍ទេ។ ឧទាហរណ៍ដូចជា គ្នាភ្ជួរទៅបាក់នង្គ័ល បាក់ពន្លួញ ហ្នឹងមិនដែលរាយការណ៍ទេ គឺដោះស្រាយនៅក្នុងមូលដ្ឋាន។ បញ្ហាហ្នឹងគឺអត់រាយទេ សូមជម្រាបអ៊ីចឹងបាទ។ តែបើបញ្ហាដែលប្រជាជនខ្វះបាយ ខ្វះសម្លៀកបំពាក់ ខោអាវ អាហ្នឹងខ្ញុំរាយការណ៍ឡើងទៅលើ។ អានេះ សូមលោកម្ចាស់សំណួរជ្រាប។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំមានសំណួរមួយចុងក្រោយ។

បាទ សូមអរគុណ លោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំសួរបញ្ចប់។

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកថា នៅពេលដែលលោកធ្វើការចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដំបូងទី លោកជាកម្មាភិបាល ហើយក្រោយមកលោកគ្រាន់តែជាប្រជាជនសាមញ្ញតែប៉ុណ្ណោះ តើលោក នៅពេលដែលលោកជាកម្មាភិបាល ហើយនិងក្រោយមកក្លាយជាប្រជាជននោះ លោកមានបានសង្កេតឃើញថា នៅសម័យនោះ មានកម្មាភិបាលដែលជាអនក្ខរជនដែរឬទេ ដែលមិនចេះអានអក្សរផង?

**លោក នីកូឡាស គូមជែន៖**

នេះគឺជាចំណុចមួយដែលខ្ញុំចង់ឲ្យមានការបញ្ជាក់ដែរ ព្រោះថាសក្ខីកម្មរបស់សាក្សីផ្ទុយពីមេធាវី ព្រោះថា មេធាវីគាត់យល់ថា យល់ទៅតាមការបកប្រែជាភាសាបារាំង ប៉ុន្តែខ្ញុំយល់ថា សាក្សី -- គឺមេធាវីយល់ថា សាក្សីជាកម្មាភិបាលធម្មតា ប៉ុន្តែខ្ញុំ ខ្ញុំយល់ថាជាបេក្ខជន ឬក៏ជាបក្ខជនធម្មតា។ ដូច្នេះ យើងគួរតែបញ្ជាក់ឲ្យបានច្បាស់អំពីបញ្ហានេះ។

[១១:៤៨:២៨]

**លោក អាកទូរ វែកកែន៖**

បាទ ខ្ញុំយល់ស្រប។

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** ឥឡូវសូមសួរបញ្ជាក់ លោកសាក្សី តើលោកអាចបញ្ជាក់ជូនតុលាការបានដែរឬទេ ថា លោកចង់និយាយថា យ៉ាងម៉េចនៅពេលដែលលោកនិយាយថា លោកគ្រាន់តែជាសមាជិកសាមញ្ញ នៅក្នុងសហាគមន៍នោះ តែប៉ុណ្ណោះ សហករណ៍នោះ តើលោកចង់មានន័យយ៉ាងម៉េចដែរ ពាក្យសមាជិកសាមញ្ញ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមធ្វើការបញ្ជាក់ជម្រាបជូន។ ក្នុងពេលនោះ ខ្ញុំធ្លាក់មកជាសមាជិកសាខា គឺសមាជិកសាមញ្ញ។ បានន័យថា គ្មានសិទ្ធិអីទាំងអស់ មានសិទ្ធិតែត្រឹមទទួលការណែនាំពីគណៈឃុំហ្នឹង បាទ មូលហេតុខ្ញុំក៏មិនបានដឹងដែរ។ ម្យ៉ាងខ្ញុំជា-- គេចាត់ថាជាអនុធនសិស្ស។ ខ្ញុំមានសញ្ញាប័ត្រ *សេទីហ្វីកា* បាទ ពីដើម គេហៅថា សញ្ញាបត្របឋមសិក្សា បារាំង-ខ្មែរ ហើយគេចាត់ថាជាអនុធន។ អ៊ីចឹងទី១ ខ្ញុំដឹងខ្លួនឯងអ៊ីចឹង។ ហើយចំណុចទី២ គឺមានបងមួយដែលមានឈ្មោះ សៅ ស៊ុំ ហៅជ្រុន ហ្នឹង គាត់មានតួនាទីជាជំទប់លេខ៣ នៅក្នុងសង្កាត់លេខ៦ហ្នឹង នៅជាមួយរដ្ឋបាល លន់ នល់ ហ្នឹង។

អ៊ីចឹងគាត់ពេលចេញទៅ គឺគាត់មានការពាក់ព័ន្ធ។ អ៊ីចឹង កាលដែលខ្ញុំអស់តួនាទី មានសិទ្ធិជាប្រជាជនសាមញ្ញ ខ្ញុំមិនឆ្ងល់ ហើយខ្ញុំក៏មិនថ្នាំងថ្នាក់ដែរ ពេលនោះគ្រាន់តែមានអារម្មណ៍សម្របខ្លួនដើម្បីរស់ៗក្នុងសង្គមបាទ ក្នុងសហករណ៍បាទ សូមអស់យោបល់ ខ្ញុំសូមជម្រាប។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអស់សំណួរហើយៗក៏ដល់ពេលបញ្ចប់ដែរ ហើយយ៉ាងម៉េចដែរ?

**លោក អាកទ្ធូរ វែកគែន៖**

លោកប្រធាន ខ្ញុំនៅសល់សំណួរចុងក្រោយត្រូវសួរដដែល សំណួរដែលខ្ញុំសួរអម្បាញ់មិញនេះគឺគ្រាន់តែសួរដើម្បីបំភ្លឺខ្លឹមសារពាក្យថាសមាជិកសាមញ្ញហ្នឹងមានន័យយ៉ាងម៉េច។ ឥឡូវចូលដល់ខ្ញុំ -- ចូលដល់ពេលខ្ញុំសួរសំណួរចុងក្រោយលោកប្រធាន។ បាទ សូមអរគុណលោកប្រធាន។

**សួរដោយ លោក អាកទ្ធូរ វែកគែន៖**

**ស៖** បាទ ខ្ញុំចង់ដឹងថាចន្លោះឆ្នាំ១៩៧៩ លោកមានកត់សម្គាល់ឃើញថានៅជុំវិញរបស់លោកនោះគឺមានកម្មាភិបាលដែលខុសពីលោក ដែលលោកនិយាយថាលោកមាន *សេទីហ្វិកា* ហើយថា ហើយកម្មាភិបាលផ្សេងទៀតនោះ មិនមានទទួលការអប់រំអីទេ ចំណេះដឹងអីទេ សុទ្ធតែជាអនក្ខរជន។ អ៊ីចឹងបើករណីហ្នឹងមានមែននោះ តើវាជះឥទ្ធិពលយ៉ាងណាដែរទៅលើការបញ្ចា ការយល់ដឹងអំពីសេចក្ដីណែនាំពីថ្នាក់លើ?

[១១:៥១:៤៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

នៅ -- នៃវិសាលភាពបញ្ចប់ត្រឹមឆ្នាំ១៩៧៧នោះទេ អ៊ីចឹងសូមឲ្យលោកមេធាវីហ្នឹង គាត់គោរពតាមវិសាលភាពនៃសំណុំរឿងនេះផង គឺថាពី៧៥ ដល់៧៧ទេ។

**លោក អាកទ្ធូរ វែកគែន៖**

អម្បាញ់មិញនេះខ្ញុំថាអត់បញ្ហាទេ ខ្ញុំសួរបាន។

**សួរដោយ លោក អាកទ្ធូរ វែកគែន៖**

ឥឡូវពីថ្ងៃជោគជ័យរហូតដល់ឆ្នាំ១៩៧៧នោះ តើលោកមានបានសង្កេតឃើញថានៅជុំវិញខ្លួន -- នៅជុំវិញលោកនោះមានកម្មាភិបាលអនក្ខរជនច្រើនដែរឬទេ ហើយបើក្នុងករណីនេះមាននោះ តើវាជះឥទ្ធិពលយ៉ាងណាដែរទៅលើការបំពេញការងាររបស់ពួកគាត់នោះ ពីការយល់សេចក្ដីណែនាំដែលចេញ

មកពីថ្នាក់លើជាដើមនោះ?

**លោក សៅ វ៉ន៖**

**ឆ៖** សូមឆ្លើយ សូមធ្វើការបញ្ជាក់ជម្រាបជូន។ គឺខ្ញុំប្រកាន់នៅអធិបតេយ្យរបស់ខ្លួន។ ដូច្នេះគេទាំងឡាយទោះបីអ្នកណាអត់ចេះអក្សរ ឬមិនចេះអក្សរអី ខ្ញុំអត់វាយតម្លៃ ឬយកការងាររបស់គេមកវិនិច្ឆ័យទេ។ អ៊ីចឹងក្នុងឋានៈខ្ញុំដែលចេះអាន ចេះសរសេរបានអានរួចនេះ កាលណាបើខ្ញុំរិះគន់ ឬសាកសួរថាអ្នកឯងរៀនដល់ណា អីរៀនណា បានន័យថាខ្ញុំជាអ្នកច្រណែន ឬជាអ្នករករឿង គឺជាអ្នកបង្កហើយស្របនឹងខ្ញុំជាអនុធន ដូច្នេះខ្ញុំត្រូវ មិនសមនឹងៗឋានៈខ្លួនជាអ្នកយល់ដឹងបន្តិចបន្តួចទេបាទ។ អ៊ីចឹងសូមអស់យោបល់ ខ្ញុំសូមឆ្លើយប៉ុណ្ណឹងបាទ។

[១១:៥៣:៥២]

**លោក អាកឡូវ វ៉េកគែន៖**

លោកប្រធាន មើលទៅទាល់តែត្រូវការពេលវេលាច្រើនដើម្បីសួរលម្អិតអំពីចំណុចអម្បាញ់មិញនេះ។ តែឥឡូវដោយសារអស់ពេលវេលាហើយ សូមបញ្ចប់ត្រឹមប៉ុណ្ណឹង សូមអរគុណច្រើនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឥឡូវដោយសារពេលវេលាវាបានបញ្ចប់អស់ហើយដែរ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការនៅពេលនេះ ហើយនឹងបន្តសវនាការនៅវេលាម៉ោងដប់បីនិងសាមសិបនាទីរសៀល ហើយសូមអញ្ជើញលោកមន្ត្រីពន្ធនាគារនាំជនជាប់ចោទត្រឡប់ទៅពន្ធនាគារវិញ ហើយដល់ពេលម៉ោងជិតដប់បី និង សាមសិបនាទី សូមអញ្ជើញត្រឡប់ -- នាំត្រឡប់មកទីកន្លែងនេះវិញ។

ប្រកាសផ្អាកបាទ។

*(សវនាការសម្រាកពីម៉ោង ១១:៥៤ នាទី ដល់ម៉ោង ១៣:២៧ នាទី)*

[១៣:២៧:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

តុលាការកំពូល -- អង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការ។ នៅថ្ងៃល្ងាចនេះ គឺជាការបន្តសួរសំណួរទៅលើសាក្សីដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹង

រដ្ឋប្បវេណី។ ដូច្នេះ គឺរយៈពេលដែលសម្រាប់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ គឺមានរយៈពេលមួយម៉ោងសាមសិបនាទី។ ដូច្នេះ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ គឺសុំការអនុញ្ញាតឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំសួរមុនលោកប្រធាន ហើយខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះជូនសហភាតារបស់ខ្ញុំ គឺមេធាវី វ៉ែន ពៅ។

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពឯកឧត្តមប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី! យើងបានស្តាប់ហើយពីការផ្តល់ចម្លើយរបស់លោកពេញមួយព្រឹកមកនេះ លោកបានឆ្លើយហើយថា មិនមានផែនការ ឬក៏ការអនុវត្តចំពោះអតីតទាហានលន់នល់ ឬមន្ត្រីរាជការទេ នៅក្រោយថ្ងៃរំដោះ ១៧ មេសា ១៩៧៥។ តែផ្ទុយទៅវិញ ភាគីយើងខ្ញុំមាន -- ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប ដែលសុំការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញនូវ ដែលពួកគាត់បានមកផ្តល់សក្ខីកម្មនៅសវនាការរួចហើយ។ ខ្ញុំសូមដកស្រង់នូវចម្លើយរបស់គាត់ ដែលផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអ្វីដែលលោកសាក្សីបានលើក ដើម្បីជូនអង្គសវនាការ និងសូមឲ្យលោកសាក្សី ដើម្បីធ្វើការអង្កេត និងឆ្លើយ ឬក៏ប្រតិកម្មទៅលើអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីទី១ ដែលខ្ញុំនឹងលើកយកមក គឺដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ យស ផល គាត់បានមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់សក្ខីកម្មអំពីផលប៉ះពាល់ និងការទទួលរងនូវព្យសនកម្មលើរូបពីរបបខ្មែរក្រហមនេះ គឺសវនាការថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ដែលមានប្រតិចារឹក ឯកសារ គឺ E1/197.1។ សូមជម្រាបអង្គសវនាការថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគាត់ត្រូវបានគេជម្លៀសឲ្យទៅនៅភូមិមួយនៅខេត្តកំពង់ចាម។ ឯកឧត្តមប្រធាន ខ្ញុំបាទសូមដកស្រង់នូវសក្ខីកម្មរបស់គាត់ នៅម៉ោង១៤:២៦:៣២វិនាទី ចម្លើយរបស់គាត់បានឆ្លើយថា៖ “បាទ លោកស្រីទាហានខ្មែរក្រហមបានឲ្យខ្ញុំធ្វើប្រវត្តិរូបដូចគ្នា ប៉ុន្តែដោយខ្ញុំឃើញមានប៉ូលិស ទាហានស្លាប់ច្រើន ឬក៏ចាប់យកទៅបាត់ច្រើន ខ្ញុំ

កុហកគេថា ខ្ញុំជាភ្នាក់ងាររដ្ឋការបម្រុង"។ ចម្លើយរបស់គាត់ជាបន្តទៀតថា៖ "ខ្ញុំឃើញអ្នក -- ឃើញពិនិត្យនឹងភ្នែកខ្ញុំ ឃើញដែលគេធ្វើប្រវត្តិរូបមានស័ក្តិ១ ស័ក្តិ២ រហូតដល់ស័ក្តិ៤ ស័ក្តិ៥ ហើយនិងគឺគេយកម៉ូតូបញ្ចោះយកទៅបាត់"។ ចម្លើយរបស់គាត់មួយទៀតដែរ៖ "សូមជម្រាបលោកប្រធាន សូមជម្រាបលោក លោកស្រីមេធាវី ខ្ញុំបានឃើញនឹងភ្នែកខ្ញុំតែម្តងបាទ ហើយបានឃើញនឹងភ្នែក ហើយបានឃើញនូវអ្វីៗទាំងអស់នៅទីនោះ ខ្ញុំមិននិយាយថាម៉េចទេ បើខ្ញុំឃើញនឹងភ្នែកទៅហើយបាទ"។ សំណួររបស់ខ្ញុំដែលចង់សួរលោកសាក្សីថា តើលោកមានបានអង្កេត ឬចងចាំឬទេ តើមានអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីលើកឡើង -- សក្ខីកម្មរបស់គាត់នេះ តើលោកមានប្រតិកម្ម ឬក៏លោកបានអង្កេតឃើញយ៉ាងម៉េចដែរ?

[១៣:៣២:០០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ មិនមែនដោយសារតែសាក្សីមិនអាចត្រូវបានគេបង្ហាញ ឬក៏បានអានឲ្យស្តាប់នូវចម្លើយរបស់សាក្សីដទៃទៀយ ប៉ុន្តែសាក្សីរូបនេះគាត់មិនអាចនិយាយអ្វីអំពីបញ្ហាស្ថិតនៅក្រៅស្រុកដែលគាត់កំពុងធ្វើការនោះឡើយ។ សក្ខីកម្មរបស់គាត់អាចផ្តល់ត្រឹមស្រុក១០៥ ហើយនិងភូមិភាគនិរតី ហើយខ្ញុំឮថា និយាយផងដែរអំពីកំពង់ចាម។ ដូច្នេះខ្ញុំគិតថាគាត់ប្រហែលជាមិនអាចឆ្លើយអ្វីបានទាក់ទងទៅនឹងហេតុការណ៍ទាំងអស់នេះ ដូចដែលមេធាវីបានរៀបរាប់នោះឡើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

កាលពីព្រឹកមិញ មេធាវីការពារខំនិយាយថា មានគោលនយោបាយ ហើយបានឲ្យសាក្សីហ្នឹងនិយាយអត្ថិភាពនៃគោលនយោបាយ ដែលសំដៅថា ហាមមិនឲ្យប៉ះពាល់ដល់អតីតយោធាលន់ នល់។ អ៊ីចឹងយើងចង់ផ្ទៀងសាក្សីនេះ និងចម្លើយរបស់សាក្សីផ្សេងទៀត ពីព្រោះថាកាលពីព្រឹកហ្នឹងគាត់ខាងមេធាវីចង់បង្ហាញថា មានគោលនយោបាយថ្នាក់ជាតិ។ អ៊ីចឹងហើយបានយើងចង់ផ្ទៀងគាត់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានឆ្លងកាត់មានបទពិសោធន៍នៅក្នុងស្រុកផ្សេងទៀតក្រៅពីស្រុករបស់សាក្សី។ អ៊ីចឹងយើងយល់ឃើញថា របៀបចោទសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនេះគឺជាការចោទសំណួរសមស្រប ដើម្បីផ្ទៀងផ្ទាត់ឲ្យដឹងថាមានមែនឬក៏យ៉ាងណា លោកប្រធាន។

[១៣:៣៣:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ ទាក់ទងទៅនឹងបញ្ហាសំណួរនេះគឺ ខ្ញុំសូមរំឭកដល់មេធាវីថា គួរណាស់តែជៀសវាងនូវសំណួរនាំមុខ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះគិតថា ឲ្យអស់លោកហ្នឹងគឺការដាក់តាំងសំណួរ គឺសំណួរណាដែលខ្លី ហើយអាចងាយយល់ ហើយនិងស្តាប់បាន។ គឺពុំគប្បីប្រើនូវសំណួរនាំមុខទេ។ ហើយអម្បាញ់មិញនេះ ខ្ញុំពិនិត្យទៅឃើញថា យកសំណួរដែលឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះមុនមកដើម្បីរៀបរាប់ឲ្យមេធាវីស្តាប់ -- ឲ្យជន សាក្សីនេះស្តាប់។ ដូច្នេះ គឺប្រហាក់ប្រហែលជាសំណួរនាំមុខដែរ។ ព្រោះអត់បានអីសួរសោះ ហើយលើកឡើងត្រង់ហ្នឹងតែម្តង អ៊ីចឹងហើយគឺសូមតាំងសំណួរឡើងវិញ ហើយការសំណួរនេះគឺធ្វើម៉េចកុំឲ្យវាមានបញ្ហាទាក់ទងនឹងការនាំមុខនោះបាទ។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ខ្ញុំសូមការបំភ្លឺពីតុលាការលោកប្រធាន ពីព្រោះថាយើងបានជ្រើសរើសយកសម្រង់ជាច្រើននៃកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីផ្ទុញជាមួយនឹងសាក្សីនេះ។ គឺដោយយើងចោទសំណួរបើកគឺថា ដើម្បីចង់ឲ្យសាក្សីនេះផ្តល់ប្រតិកម្មរបស់គាត់ហៅថា តើគាត់យល់យ៉ាងណាដែរចំពោះពីចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់មកកន្លងមកនេះ មិនមែនជាសំណួរនាំមុខទេលោកប្រធាន។ គ្រាន់តែចង់បង្ហាញថា សាក្សីនេះគាត់មិនបានដឹងពីគោលនយោបាយនោះទេ កាលពីសម័យនោះនោះ ព្រោះចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ វាខុសពីហ្នឹង។ អ៊ីចឹងហើយ យើងនៅទីនេះដើម្បីឲ្យតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងធ្វើយ៉ាងដើម្បីគេឲ្យស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ អ៊ីចឹង យើងគួរតែត្រូវបានអនុញ្ញាតក្នុងការដកស្រង់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អ៊ីចឹង បើសិនជាតុលាការយល់ឃើញថារបៀបសួររបស់យើងនេះ មិនសមស្របនោះអ៊ីចឹងខ្ញុំត្រូវការបំភ្លឺពីតុលាការ ពីព្រោះថាកាលណា តុលាការធ្វើការបំភ្លឺហើយ យើងអាចកែតម្រូវរបៀបសួររបស់យើងបាន លោកប្រធាន។

[១៣:៣៥:៥០]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកស្រីមេធាវី យើងអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ហើយដូចដែលលោកដឹងហើយ កាលពីយប់មិញ ខ្ញុំបានជម្រាបហើយ ប៉ុន្តែវាមិនមែនជាបញ្ហានៃភាពអាចទទួលយកបាន ឬមិនទទួលយកបាននៃកំណត់ត្រានោះឡើយ។ ខ្ញុំគិតថា ការជំទាស់របស់មេធាវីការពារក្តី គឺ

ទាក់ទងទៅនឹងហេតុការណ៍ដែលដើមបណ្តឹងរដ្ឋប្បវេណីបានពាក់ព័ន្ធ ហើយនិងការយល់ -- ហើយនិងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់។ ហេតុដូច្នេះហើយ មេធាវីការពារ -- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគួរតែផ្តល់ព័ត៌មានលម្អិតបន្ថែមអំពីហេតុការណ៍ ក៏ដូចជាទីកន្លែងអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនោះ។ ហេតុដូច្នេះហើយ ទើបយើងអនុញ្ញាតឲ្យមានការសួរបែបនេះឡើងវិញ។

**លោក វ៉ែន ពៅ៖**

សូមអរគុណឯកឧត្តមប្រធាន។ អ៊ីចឹងខ្ញុំសូមប្តូរប្រធានបទសួរវិញ ដោយសារខ្ញុំត្រៀមសំណួរនេះ ដល់ពេលឥឡូវមិនត្រូវបានអនុញ្ញាត ខ្ញុំសូមដូរសំណួរវិញ។ ខ្ញុំមានសំណួរតែពីរទេ ដែលទុកពេលវេលាឲ្យសហព្រះរាជអាជ្ញាបានសួរឲ្យបានវែង។

[១៣:៣៧:០៨]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** លោកសាក្សី ពីព្រឹកមិញ លោកបានបញ្ជាក់ថា លោកធ្លាប់បានចូលរួមប្រចាំឆ្នាំជាមួយនឹងតាម៉ុក ហើយនៅពេលនោះ តាម៉ុក បានប្រាប់ក្រុមចូលរួមប្រជុំរបស់លោកនោះថា បញ្ហាអាយុជីវិតរបស់មនុស្សចាប់ពីថ្នាក់ អ្នកដែលមានឋានៈត្រឹមភូមិ ឃុំ ស្រុក ពុំមានសិទ្ធិសម្រេចពីបញ្ហានេះទេ គឺមានតែគណៈភូមិភាគ ឬក៏មជ្ឈិមបក្ស បានមានសិទ្ធិវិនិច្ឆ័យលើបញ្ហានេះ។ សំណួររបស់ខ្ញុំចង់សួរលោកថាតើក្នុងករណីដែលមានសេចក្តីសម្រេចពីភូមិភាគ ឬក៏មជ្ឈិមបក្សឲ្យថ្នាក់ក្រោមរបស់លោក ធ្វើការបញ្ហាពាក់ព័ន្ធនឹងអាយុជីវិត ឬក៏បញ្ហាឲ្យមានការសម្លាប់មនុស្សជាដើមនោះ ថាតើលោកមានសិទ្ធិប្រឆាំងទេបាទ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ ខ្ញុំសូមធ្វើការឆ្លើយ--

**លោក គង់ សំអុន៖**

សូមជំទាស់។ ទាក់ទងទៅនឹងសំណួរចុងក្រោយរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាប្រភេទសំណួរមួយ ជាឧបមាវិធី មិនមានភាពច្បាស់លាស់ ព្រោះអត់មានភាពជាក់ស្តែងទេ។ បើសិនជាចង់សួរសាក្សីទាក់ទងបញ្ហានេះ គួរតែលើកអង្គហេតុជាក់លាក់ណាមួយ ទាក់ទងទៅនឹងបទបញ្ហា។ បាទ សូមអរគុណ។

[១៣:៣៨:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវីបន្ត។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សំណួរមួយទៀត កាលពីព្រឹកមិញនេះដែរ លោកបានឆ្លើយផងដែរ បន្ទាប់ពីជ័យជម្នះបីខែមក មានការប្រជុំនៅអង្គរជ័យ តំបន់ ស្រុក១០៦ នៅភ្នំត្រែល ឬភ្នំត្រៀលទេបាទ។ ហើយលោកបានបញ្ជាក់ថា តាសោម បានប្រាប់មកលោកថា ចំពោះអតីតទាហានលន់ នល់ ចាប់ពីស័ក្តិ១ ដល់ស័ក្តិ៥ទៅ មិនត្រូវឱ្យធ្វើការប៉ះពាល់ទេ។ សំណួរខ្ញុំចង់សួរលោកថា តើលោកដឹងពីមូលហេតុអី បានជាតាសោម គាត់ណែនាំបែបនេះ ដោយសារមានការប៉ះពាល់ក្នុងរយៈពេលបីខែមកហើយ មានបទ-ពិសោធន៍បែបហ្នឹង បានគាត់ណែនាំ ឬក៏យ៉ាងម៉េចបាទ?

**លោក សៅ វ៉ន៖**

**ឆ៖** សូមឆ្លើយ អ្វីដែលខ្ញុំឆ្លើយនេះ គឺបងសោម មិនប្រាប់តែម្នាក់ទេ មិនប្រាប់តែខ្ញុំម្នាក់ទេ សូមជម្រាប មេធាវីឱ្យបានច្បាស់។ គឺរៀន មនុស្សរាប់រយ គ្រប់ៗឋានៈទាំងអស់ សូមលោកជ្រាប។ អ៊ីចឹង ដូចខ្ញុំពីព្រឹកមិញបានលម្អិតហើយ ថារាល់ការជម្លៀសមកនេះ មកពីទីក្រុងភ្នំពេញ សភាពពេលនោះកំពុងតែច្របូកច្របល់។ អ៊ីចឹងអ្នកនៅជនបទ និងតំបន់រំដោះសូមលោកជ្រាប មានបងមានប្អូនគេជួយឧបត្ថម្ភបដិវត្តន៍ តែក៏គេមានកូនគេ ឬប្អូនគេ ឬក្មួយគេនៅខាងក្នុង អ៊ីចឹងហើយទស្សនៈនិងស្មារតីរបស់រណសិរ្សរួបរួមជនជាតិកម្ពុជាពេលនោះ និងអ្នកដឹកនាំពេលនោះ យល់ឃើញថា ដើម្បីសន្តិភាព ដើម្បីបញ្ចប់ជម្លោះ ត្រូវតែអនុគ្រោះរាល់ឋានៈតួនាទីអ្វីទាំងអស់ សូមកុំឱ្យកើតមាន។ នេះការយល់របស់ខ្ញុំ ហើយខ្ញុំទទួលយកបាន ដែលខ្ញុំចងចាំមកទល់ថ្ងៃនេះ។ បាទ សូមលោកមេធាវីជ្រាប។

[១៣:៤១:៤២]

**លោក វ៉ែន ពៅ៖**

បាទ ខ្ញុំៗអស់សំណួរហើយឯកឧត្តមប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

ជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី។

**ស៖** ជម្រាបសួរលោកសាក្សី! លោកសាក្សីតើពិតទេ ដែលថាលោកបម្រើរបបខ្មែរក្រហម

ដោយស្មោះស្ម័គ្រនៅពេញមួយរយៈកាលនៃរបបនោះតែម្តង?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ ខ្ញុំឆ្លើយ សូមឆ្លើយ ខ្ញុំបម្រើដោយស្មោះស្ម័គ្រពីព្រោះគោលនយោបាយទាំងអស់នោះ គឺលើកឡើងពីការកសាងប្រទេស ការពារប្រទេស ហើយនិងកសាងសហករណ៍ដើម្បីបំប៉ន ជីវភាព និង សុខភាពរបស់ប្រជាជនក្នុងឃុំទាំងមូលបាទ។ សូមអស់យោបល់។

**ស៖** ហើយលោកសាក្សីតួនាទីសំខាន់ៗដែលលោកបានទទួលពេលនោះ ដូចជាលោកធ្វើជាមេ ឃុំ លោកស្ថិតនៅក្រោមសិទ្ធិអំណាចនៃការត្រួតត្រារបស់ តាម៉ុក។ តើត្រឹមត្រូវដែរឬទេ?

[១៣:៤២:៥០]

**ឆ៖** ខ្ញុំសូមធ្វើការបញ្ជាក់ ជម្រាបជូនឆ្លើយតបនឹងសំណួររបស់លោក។ ខ្ញុំធ្វើពេលនោះជាទូទៅ មួយពេញផ្ទៃប្រទេសកម្ពុជា គឺរណសិរ្សរួបរួមជាតិកម្ពុជា ដូចនេះខ្ញុំអត់ទាន់ស្គាល់តាម៉ុកទេ ខ្ញុំស្គាល់ត្រឹម តែក្របខ័ណ្ឌស្រុក ហើយនិងខេត្ត មានតាសោម តាមុត តាផែង ហើយមកស្រុកមាន យាយខុន តាគាវ និងតាញ៉ៅ ដែលចូលចុះមករៀបចំ ឲ្យខ្ញុំពង្រឹងនិងធ្វើចលនាសុំអង្ករ សុំបន្លែបង្កា បម្រើសមរភូមិ។ សូម លោកមេធាវីជ្រាប។

**ស៖** លោកសាក្សី លោកថាលោកពេញចិត្តនឹងឆ្លើយនឹងសំណួររបស់ខ្ញុំ។ តើពិតទេដែលថា លោកស្ម័គ្រស្មោះបម្រើរបបខ្មែរក្រហមពេញមួយរបបនោះតែម្តង គឺ ១៧មេសា ៧៥ ដល់ ០៦ មករា ៧៩ ដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ តាម៉ុក តែប៉ុណ្ណោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាសួរឲ្យបានច្បាស់លាស់ ជាក់លាក់ ពីព្រោះថារបបកម្ពុជាប្រជាធិប តេយ្យមិនទាន់មានទេ រហូតដល់ខែមីនា ឆ្នាំ១៩៧៦ ទើបមានរបបកម្ពុជាប្រជាធិបតេយ្យ មុននោះគឺថា មានរណសិរ្ស រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាតែប៉ុណ្ណោះ។

**លោក នីកូឡាស គូមជែន៖**

អរគុណ--

[១៣:៤៤:៣៥]

**លោក គង់ សំអុន៖**

ខ្ញុំសូមជំទាស់បន្ថែមទៅលើការតាំងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ ដែលខ្ញុំពិនិត្យ

មើលទៅឃើញថា សំណួរជាទូទៅ ជាសំណួរនាំមុខ ហើយមិនបានផ្តល់ឱកាសឲ្យសាក្សីបញ្ចេញនូវការយល់ដឹងជាលក្ខណ:បទពិសោធន៍ផ្ទាល់របស់ខ្លួនទេ គឺគាត់បានតម្រង់ផ្លូវមួយដើម្បីឲ្យសាក្សីឆ្លើយ។ ដូច្នេះខ្ញុំសូមជំទាស់ការតាំងសំណួរប្រភេទនេះ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះលោកមេធាវី សំណួរដែលសហព្រះរាជអាជ្ញាអន្តរជាតិសួរអម្បាញ់មិញនេះ គឺខ្ញុំពិនិត្យទៅឃើញថាមិនមែនជាសំណួរនាំមុខទេ។ គ្រាន់តែជាសំណួររួមមួយដែលលោកសួរជាទូទៅគឺពីឆ្នាំ៧៩ ដល់ -- ឆ្នាំ៧៥ ដល់ឆ្នាំ ៧៩។ អ៊ីចឹងសូមព្រះរាជអាជ្ញាបន្តទៅទៀតបាទ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំនិយាយអំពី រយ:ពេលពី ១៧ មេសា ៧៥ រហូតដល់ ០៦ មករា ១៩៧៩ គឺពេញមួយរបបខ្មែរក្រហមតែម្តង។ ក្នុងរបបខ្មែរក្រហម តើលោកស្ថិត -- លោកបម្រើការងារទាំងនោះដោយស្ថិតនៅក្រោមការត្រួតត្រារបស់ តាម៉ុក ឬស្ថិតនៅក្រោមការត្រួតត្រារបស់មេភូមិភាគផ្សេង?

[១៣:៤៥:៥៧]

**លោក សៅ វ៉ន៖**

**ឆ៖** ខ្ញុំសូមធ្វើការឆ្លើយជម្រាបលោកម្ចាស់សំណួរ។ ពី ៧៦ ទៅ ៧៩ ខ្ញុំធ្វើក្រោមការដឹកនាំរបស់គណបក្សកម្ពុជាប្រជាធិបតេយ្យ បក្សកុម្មុយនិស្តកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំមិនអាចឆ្លើយថាខ្ញុំធ្វើក្រោមគណ: -- ក្រោមលោកគណ:ភូមិភាគនេះ ឬភូមិភាគនោះទេ ពីព្រោះពេលនោះខ្ញុំធ្វើដើម្បីរស់នៅសម្រាប់ខ្លួនខ្ញុំផងហ្នឹងម្យ៉ាង។ តែម៉្យាងខ្ញុំយល់ថាពាក្យ "គណ:" អត់មានបុគ្គលទេ គឺមានពី ៣ទៅ៥ ទៅ៧ ទៅ១១។ អ៊ីចឹងគណ:បានន័យថា "ពហុ"១មតិ។ បើអ៊ីចឹងមានឯកសារ។ អ៊ីចឹងខ្ញុំធ្វើទៅតាមហ្នឹងបានជាខ្ញុំបានសុខ មកដល់ថ្ងៃនេះ ចំពោះខ្ញុំម្នាក់។

**ស៖** លោកសាក្សី ខ្ញុំសូមទោសដែលខ្ញុំកាត់ផ្តាច់លោក។ លោកមិនទាន់ឆ្លើយមកសំណួររបស់ខ្ញុំ ហើយលោកឆ្លើយវែងឆ្ងាយ។ ព្រឹកមិញនេះ គឺថាលោកប្រាប់ថា លោកធ្វើការនៅភូមិភាគនិរតីនៅពេញមួយរយ:ពេលនៃរបបខ្មែរក្រហម។ នៅក្នុងតំបន់ដែល តាម៉ុក ត្រួតត្រា តាំងពីពេលនៅត្រាំកក់ រហូតមកដល់ពេលដែលគេបញ្ជូនមកស្រុកកៀនស្វាយ នៅក្នុងតំបន់២៥។ តើវាពិតមែន ឬក៏អត់ទេ?

**ឆ៖** សូមជម្រាបលោកមេធាវី ពិតមែន បាទ។

[១៣:៤៧:៥២]

**ស៖** សូមអរគុណ។ ពេលខ្លះលោកប្តូរឈ្មោះរបស់លោក លោកសាក្សី។ តើៗលោកមានបានប្តូរឈ្មោះរបស់លោកទេ?

**ឆ៖** សូមជម្រាប ខ្ញុំប្តូរ។ មូលហេតុដែលខ្ញុំប្តូរ ម្តាយខ្ញុំដាក់ឈ្មោះ សៅ វ៉ន ដល់ពេលកើតមក។ តែឪពុកខ្ញុំ គាត់ទៅចុះបញ្ជីជាតិ ទៅចុះបញ្ជីជាតិខ្ញុំដាក់កំណើតខ្ញុំ សៅ ពត។ ដល់តែពេលខ្ញុំឈរឈ្មោះក្នុងគណបក្ស សម រង្ស៊ី ពីឆ្នាំ២០០២នេះ គឺខ្ញុំដាក់ សៅ ពត តែពេលនោះមិនទាន់មានចុះអត្តសញ្ញាណប័ណ្ណ។ ដល់តែពេលធ្វើអត្តសញ្ញាណប័ណ្ណទៅ ខ្ញុំក៏ធ្វើ -- ក៏ចុះ សៅ វ៉ន។ អ៊ីចឹងសូមជម្រាបលោកមេធាវី ខ្ញុំមិនគេចវេះទេ ឈ្មោះនេះខ្ញុំដាក់ឈ្មោះទាំងពីរដើម្បីកុំឲ្យគេភ្លេច ពីព្រោះខ្ញុំគេធ្លាប់ស្គាល់ សៅ ពត ផង ហើយទាំងពីរៀនសូត្រ ហើយនៅ ៧៩ នេះ ទៅស្រុកវិញដាក់ឈ្មោះ សៅ វ៉ន។ បាទ សូមអស់យោបល់។

**ស៖** តើលោកសាក្សីជ្រើសរើសប្រើឈ្មោះ ពត នៅពេលដែលលោកត្រូវការប្រើឈ្មោះជាផ្លូវការ លោកជាអ្នកសម្រេចជ្រើសរើសឈ្មោះ ពត នេះឬ?

**ឆ៖** ខ្ញុំសូមឆ្លើយ ឈ្មោះជាផ្លូវការបច្ចុប្បន្ន ខ្ញុំប្រើឈ្មោះ សៅ វ៉ន បាទ ដើម្បីបំពេញបំណងទឹកមាត់ម្តាយខ្ញុំដែលគាត់ខំបង្កើតខ្ញុំ ហើយគាត់ស្រឡាញ់ឈ្មោះហ្នឹង។ អ៊ីចឹងខ្ញុំសុំដាក់ សៅ វ៉ន ប្រើជាផ្លូវការតទៅបាទ។

[១៣:៤៩:៤៤]

**ស៖** លោកសាក្សី ខ្ញុំសូមបន្តទៅមុខទៀត ប៉ុន្តែខ្ញុំសួរសំណួរដែលខ្ញុំបានសួរ ហើយដែលលោកឆ្លើយមិនទាន់បានពេញលេញ។ លោកនិយាយអំពីថា -- និយាយអំពីមូលហេតុដែលរស់រានមានជីវិតបានពីរបបខ្មែរក្រហម។ ក្នុងរបបខ្មែរក្រហមលោកភ័យខ្លាចទេ?

**ឆ៖** សូមឆ្លើយ សូមធ្វើការជម្រាប ព្រោះថាខ្ញុំខ្លាចហើយបានជាខ្ញុំរស់ដល់ថ្ងៃនេះ។ មួយវិនាទីស្លាប់ មួយវិនាទីរស់ ណាជីវភាពប្រចាំថ្ងៃ ណាគ្រាប់រំសេវ កាំភ្លើងតូចធំ ទ័ពទឹង ទម្លាក់យប់ឡើង សូមជម្រាបលោកចុះ ចម្លើយខ្ញុំហ្នឹងហាក់ដូចជាវែងបន្តិច។ យប់ឡើង គឺចក្រពត្តិអាមេរិកទម្លាក់ភ្លើងគោមធ្វើឲ្យរងាខ្លាច--

**ស៖** លោកសាក្សី ខ្ញុំត្រូវតែបញ្ឈប់លោក ដោយសារខ្ញុំសួរសំណួរ គ្រាន់តែសួរថា ក្នុងរបបខ្មែរក្រហម គឺយើងកំណត់ថាពីថ្ងៃ១៧ មេសា ៧៥ ដល់ ០៦ មករា ១៩៧៩។ ពេញមួយអំឡុងពេលនេះ ខ្ញុំសួរថាតើលោកអាចរស់រានមានជីវិតបានដោយរបៀបណា? លោកមានការភ័យខ្លាចដែរនៅក្នុងរបបនោះ?

**ឆ៖** បាទ សូមឆ្លើយ គឺខ្ញុំរស់នៅក្នុងឋានៈជាអ្នកខ្លាច ជាអ្នកព្រួយ ជាអ្នកបារម្ភប្រចាំថ្ងៃ បាទ ដើម្បីជីវិតរស់នៅ។ សូមអស់យោបល់។

**សៈ** លោកសាក្សី លោកបែរមកថៅក្រុម ប៉ុន្តែនៅខាងក្រោយលោកមានសាធារណជនជាច្រើន តើ -- ខ្ញុំសួរថាតើនៅក្នុងរបបខ្មែរក្រហមនោះ ខ្មែរក្រហមមានសម្លាប់មនុស្សទេ?

[១៣:៥១:៥៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរបែបនេះ។ លោកប្រធាន សាក្សីនេះកំពុងតែឆ្លើយជូនអង្គជំនុំជម្រះតុលាការកំពូល ដូច្នេះមិនបាច់លើកយកបញ្ហាសាធារណជនអី យកមកសំអាងអីនោះទេ។

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំសូមបន្ថែមការជំទាស់។ ដោយសហព្រះរាជអាជ្ញាបានលើកអំពីអំពើរបស់ខ្មែរក្រហមថាជាអ្នកសម្លាប់ប្រជាជន ក៏ប៉ុន្តែនៅទីនេះ គឺមិនបានចោទប្រកាន់ខ្មែរក្រហមទេ គឺមានកូនក្តីរបស់ខ្ញុំ ខៀវ សំផន ដែលត្រូវបានចោទប្រកាន់។ អ៊ីចឹងសូមលើក គឺលើកឲ្យចំបញ្ហា កាលណានិយាយពីខ្មែរក្រហមអ៊ីចឹង យើងមិនដឹងថានិយាយអំពីអ្វីទេ បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ការជំទាស់នេះ គឺវាមិនមានភាពពាក់ព័ន្ធទេ ដោយសារសំណួររបស់សហព្រះរាជអាជ្ញា គឺសំដៅទៅលើការសម្លាប់។ មានរបបហ្នឹង មានការសម្លាប់ដែរឬទេ? ដូច្នេះ គឺសូមឲ្យលោកព្រះរាជអាជ្ញាធ្វើសំណួរបន្ថែម -- បន្តបាទ។ សូមអញ្ជើញ!

[១៣:៥៣:១៣]

**សួរដោយលោក នីកូឡាស គូមជែន៖**

**សៈ** លោកសាក្សី តើខ្មែរក្រហមមានសម្លាប់មនុស្សដែរនៅក្នុងរបបនោះ?

**លោក សៅ វ៉ន៖**

**ឆ៖** ខ្ញុំបាទសូមធ្វើការឆ្លើយចំពោះសំណួរនេះ។ ខ្ញុំមិនអាចដឹងថា ខ្មែរក្រហមសម្លាប់ទេបាទ។ សូមអត់ -- ខ្ញុំអត់ដឹងបាទ សូមឆ្លើយ។ សូមអស់យោបល់។

**សៈ** លោកសាក្សី លោកមកពីស្រុកត្រាំកក់ ក្នុងខេត្តតាកែវ លោកធ្លាប់ទៅក្រាំងតាចាន់ដែរ?

**ឆ៖** សូមឆ្លើយ ខ្ញុំធ្លាប់ទៅក្រាំងតាចាន់ ប៉ុន្តែខ្ញុំបានឃើញនៅដណ្តង់(?) ទាំងអស់នោះ។ ក្នុងន័យ

នេះ គឺខ្ញុំសូមជម្រាបថា ខ្ញុំឃើញទទួលស្គាល់នូវលលាដ៍ ព្រះកេសគេទាំងឡាយដែលមាននៅក្នុងនោះ។ ប៉ុន្តែក្នុងរយៈកាលពី៧០-៧៥, ៧៥ ទល់ ៧៩ ខ្ញុំអត់បានដឹងទាំងអស់ ព្រោះខ្ញុំគ្មានតួនាទី។ តួនាទីត្រឹមតែការងារនៅមូលដ្ឋាន ការងារគេ គេដឹង ការងារខ្ញុំ ខ្ញុំដឹងបាទ។ សូមអស់យោបល់។

**ស៖** សូមអរគុណលោកសាក្សី។ តើអង្គជំនុំជម្រះគួរត្រូវតែដឹងពីលោកថា មានអ្វីកើតឡើងទេរបបខ្មែរក្រហម លើកលែងតែឃុំរបស់លោក គឺលោកដឹងតែនៅក្នុងឃុំរបស់លោកទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[១៣:៥៥:០៨]

**ស៖** លោកសាក្សី លោកដឹងថាមានប្រជាជនណានៅក្នុងឃុំរបស់លោកនោះ បាត់បង់សមាជិកគ្រួសាររបស់គេទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំមិនបានដឹងទាំងអស់ទេ តែក៏ខ្ញុំមិនបដិសេធដែរ មានបាត់ តែការបាត់នេះបាត់បង់ដោយស្លាប់ក្នុងសង្គ្រាម បាញ់ទៅបាញ់មក ហើយក៏ក្រោយពីថ្ងៃ១៧ មិន -- មានបាត់ក៏ខ្ញុំមិនដឹងថា គ្រួសារណាបាត់ អ្នកណាៗដែរ អត់ទេ។ ខ្ញុំអត់បានដឹងទេ។ រហូតទៅដល់ថ្ងៃ០៩ -- ៧៩ ដែលកងទ័ពវៀតណាមបុកចូលមក រត់បាត់បង់នូវតំបន់ភ្នំវាលរាប បឹងបូអី ក៏ខ្ញុំអត់ដឹងដែរ។ ដូច្នេះ ខ្ញុំសូមឆ្លើយជម្រាបថា ខ្ញុំមិនបានដឹង បាទ មិនបានដឹងមានប៉ុន្មានៗនោះទេ បាទ សូមអស់យោបល់។

**ស៖** សូមអរគុណ។ ខ្ញុំគ្រាន់តែសួរដើម្បីឲ្យខ្ញុំស្តាប់ចម្លើយលោកឲ្យបានច្បាស់លាស់។ លោកដឹងអំពីប្រជាជនស្លាប់ដោយសង្គ្រាមមុនឆ្នាំ១៩៧៥ និងលោកបានដឹងថាមានប្រជាជនស្លាប់ក្រោយរបប -- ក្រោយថ្ងៃ០៦ មករា ៧៩ហើយ ប៉ុន្តែនៅក្នុងរបបខ្មែរក្រហម លោកថាលោកមិនបានដឹងថាមានមនុស្សស្លាប់ទេ។ តើអ៊ីចឹងមែនទេ?

**លោក អាកឡូ វែកគែន៖**

លោកប្រធាន ខ្ញុំសូមជំទាស់។ លោកសហព្រះរាជអាជ្ញា គឺបានបំប្លែងនូវសម្តីរបស់សាក្សី ដែលគាត់បានឆ្លើយអម្បាញ់មិញនេះ។ ដើម្បីផលប្រយោជន៍របស់គាត់ យើងមិនអាចសន្និដ្ឋានថាគាត់មិនអាចយល់ចម្លើយរបស់សាក្សីទេ ហើយគាត់សង្ខេបចម្លើយរបស់សាក្សីហ្នឹង គឺមិនត្រូវទេ។ ដូច្នេះ ខ្ញុំសូមឲ្យសួរឡើងវិញ ពីព្រោះថាវាមិនពាក់ព័ន្ធទៅនឹងចម្លើយដែលសាក្សីឆ្លើយអម្បាញ់មិញនេះទេ គឺសហព្រះរាជអាជ្ញាកំពុងតែបង្កើតនូវការអំណះអំណាងថ្មីរបស់ -- សាកសមហើយ តាមការពិតនោះ គាត់មិនបានឆ្លើយអ៊ីចឹងទេ។

[១៣:៥៧:៣៧]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកប្រធាន។ យើងដឹងថា សហព្រះរាជអាជ្ញា គឺមិនបានសង្ខេបឡើងវិញនូវចម្លើយដែលបានឆ្លើយទៅមេធាវីការពារក្តីទេ ប៉ុន្តែយើងបានស្តាប់ឮថា សាក្សីបាននិយាយថា គាត់ដឹងថាប្រជាជនស្លាប់នៅពេលទម្លាក់គ្រាប់បែក ប្រជាជនបាត់ខ្លួនក្នុងរបបខ្មែរក្រហម ហើយនិងដឹងថាប្រជាជនមានការបាត់ខ្លួន និងស្លាប់ក្រោយឆ្នាំ១៩៧៩។ ដូច្នេះ យើងខ្ញុំយល់ឃើញថា យើងមិនចាំបាច់សង្ខេបនូវចម្លើយរបស់សាក្សីឡើងវិញនោះទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី លោកថា មានមនុស្សបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម។ ពាក្យថាបាត់ខ្លួននេះបាត់ជារៀងរហូតឬ?

**លោក សៅ វ៉ន៖**

**ឆ៖** សូមឆ្លើយ ត្រង់បាត់រៀងរហូត ឬមិនរៀងរហូត ក៏ខ្ញុំមិនអាចដឹងបានទេ ពីព្រោះតួនាទីរបស់ខ្ញុំ សូមជម្រាបលោកឲ្យបានជ្រាបថា ក្រោយពីខ្ញុំអស់តួនាទីទៅ ខ្ញុំក៏ស្ថិតក្នុងឋានៈជាអ្នកចាញ់រោគសង្គ្រាមនៅតាមភូមិឃុំ។ ដូច្នេះ ខ្ញុំគ្មានសិទ្ធិសួរសាកអ្នកនេះ អ្នកនោះ គ្រួសារនេះបាត់ អ្នកនេះបាត់ អ្នកនោះ ខ្ញុំអត់ទេ។ បាទ សូមជម្រាបចំពោះលោកអ្នកម្ចាស់សំណួរ។

**ស៖** ដូច្នេះ លោកមិនដឹងថាមានគេសម្លាប់មនុស្សទេ លោកមិនដែលធ្លាប់ឮថាមានគេសម្លាប់មនុស្សទេឬ នៅក្នុងរបបខ្មែរក្រហម?

[១៣:៥៩:៣៩]

**ឆ៖** បាទសូមឆ្លើយ។ គ្រប់កិច្ចការ ខ្ញុំឆ្លើយអត់បានឮ អត់ទេ ព្រោះគេសម្លាប់ក៏ខ្ញុំអត់ដឹង ពីព្រោះខ្ញុំក៏អត់បានសាកសួរគេ អត់ទេ ពីព្រោះការសម្លាប់ ឬ-- ខ្ញុំបដិសេធតែម្តង ខ្ញុំអត់ដឹង បាទ។ សូមលោកមេធាវី មិនបាច់សួរខ្ញុំត្រង់ហ្នឹងទៀតទេបាទ។ ខ្ញុំសូមឆ្លើយជាឱឡារិកក្នុងឋានៈខ្ញុំម្នាក់ គឺខ្ញុំអត់ដឹង។

**ស៖** ខ្ញុំសូមទោស ក៏ប៉ុន្តែខ្ញុំសួរលោកបន្ថែមទៀតទៅលើប្រធានបទហ្នឹង ពីព្រោះវាជាប្រធានបទសម្រាប់សំណុំរឿងមួយនេះ។ តើមានអ្វីកើតឡើងចំពោះកម្មាភិបាលដែលត្រឡប់មកពីហាណូយ គឺជនកុម្មុយនីស្តកម្ពុជាដែលបានត្រឡប់មកពីហាណូយវិញ ហើយគេត្រូវគេបញ្ជូនទៅភូមិភាគនិរតី។ តើ

មានអ្វីកើតឡើងចំពោះអ្នកទាំងនោះ?

**ឆ៖** ខ្ញុំសូមរីករាយនឹងឆ្លើយជម្រាប ដូចខ្ញុំបានជ្រាបថា ពេលនោះ ខ្ញុំនៅក្នុងឋានៈជាកូនសិស្ស ឆ្នាំ ៧១, ៧០ ខ្ញុំមានគ្រួសារហើយ ខ្ញុំអាយុ២៩ឆ្នាំ។ អ៊ីចឹង ដល់តែខ្ញុំចូលបម្រើការងារក្នុងបដិវត្តន៍ ខ្ញុំអត់ដឹងថាអ្នកណាមកពីហាណូយ អ្នកណានៅក្នុងប្រទេសទេបាទ អត់ដឹង អត់យល់អីទាំងអស់ បាទ។ មិនដឹងអ្នកណាមកពីហាណូយ អ្នកណាមកពីណាទេ អត់ទេ។

**ស៖** ខ្ញុំចង់ឲ្យច្បាស់ថា ខ្ញុំយល់ចម្លើយរបស់លោកគឺមានន័យថា លោកមិនដែលបានដឹងថា មានកម្មាភិបាលកម្ពុជាត្រឡប់មកពីវៀតណាម ហើយត្រូវគេបញ្ជូនទៅភូមិភាគនិរតី ហើយបាត់ខ្លួន គឺថាលោកមិនបានដឹងទេ។ លោកឆ្លើយថាអ៊ីចឹងមែនទេ?

[១៤:០១:៤៤]

**ឆ៖** ខ្ញុំឆ្លើយថាអ៊ីចឹងបាទ។ ប៉ុន្តែការដែលចម្លើយរបស់ខ្ញុំនេះ លោកអនុញ្ញាតឲ្យខ្ញុំអង្គុយនឹកបន្តិចបានទេ ដើម្បីឆ្លើយ ក្រែងថាខ្ញុំភ្លេចភ្លាំង ព្រោះខ្ញុំចូលមកកន្លែងនេះ គឺ -- ហើយចំណាស់ខ្ញុំ ក៏វាមានការភ្លេចភ្លាំងដែរ។ ស្អែកខ្ញុំឆ្លើយបន្តបានទេ ពេលនោះ ខ្ញុំឃើញអ្នកដែលដើរធ្វើការជាមួយនឹង តាញ៉េវ តាគាវ មាន--

**ស៖** បាទ សូមអញ្ជើញបន្តទៅទៀតលោកសាក្សី។

**ឆ៖** បាទ ខ្ញុំឃើញមានមួយ ឈ្មោះ តាជា បាទ។ តាជា ហ្នឹង ខ្ញុំសួរគេទៅ ថាគាត់មកពីហាណូយ បាទ នៅក្នុងស្រុក។ ហើយមួយទៀត ឈ្មោះ តាណន មានពីររូបហ្នឹងដែលគាត់មានកំណើតកើតជានៅភូមិត្រពាំងធំខាងត្បូង ហើយមានមួយនៅឃុំសំរោង។ បាទ ខ្ញុំនឹកឃើញហើយ ពីរហ្នឹង។ សូមអស់យោបល់។

**ស៖** តើអ្នកទាំងពីរនេះ ត្រូវបានខ្មែរក្រហមសម្លាប់ចោលមែនទេ?

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សាក្សីបាននិយាយថា គាត់មិនបានដឹងអំពីការសម្លាប់មនុស្សទេ ដូចនេះមិនបាច់ជជីកកន្លែងនេះទេ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមបន្តទៅមុខទៀត។--

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ប្រសិនណាសាក្សីអាចដឹងថាមានអ្វីកើតឡើងចំពោះអ្នកទាំងនោះ គឺថា យើងក៏ចង់ដឹងនោះដែរ។

**លោក នីកូឡាស គូមជែន៖**

សំណួរខាងដើមនោះ សួរអំពីអំឡុងពេលដែលស្ថិតនៅខាងក្រៅវិសាលភាពនៃការជំនុំជម្រះនេះ គឺមុនឆ្នាំ១៩៧៥។

**លោក វ៉ិចទ័រ កូប៉េ៖**

សហព្រះរាជអាជ្ញាអាចសួរសំណួរនេះបាន ក៏ប៉ុន្តែយើងមិនគួរណាពាក់ព័ន្ធទៅបញ្ហានេះទេ ដោយសារថា ពេលវេលានេះ គឺវាស្ថិតនៅក្រៅយុត្តាធិការពេលវេលា។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមទោស ដែលខ្ញុំសួរតែរឿង -- ខ្ញុំនឹងសួរតែបញ្ហាពាក់ព័ន្ធក្រោយឆ្នាំ១៩៧៥។

**សួរដោយ លោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី មូលហេតុអីបានជាលោកចូលបម្រើខ្មែរក្រហម?

**លោក សៅ វ៉ន៖**

**ឆ៖** ខ្ញុំសូមសួរ ដូចជាមិនទាន់យល់ពីសំណួរ សូមឲ្យលោកសួរម្តងទៀតបាទ។

[១៤:០៥:២១]

**លោក អាកឡូវ វ៉ែកកែន៖**

លោកប្រធាន ខ្ញុំសូមរំឭកថា ខ្មែរក្រហម គឺជាការហៅមួយដោយសម្តេច សីហនុ។ នេះមិនមែនជាការហៅផ្លូវការ ជាប្រវត្តិសាស្ត្រនៅក្នុងសំណុំរឿងយើងនេះទេ។ ដូច្នេះ គួរប្រើពាក្យពេចន៍ឲ្យត្រឹមត្រូវទៅតាមសម័យកាលនៃបញ្ហា នៃអង្គហេតុរបស់យើង។ ប្រសិនបើលោកសហព្រះរាជអាជ្ញានិយាយអំពីឆ្នាំ៧១ សូមឲ្យប្រើពាក្យពេចន៍ឲ្យត្រឹមត្រូវទៅតាមរយៈកាលនោះផង កុំឲ្យប្រើពាក្យជាលក្ខណៈទូទៅពេក។

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ខ្ញុំនិយាយអំពីខ្មែរក្រហម។ ខ្ញុំដឹងថាគេបានប្តូរឈ្មោះជាញឹកញាប់ ប៉ុន្តែអ្នកណាក៏ដឹងដែរនៅក្នុងបន្ទប់សវនាការនេះ កាលណាខ្ញុំប្រើពាក្យថា “ខ្មែរក្រហម” ហើយបើខ្ញុំប្រើថាកម្ពុជាប្រជាធិបតេយ្យ អ្នកខ្លះអត់យល់ទេ។ ខ្ញុំក៏អាចប្រើពាក្យបច្ចេកទេសពីពេលមួយទៅពេលមួយ

ដែរ ក៏ប៉ុន្តែម្នាក់ៗនៅក្នុងបន្ទប់សវនាការដឹងថា "ខ្មែរក្រហម" ពេលខ្លះគេហៅខ្លួនឯងថាជា "បក្សកុម្មុយនីស្តកម្ពុជា" ប៉ុន្តែពាក្យជាទូទៅគេប្រើពាក្យ "ខ្មែរក្រហម"។

**លោក វ៉ិចទ័រ កូប៉េ៖**

នៅក្នុងឆ្នាំ១៩៧១ ហៅថា "រណសិរ្ស" មិនមែនជាសមាជិកបក្សកុម្មុនីស្តកម្ពុជាទេ ហើយមកទៀតមកពីឆ្នាំ៧៥ គឺក៏បានបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមកបានកម្ពុជាប្រជាធិបតេយ្យហ្នឹងគឺថាត្រួតត្រាទាំងស្រុងតែម្តង។ ការប្រើពាក្យ "ខ្មែរក្រហម" ទូលំទូលាយបែបនេះក៏វាបានដែរ ក៏ប៉ុន្តែការប្រើពាក្យនេះគឺវាមិនចំលក្ខណៈរបស់វាទេ។

[១៤:០៦:១៦]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញា គឺសុំលោកប្រើពាក្យ សំខាន់គឺទាក់ទងបញ្ហាទី១ គឺលោកមេធាវីបានមានប្រសាសន៍អំមិញនេះគឺនៅចាប់ពី ១៧ មេសា ៧៥ មក យើងប្រើថា "កម្ពុជាប្រជាធិបតេយ្យ" ប៉ុន្តែពេលវេលាដែលទាក់ទងវិសាលភាពរបស់យើងនេះគឺត្រឹមឆ្នាំ៧៧ ទេ។ ដូច្នេះគឺអង្គហេតុ ឬក៏ចំណុចដែលលោកចង់សួរគឺទាក់ទងទៅនឹងវិសាលភាពនេះបាទ។ សូមអញ្ជើញ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី នៅពេលដែលលោកចូលរួមជាមួយនឹងចលនានេះ តើលោកអាចជម្រាបជូនតុលាការកំពូល តើពេលដែលលោកចូលរួមចលនាហ្នឹង គឺជាការចូលរួមមួយដោយលោកជួយទៅដល់សម្តេច សីហនុ ដែរឬក៏អត់ទេ?

**លោក សៅ វ៉ន៖**

**ឆ៖** សុំឆ្លើយ ពេលដែលខ្ញុំចូលរួមក្នុងពេលនោះ គឺទី១ ដោយចូលរួមស្រលាញ់សម្តេចសីហនុជាអ្នកដឹកនាំប្រទេស ហើយទី២ អស់ជម្រើស។ មានន័យថាអស់ជម្រើសយ៉ាងម៉េចនៅក្នុងតំបន់ហ្នឹងគឺរួមទាំងអស់ ចូលរួមក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ឯករាជ្យ អព្យាក្រឹត អធិបតេយ្យ សម្បូររុងរឿងមានជាតិ សាសនា ព្រះមហាក្សត្រ។ អ្វីដែលលោកលើកឡើងជជីកសួរខ្ញុំថា តើលោកដឹងខ្មែរក្រហមនេះសុំជម្រាប ពាក្យនោះ សុំបិទវង់ក្រចក គឺចាប់ពី៧១ ទល់ ៧៥ អត់មានប្រើពាក្យ "ខ្មែរក្រហម" ទេ។ ពីព្រោះប្រជាជនស្អប់ខ្មែរក្រហម ខ្ញុំដឹងថាស្អប់ ព្រោះគេអត់ទាន់យល់ពីស្មារតីខ្មែរក្រហម។ អ៊ីចឹងអ្នកណានិយាយឲ្យប៉ះពាល់ កម្មាភិបាលណានិយាយឲ្យប៉ះពាល់ គឺអ្នកនោះ អត់ទេ – បានន័យថា បំបែក

បំបាក់កម្លាំង។ ដូច្នេះ ពេលហ្នឹងមានក្របខ័ណ្ឌរណសិរ្សរួមកម្លាំងដើម្បីរំដោះប្រទេសជាតិ បាទ។ សុំអស់យោបល់។

[១៤:០៨:៣៣]

**ស៖** នៅពេលដែលលោកចូលរួមជាមួយនឹងចលនានោះ តើលោកយល់យ៉ាងណាដែរពាក់ព័ន្ធទៅនឹងបញ្ហា -- ពាក់ព័ន្ធទៅនឹងសាសនា?

**ឆ៖** សាសនា ការយល់របស់ខ្ញុំគឺ សាសនា សន្តិភាព បាទ ហើយសាសនា មិនលោភលន់ ខ្ញុំយល់តែប៉ុណ្ណឹង ហើយការពេលហ្នឹងគឺ ជាតិ សាសនា ព្រះមហាក្សត្រ ចូលរួមបាទ។

**ស៖** ខ្ញុំសុំសួរឱ្យច្បាស់ឡើងវិញ។ តើលោកយល់ដែរទេនៅពេលដែលលោកចូលរួមជាមួយនឹងចលនានោះ? នៅសំណួរមួយទៀតថា តើលោកជាពុទ្ធសាសនិកជន ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំសប្បាយនឹងចូលរួម ហើយខ្ញុំជាអ្នកកាន់សាសនាព្រះពុទ្ធ បាទ។ សុំទទួលជ្រាប។

**ស៖** នៅពេលដែលលោកចូលរួមជាមួយចលនា តើគេមានបានពន្យល់ប្រាប់លោក -- ខ្ញុំរៀបសំណួរឡើងវិញ។ តើបក្សកុម្មុយនីស្តកម្ពុជា រួមទាំងរបបកម្ពុជាប្រជាធិបតេយ្យ មានបានហាមឃាត់មិនឱ្យគេគោរពសាសនាព្រះពុទ្ធទេ?

[១៤:១០:០០]

**ឆ៖** បាទ សូមឆ្លើយ បក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យអត់មានហាមទេ បាទ អត់មានហាមថាមិនឱ្យឱ្យគោរពសាសនាព្រះពុទ្ធទេ។

**ស៖** ចុះលោកមាន -- លោកមានបានគោរពព្រះពុទ្ធសាសនាទេ លោកខ្លួនឯងនេះពីឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩ លោកខ្លួនឯងហ្នឹងមានបានគោរពប្រតិបត្តិព្រះពុទ្ធសាសនាទេ?

**ឆ៖** ពីឆ្នាំ១៩៧៥ ទល់៧៩ ខ្ញុំគោរពក្នុងឋានៈខ្ញុំ អាដែងកាន់ នូវអាដែងធម៌ប្រាំហ្នឹង គឺមិនប្រមាថកាតទានកូនប្រពន្ធគេ មិនជិះជាន់គេ ហើយមិន ព្រះពុទ្ធហាមមិនឱ្យផឹកស្រា មិនឱ្យលេងល្បែង ដូច្នេះ ខ្ញុំគោរព ក្នុងស្មារតីខ្ញុំបួស បួសកាយ -- អ៎! បួសចិត្ត ខ្ញុំអត់បានបួសកាយ ខ្ញុំបួសចិត្ត។ បាទ ដូច្នេះ ខ្ញុំសូមជម្រាបមេធាវីឱ្យអស់ចម្ងល់ថា ខ្ញុំគោរពសាសនាព្រះពុទ្ធ។

**ស៖** ចុះ--

**លោក អាកឡូរ វែកគែន៖**

បាទ ខ្ញុំសោកស្តាយ ដែលខ្ញុំបណ្តោយឱ្យសាក្សីនិយាយអម្បាញ់មិញនេះ ពីព្រោះខ្ញុំមិនចង់រាំង

ក៏ប៉ុន្តែ យើងកំពុងតែស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ទាំងស្រុងទៅហើយ។ ពិតណាស់ថា សហព្រះរាជអាជ្ញាគាត់បានប្រើប្រាស់ពេលវេលារបស់គាត់ សួរតាមដែលគាត់ចង់ ក៏ប៉ុន្តែសូមកុំភ្លេចថា គោលដៅរបស់យើងហ្នឹង គឺយ៉ាងម៉េច គឺលោកដឹងហើយ សូមកុំភ្លេចឱ្យសោះ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសង្ឃឹមថា តុលាការនឹងពិចារណាអំពីពេលវេលាដែលបានឡើងជំទាស់មកកាន់យើងខ្ញុំនេះ។

[១៤:១២:០៩]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នៅពេលដែលប្រជាជនមានវ័យដូចលោក ឋានៈដូចលោកចូលរួមចលនា ចូលរួមរណសិរ្សគឺថា គឺចូលរួមហ្នឹង គឺដោយសារដើម្បីវាយប្រយុទ្ធដណ្តើមអំណាចឱ្យសម្តេច នរោត្តម សីហនុ វិញ។ មនុស្សតិចតួចទេ ដែលគិតថាព្រះពុទ្ធសាសនា--

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកសហព្រះរាជអាជ្ញា គឺមិនឱ្យសាក្សីឆ្លើយស្មានៗចំពោះការយល់ឃើញរបស់អ្នកដទៃទៀតទេ។ សួរតែ លោកសួរតែចំពោះបទពិសោធន៍ផ្ទាល់របស់សាក្សីបានហើយ ពីព្រោះគាត់មានហេតុផលដែលគាត់ត្រូវជឿដោយខ្លួនឯង។ ដូច្នេះ បើសិនណាជាអាចធ្វើទៅបាន លោកសួរឱ្យចំៗចំណុចតែម្តង។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើមានគេនាំឱ្យលោកយល់ខុសដែរទេ នៅពេលដែលលោកចូលរួមជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា អំពីអ្វីដែលថាវាអាចនឹងកើតឡើងនោះ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមឆ្លើយ អត់មានអ្នកណានាំខ្ញុំទៅណាទេ បាទ។

**ស៖** លោកសាក្សី លោកបានឆ្លើយថាលោករស់រានមានជីវិតពីរបបនេះ ថាតើលោកដែលធ្លាប់បានទទួលបញ្ជាឱ្យចាប់ខ្លួនអ្នកណាម្នាក់ទេ?

**ឆ៖** បាទ អត់ទេ បាទ។

[១៤:១៣:៥៥]

**ស៖** តើលោកធ្លាប់បានទទួលបញ្ជាឱ្យសម្លាប់អ្នកណាម្នាក់ មិនមែនឱ្យលោកសម្លាប់ទេ គឺឱ្យអ្នកណាផ្សេងសម្លាប់ ប៉ុន្តែទទួលបញ្ជាឆ្លងកាត់តាមរយៈលោក។ ធ្លាប់ទេ?

**ឆ៖** បាទ អត់ទេ។ សូមឆ្លើយថា អត់ អត់ដែលមានទេ។

**ស៖** លោកសាក្សី នៅពេលទីក្រុងភ្នំពេញត្រូវបានដណ្ដើមបានដោយកងកម្លាំងខ្មែរក្រហម តើលោកមានការព្រួយបារម្ភអំពីក្រុមគ្រួសាររបស់លោកដែរឬទេ ដែលរស់នៅខាងរបបនេះ?

**ឆ៖** ជាទស្សនៈនិងសីលធម៌ គឺមានការបារម្ភ បាទ ព្រោះមានបងមួយក្រុងភ្នំពេញចេញទៅ។ ខ្ញុំបារម្ភ សូមជម្រាប។

**ស៖** លោកសាក្សី តើឪពុក និងម្ដាយរបស់លោកធ្វើអ្វីដែរ?

**ឆ៖** ឪពុកខ្ញុំជាអាចារ្យវត្ត ហើយម្ដាយខ្ញុំជាឧបាសិកាជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយពេលនុ៎ងគាត់ជាកសិករសាមញ្ញបាទ។

**ស៖** តើគ្រួសាររបស់លោកធ្វើស្រែចម្ការដែរឬទេ?

**ឆ៖** បាទ គ្រួសារខ្ញុំធ្វើស្រែចម្ការ អត់មានតួនាទីអីនឹងគេទេ អត់ទេ។

**ស៖** លោកបាននិយាយថា គេចាត់ទុកលោកថាលោកគឺជាអនុធន។ ហេតុអ្វីបានជាគេចាត់ទុកលោកនេះគឺជាពួកអនុធន?

**ឆ៖** បាទ ខ្ញុំសូមធ្វើការឆ្លើយ ពេលនោះ តារាងណែនាំអប់រំបាទ ក្នុងករណីគេថាប្រមូលកម្លាំងវណ្ណៈកសិករ កម្មករ សិស្ស និស្សិត អនុធន លក់ដូរ អនុធនសិស្ស អ្នកស្នេហាជាតិ ដើម្បីរួមកម្លាំងកម្ចាត់នាយទុនកុំប្រាដ័រ និងពួកប្រតិកិរិយា បាទ មានចក្រពត្តិអាមេរិក ហើយខ្ញុំហ្នឹងមិនទាន់យល់ផងទេ នាយទុនកុំប្រាដ័រនោះ មិនដឹងម៉េចទៅវិញផងទេ ប៉ុន្តែអានេះចាំជាទ្រឹស្ដី។ បាទ សូមលោកមេធាវីជ្រាប។

[១៤:១៦:៤៨]

**ស៖** សហការីរបស់ខ្ញុំពីខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានអាននូវចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានគេបង្ខំឲ្យសរសេរប្រវត្តិរូប។ តើនេះជាការអនុវត្តជាទូទៅឬនៅក្នុងរបបខ្មែរក្រហមដែលគេបង្ខំឲ្យប្រជាជនសរសេរប្រវត្តិរូប?

**ឆ៖** សំណួរនេះ ខ្ញុំចង់និយាយថា សំណួរនេះហាក់ដូចជាលោកកាន់ផ្លែក្រូចមួយផ្លែយកមកដាក់លើតុ ហើយសួរថាតើក្រូចហ្នឹងផ្អែមឬជូរ? ដូច្នេះខ្ញុំមិនអាចបដិសេធ ឬឆ្លើយប្រាប់ថាលោកក្រូចលោកនេះផ្អែម ឬក្រូចនេះជូរទេ។ ព្រោះអ្វីលោកសួរសំណួរហ្នឹង ខ្ញុំអត់មានមតិណែនាំ ហើយខ្ញុំអត់បានធ្វើ។ អ៊ីចឹងអ្នកដែលធ្វើហ្នឹងមិនដឹងធ្វើនៅតំបន់ណា អីណាទេ។ បាទ សូម -- ខ្ញុំសូមបដិសេធ ខ្ញុំឆ្លើយថា ខ្ញុំអត់ បាទ អត់ទេ។

**ស៖** សំណួររបស់ខ្ញុំ អ៊ីចេះលោកសាក្សី ក្នុងឋានៈលោកជាមេឃុំ ដែលលោកបានទទួលឋានៈហ្នឹងក្រោយមក លោកត្រូវបានទទួលតួនាទីដដែលនៅតំបន់២៥។ តើលោកមានបានទទួលបញ្ជាពីថ្នាក់លើនេះឲ្យលោកធ្វើប្រវត្តិរូបប្រជាជនដែរឬទេ? ស្រង់ប្រវត្តិរូបប្រជាជនដែរទេ?

**ឆ៖** បាទ សូមឆ្លើយ សូមអត់ទេ។ ប៉ុន្តែខ្ញុំសូមឆ្លើយលម្អិតដែលលោកសួរខ្ញុំថា តើគេចាត់ទុកខ្ញុំជាអនុធននោះ តើកម្រិតវប្បធម៌ចេះថាម៉េច? សូមជម្រាបថា ចាប់ពីត្រឹមអ្នកចេះអានចេះសរសេរថ្នាក់រៀន១ពីថ្នាក់ពី៧ ពីដើមគេហៅទី៦ ទី៥ ទី៣ ទី៤ អីហ្នឹង គឺជាអនុធនសិស្សហើយបាទ។ អ៊ីចឹងកម្រិតការយល់ដឹង។ ការដែលគេកំណត់ ប៉ុន្តែដោយឡែកចំពោះឲ្យស្រង់ប្រវត្តិរូបមកឃុំនីមួយៗ ចំពោះឃុំកំពង់ស្វាយដែលខ្ញុំបានទៅរស់នៅនោះគឺអត់ទេបាទ ខ្ញុំអត់បានធ្វើ ហើយបានទទួលនូវយកមតិណែនាំផងដែរ។ បាទ សូមអស់យោបល់។

[១៤:១៩:១២]

**ស៖** ការចាត់ទុកលោកថា ជាអនុធនហ្នឹង តើវាធ្វើឲ្យលោកប្រឈមនឹងគ្រោះថ្នាក់ដែរទេ?

**ឆ៖** សូមឆ្លើយ វាប្រឈមទាំងទស្សនៈ ទាំងសកម្មភាព។ សូមជម្រាបលោកមេធាវី។

**ស៖** សូមលោកពន្យល់ផងថា ហេតុអ្វីបានជាលោកអាចប្រឈមទៅនឹងគ្រោះថ្នាក់ដោយសារតែលោកមានការអប់រំ រៀនសូត្រនេះ?

**ឆ៖** សូមឆ្លើយនឹងចំពោះមុខម្ចាស់សំណួរ។ អ្វីដែលខ្ញុំប្រឈម ពីព្រោះពេលនោះ ខណៈនោះក្រោយពីមានឈ្មោះថា "កម្ពុជាប្រជាធិបតេយ្យ" ហើយក៏គេយកជនអក្ខរាកម្ម បានន័យថា អ្នកមិនសូវចេះសរសេរ មិនសូវចេះអានឲ្យដឹកនាំ។ អ៊ីចឹង អ្នកទាំងនោះ ច្រើនតែអនុវត្តឆ្វេងទៅតាមអង្គការដាក់ចុះ អ៊ីចឹងហើយយើងមានការលំបាកតស៊ូមតិ ឬនិងប៊ាននិយាយ។ កាលណាពេលនិយាយ គេថាឯងមានធាតុអនុធន ធាតុមុខមាត់។ ម្ល៉ោះហើយ គឺលំបាក។ សូមជម្រាបមេធាវី សូមជម្រាបលោកឲ្យបានជ្រាប។

**ស៖** លោក គឺថាលោកកំពុងតែនិយាយថា ការចាប់ខ្លួន ត្រូវបានបញ្ជាតែពីខាងភូមិភាគ។ តើអ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** សូមលោកនិយាយម្តងទៀត ព្រោះអំម្បាញ់មិញ មីក្រូហ្វូនអត់ទាន់បើកនៅឡើយ។

**ឆ៖** បាទ ខ្ញុំសូមធ្វើការជម្រាបសំណួររបស់លោកសួរ ថាតើអ្នកដែលចាប់ -- អ្នកនេះគឺមានត្រឹមគណៈភូមិភាគនិងមជ្ឈិម។ បាទ ពិតប្រាកដហើយ ខ្ញុំ -- ព្រោះពាក្យហ្នឹងពាក្យ តាម៉ុក គាត់និយាយប្រាប់។

[១៤:២១:៤៥]

**ស៖** តើតាម៉ុក ហ្នឹងគាត់ធ្វើយ៉ាងម៉េចដែរ នៅពេលចាប់ខ្លួនហ្នឹង? គាត់ចាប់ខ្លួនដោយខ្លួនឯងផ្ទាល់ ឬមួយក៏គាត់ចេញបញ្ជាទៅឲ្យគេចាប់ខ្លួន?

**ឆ៖** ខ្ញុំជម្រាបថា ខ្ញុំអត់ដឹងទាំងអស់រាល់មតិ រាល់សារាចរចាត់ចែងក្នុងបញ្ហាជីវិតមនុស្សហ្នឹង បាទ។ ពីព្រោះការងារគេ គេដឹង ការងារខ្ញុំ ខ្ញុំដឹង ហើយវាមានផ្នែក។ អ៊ីចឹងសូមជម្រាបមេធាវីឲ្យបានជ្រាប បាទ។

**ស៖** លោកសាក្សី តើលោកត្រូវបានពួកខ្មែរក្រហមដកតំណែងមែនទេ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ដកតំណែង តួនាទីរបស់ខ្ញុំ ត្រឹមត្រូវហើយ សំណួរដែលលោកបានសួរ។

**ស៖** តើគេដកតំណែងលោកហ្នឹង ដោយសារតែលោកធ្វើខុសសីលធម៌ មែនទេ?

**ឆ៖** ការខុសសីលធម៌ ក៏ខ្ញុំមិនបដិសេធដែរ ប៉ុន្តែខ្ញុំមិនបានប្រមាថកាតទានទៅលើនារីណាទេ។ ប៉ុន្តែពេលនោះ ក្រោយពីខ្ញុំបានទទួលទារុណកម្ម គេបន្ថយសិទ្ធិខ្ញុំ បានដឹងថាគេនៅធ្វើការជាមួយហ្នឹង គេមានតួនាទីមុខមាត់ ហើយគេចង់បានតំណែងហ្នឹងម្យ៉ាង។ តែម្យ៉ាង ខ្ញុំដឹងខ្លួនខ្ញុំថា អ្វីដែលខ្ញុំមិនតូចចិត្ត ពីព្រោះខ្ញុំមានបងមួយចេញពីក្រុងភ្នំពេញ។ អ៊ីចឹងការពាក់ព័ន្ធវាមានពីរចំណុចហ្នឹង ជាធាតុផ្សំដែលខ្ញុំខំសម្របពង្រឹងខ្លួនដើម្បីរស់ បានមកទល់ថ្ងៃនេះ បាទ។ សូមជម្រាប។

[១៤:២៤:០៥]

**ស៖** អ៊ីចឹង លោកឆ្លើយថា គេសង្ស័យលោកថា ដោយសារតែលោកមានបងប្អូន មាននិន្នាការ ទោះបីថាលោកបានបំពេញការងារច្រើនក៏ដោយ តើអ៊ីចឹងមែនទេ? អ៊ីចឹងមានន័យថា គេសង្ស័យលោកហ្នឹង ដោយសារតែតួនាទីកន្លងមករបស់បងប្រុសលោក អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើគេមានចោទប្រកាន់អំពីការមានអំពើសាហាយស្មន់ជាមួយប្រពន្ធរបស់កម្មាភិបាលផ្សេងទេ?

**ឆ៖** បាទ អត់មានទេ បាទ។

**ស៖** អ៊ីចឹងមានន័យថា លោកមិនដែលឮគេ ឬក៏លោកមិនដែលដឹងថាគេចោទប្រកាន់លោក ដោយសារតែលោកសាហាយស្មន់ជាមួយនឹងរបស់ប្រពន្ធស័ក្តិ៥ ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់ទេបាទ អត់។

**ស៖** តើក្នុងរបបខ្មែរក្រហមលោកធ្លាប់ជួយសង្គ្រោះជីវិតរបស់មនុស្សណាម្នាក់ផ្សេងទេ?

**ឆ៖** បាទ ចំពោះការជួយសង្គ្រោះ ជាទូទៅ ជាបុគ្គលម្នាក់ៗហ្នឹង គឺខ្ញុំអត់មានទេ ពីព្រោះយកមាគ៌ា មតិណែនាំឲ្យគេទាំងអស់សម្របសម្រួលខំធ្វើការដើម្បីរស់ទាំងអស់គ្នា តែប៉ុណ្ណឹងបាទ តែត្រង់ចុចដូចថាជួយអ្នកនេះ ជួយអ្នកនោះ ខ្ញុំអត់មានទេបាទ។

**ស៖** តើលោកធ្លាប់ឃើញ គេចាប់ស្ត្រីម្នាក់យកទៅសម្លាប់ចោល ក្រោយពេលដែលគាត់ឆ្លងទន្លេទេ?

**ឆ៖** បាទ អត់បានឃើញទេបាទ។

[១៤:២៦:២១]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានៗ ខ្ញុំសូមអនុញ្ញាតបន្តិច។ នៅពេលដែលខ្ញុំមិនបង្ហាញកាលបរិច្ឆេទ នៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សហព្រះរាជអាជ្ញា ងើបឈរឡើងហើយជំទាស់។ ហើយឥឡូវនេះព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់គាត់រៀបរាប់និយាយយ៉ាងលម្អិតអំពីឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមបញ្ចូលទាំងការប្រព្រឹត្តខុសសីលធម៌ជាដើម។ ដូច្នេះ តើគាត់កំពុងធ្វើអ្វីឥឡូវនេះ? ហើយអង្គជំនុំជម្រះប្រាប់ខ្ញុំថាមិនឲ្យសួរសំណួរនាំមុខដោយសារជាឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែឥឡូវព្រះរាជអាជ្ញាគាត់ធ្វើខ្លួនឯង។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនមែននាំមុខទេ ប៉ុន្តែខ្ញុំគ្រាន់តែលើកយកព័ត៌មាន គឺថាខ្ញុំធ្វើដូចនឹងមេធាវីការពារក្តីបានធ្វើពីព្រឹកអ៊ីចឹង។ គឺជាឯកសារដូចគ្នាដែលមេធាវីការពារក្តីបានលើកយកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដូចគ្នា។ ខ្ញុំមិនបានបង្ហាញថាឯកសារនេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏អត់ទេ គឺមេធាវីការពារក្តីបានធ្វើ។

[១៤:២៧:៣១]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

យើងមិនអនុញ្ញាតឲ្យមានការសួរសំណួរសាក្សីកាលពីមុន មកដោយសារតែយើងមិនអាចដឹងថាតើមានអ្វីគិតនៅក្នុងចិត្តរបស់មេធាវី ក៏ដូចជាព្រះរាជអាជ្ញា។ ដូច្នេះ យើងអនុញ្ញាត ប្រសិនបើសំណួរហ្នឹងវាពាក់ព័ន្ធ ហើយវាមិននាំមុខ។ ប្រសិនបើមិនមានសំណួរនាំមុខទេ គឺថាយើងមិនមានអ្វីនឹងត្រូវ

ជំទាស់ជាមួយនឹងសហព្រះរាជអាជ្ញា ប៉ុន្តែចំពោះភាពពាក់ព័ន្ធនៃសំណួរហ្នឹង ខ្ញុំមិនដឹងថាហេតុអ្វីទេ។ ដូច្នេះព្រះរាជអាជ្ញាអាចពន្យល់បានទេ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា ការដែលឃើញស្ត្រីម្នាក់ត្រូវបានគេយកទៅសម្លាប់ក្រោយពេលដែលប្រសូត្របុត្រ គឺជាពាក់ព័ន្ធណាស់ ព្រោះស្ត្រីនោះគឺជាប្រពន្ធរបស់ស័ក្តិ៥។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

គឺថាខ្ញុំមិនយល់ច្បាស់អំពីចំណុចខាងក្រោយហ្នឹង ដែលនិយាយអំពីការប្រព្រឹត្តខុសសីលធម៌នោះ គឺទំនាក់ទំនងរវាងកំហុសសីលធម៌ ហើយនិងអ្វីដែលលោកបានលើកឡើងខាងក្រោយ។ នេះគឺជាអ្វីដែលខ្ញុំគិតថា វាជាបញ្ហាព្រោះយើងអត់មានឯកសារហ្នឹងចំពោះមុខ។

**លោក នីកូឡាស គូមជែន៖**

សំណួរចុងក្រោយគឺនិយាយអំពីការសម្លាប់ស្ត្រីម្នាក់ គឺដែលថាតើយកស្ត្រីហ្នឹងទៅសម្លាប់ ឬក៏អត់។ ដូច្នេះ បញ្ហាគឺទាក់ទងទៅនឹងកំហុសសីលធម៌ ក៏ដូចជាភាពដែលជឿជាក់បានរបស់សាក្សី។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ថាតើមានសំណួរច្រើនទៀតដែរឬទេ ដែលធ្វើឲ្យយើងអាចឆ្លុះពីភាពពាក់ព័ន្ធនោះ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថាមិនច្រើនពេកទេ។

[១៤:២៩:៣២]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ដូច្នេះខ្ញុំគិតថាវាជាសំណួរដែលខ្ញុំបានសួរកន្លងមក ហើយខ្ញុំត្រូវសួរឡើងវិញ។ តើលោកឃើញស្ត្រីម្នាក់ជាប្រពន្ធរបស់ស័ក្តិ៥ ដែលត្រូវបានគេយកទៅសម្លាប់ចោល ឬក៏អាចនិយាយម្យ៉ាងទៀតថាគាត់ត្រូវបានគេយកទៅក្រោយពេលដែលប្រសូត្របុត្រនោះ។ តើលោកធ្លាប់ឃើញទេ?

**លោក សៅ វ៉ន៖**

**ឆ៖** សូមធ្វើការជម្រាប។ បាទ ក្នុងរឿងហ្នឹង ក្រោយពីខ្ញុំទទួលទារុណកម្ម គេចោទថាខ្ញុំសាហាយស្មន់ ឬក៏ថាមានពាក់ព័ន្ធជាមួយបងស្រីស័ក្តិ៥ -- ប្រពន្ធស័ក្តិ៥ ហ្នឹង។ ពេលដែលខ្ញុំទៅពី១៣ទៅ១ដល់២៥ គឺប្តីគាត់ទៅបាត់ហើយ។ គេយកទៅបាត់។ ត្រង់ខ្ញុំដឹងគេយកទៅណាមកណា មិនដឹងទេ

បាទ។ អាហ្នឹងសូមជម្រាប ខ្ញុំអត់បានឃើញ។ តែចំពោះបងស្រី មិនមែនបងខ្ញុំទេ ពេលហ្នឹងប្រហែល គាត់អាយុ៣០ជាងទេ។ គាត់មានទម្ងន់ពិតប្រាកដ។ ហើយខ្ញុំនិយាយនេះ គឺខ្ញុំអំណះអំណាង ហើយខ្ញុំ ក្លាហានខ្ញុំជម្រាប ហើយក្លាហានហ្នឹងបកស្រាយ។ ដល់តែពេលគាត់ ពេលសម្រាល គាត់ចូលទៅ សម្រាលនៅមន្ទីរពេទ្យឃុំកំពង់ស្វាយហ្នឹង។ ហ្នឹងសូមជម្រាប។ ដល់តែហើយក្នុងមន្ទីរពេទ្យហ្នឹង ខ្ញុំរីករាយណាស់ ហើយខ្ញុំលើកឡើងការពិត។ ពេលហ្នឹងក្នុងមន្ទីរពេទ្យហ្នឹង រោងហ្នឹង មានគ្រែសងខាង ហើយស្ថិតនៅក្នុងចម្ការក្រូច។ ក្រូចផ្អែដុំវិញហ្នឹង។ ដល់តែហើយពេលដែលខ្ញុំចូលទៅ ខ្ញុំមកពីការដ្ឋាន ចូលទៅឃើញគាត់សម្រាល។ ហើយម្ខាងអ្នកដែលដេក សុំទោស គេច្រើននិយាយថាអ្នកមូលដ្ឋាន។ គ្រែម្ខាង ជួរ -- ពីរជួរ។ ដល់តែហើយបងប្អូនខាងមូលដ្ឋានគាត់មាន ដូចថាចំណីចំណុកហូបពិសា តែ ដោយឡែកចំពោះគាត់ហ្នឹង គឺអត់។ ហ្នឹងសូមជម្រាប។ អ៊ីចឹងខ្ញុំឡូឡាប្រាប់ពេទ្យ ថាផ្លែក្រូចដុំវិញហ្នឹង រឿងអីបានបេះយកជូនគាត់ហូបទាំងអស់ហ្នឹង។ ត្រង់ចំណុចហ្នឹងហើយដែលគេចាប់អារម្មណ៍ថាខ្ញុំមាន ទំនាក់ទំនងជាមួយអ៊ីហ្នឹង។ ដល់តែពេលក្រោយបានបីថ្ងៃ ខ្ញុំសូមធ្វើការជាឱឡារិក។ ខ្ញុំចុះទៅការដ្ឋាន ជាមួយនីរសារខ្ញុំម្នាក់ តែខ្ញុំភ្លេច។ ពេលហ្នឹងខ្ញុំមានថ្នាំពេទ្យ ស្រាប់តែឃើញអ៊ីហ្នឹង គាត់នៅនឹងរោងគាត់ ផ្ទះគាត់។ ខ្ញុំសួរ -- ងាកទៅឃើញ ព្រោះផ្ទះគាត់វាជាប់នឹងផ្លូវ។ ហើយខ្ញុំមិនទាំងស្គាល់ឈ្មោះគាត់ទេ។ ហើយខ្ញុំក៏អត់មានសំណេះសំណាល ឈរសួរគាត់ដែរ។ បាទ សួរថា "ចេញហើយ?" ថា "ចេញហើយ" ហើយខ្ញុំក៏ថា ចុះគេប្រញាប់ឲ្យចេញម្ល៉េះ។ ហើយខមាទោស គាត់ក៏ ដូចថាវាសុខភាពហ្នឹងវាមិនទាន់នេះ ផង។ ខ្ញុំក៏ឲ្យនីរសារហ្នឹងឲ្យថ្នាំសង្កូវទៅគាត់។ ហ្នឹងសូមជម្រាបការពិត។ ដល់តែក្រោយមកនេះ រំលង បានប៉ុន្មានខែមក គេដកសេចក្តីទុក -- ដកសិទ្ធិខ្ញុំមក១កណ្តាលស្ទឹងនេះ។ ហើយក្រោយមកទៀតបានខ្ញុំ ដឹង១ថាគេចោទខ្ញុំពីរឿងសីលធម៌នារី ព្រោះខ្ញុំដោះស្រាយទំនាស់ពេលនោះ ខ្ញុំដោះស្រាយផ្អែកលើ -- ស្មើតែម្តង អត់មានថាបែងចែងអ៊ីចេះអ៊ីចុះអីទេ។ អាហ្នឹងសូមជម្រាបមេធាវី -- ម្ចាស់សំណួរ។ ខ្ញុំអត់ បានឃើញគាត់ស្លាប់ទេ អត់ទេ។ សូមជម្រាបដោយស្មោះត្រង់ ដើម្បីឲ្យអស់ការមន្ទិល ហើយការ សង្ស័យ។ ហើយខ្ញុំអត់លាក់លៀមទៀតនៅឃុំកំពង់ស្វាយ បើអស់លោកមិនច្បាស់ប្រាកដថា ខ្ញុំប្រតិ- កិរិយាប៉ុនណាអីប៉ុនណា សូមគិតថែមទៀតចុះ។ សូមអស់យោបល់។

[១៤:៣៣:២៧]

**ស៖** ដូច្នេះមុនពេលដែលលោកឃើញ -- មុនពេលដែលលោកឃើញគាត់នៅពេទ្យហ្នឹង គឺ មានន័យថាប្តីរបស់ស្ត្រីហ្នឹងបាត់ខ្លួនបាត់ទៅហើយ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាត់ហើយបាទ ខ្ញុំទៅអត់ទាន់ទេ បាត់ហើយ។

**ស៖** ខ្ញុំគិតថាប្រហែលជាមានអ្នកអត់ស្ដាប់ឮចម្លើយរបស់លោក។ តើលោកអាចបញ្ជាក់ឡើងវិញបានទេ?

**ឆ៖** ខ្ញុំឆ្លើយថាពេលប្ដីរបស់គាត់ហ្នឹង បាត់ហ្នឹងខ្ញុំទៅៗដល់ គាត់បាត់ទៅហើយបាទ។ ខ្ញុំអត់ដឹងថាអ្នកណាគេយកទៅណា បញ្ជូនទៅណាទេបាទ។ សូមអស់យោបល់ប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់និយាយអំពីបងប្អូនប្រុសរបស់លោកម្ដង គឺថានៅពេលដែលគេយកគាត់ទៅបីខែ គឺថាបីខែក្រោយថ្ងៃ១៧ មេសា ៧៥ គឺគេ - គឺបីខែក្រោយមក បងប្រុសរបស់លោកបានត្រឡប់មកផ្ទះនៅត្រាំកក់វិញ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលដែលចេញ ក្រោយ១៧ហ្នឹង គាត់ថាគាត់ធ្វើដំណើរទៅជើង បាទ។ ពីព្រោះផ្លូវមកត្បូងនេះ ចង្អៀត។ ដូច្នេះ ទៅហ្នឹង គឺទៅក្នុងស្មារតីមួយ គាត់ចេញទៅជាមួយគេជាមួយឯងទេ។ អត់មានអ្នកណាចាប់ចងអីទេ។ អត់ទេ ហើយដល់ទៅប្រហែលបានបីខែ បួនខែ គាត់ធ្វើដំណើរសុំប្រធានកងហ្នឹងមកស្រុកវិញ។ បាទ ដើរមករែកកូនរែកចៅហ្នឹងមក ធ្វើដំណើរមក ទៅដល់ស្រុកបាទ។ ហើយពេលទៅដល់ស្រុកហ្នឹង ខ្ញុំក៏បានជួបសំណេះសំណាលសួរគាត់ប៉ុណ្ណឹងបាទ។ ហើយដល់តែហើយទៅបងហ្នឹងក៏មិនបាននៅនឹងផ្ទះទេ បានទៅរៀន២០៤ មន្ទីរ២០៤ ហើយខ្ញុំក៏អង្គការបញ្ជូនទៅនៅ២៥ហ្នឹងទៅ។ ដូច្នេះរយៈកាលបីឆ្នាំប៉ុន្មានហ្នឹង គឺអត់បានជួបគ្នា នៅជាមួយគ្នា ជាមួយគាត់ទេ។ បាទ សូមជម្រាប ក្នុងចម្លើយនេះវាវែងបន្តិចទៅហើយ។ សូមអស់យោបល់។

[១៤:៣៦:២៥]

**ស៖** ២០៤ ៗហ្នឹង គឺជាគុកមែនទេ លោក?

**ឆ៖** កំណត់ថាគុកក៏ថាមិនបាន គឺកន្លែងដែលអប់រំ កន្លែងដែលត្រូវបង្កបង្កើនផល ហើយអ្នកដែលមាននេះ គឺគេយកទៅហ្នឹង ទាំងបងខ្ញុំ ទាំងមនុស្សក្នុងមូលដ្ឋានហ្នឹង ទៅពង្រីកដីបាទ ២០៤ហ្នឹងកន្លែងហ្នឹង។

**ស៖** តើ២០៤ហ្នឹង គឺជាវត្តចាស់ គឺជាអតីតវត្ត តើមែនទេលោក?

**ឆ៖** បាទ សូមជម្រាប មិនមែនជាវត្តចាស់ទេ គឺកន្លែងដែលព្រៃ មានព្រេច មានកូនខ្ពង់កូនត្បែងអី។ ប្រជាជននៅតាមឃុំដែលចេញពីភ្នំពេញទៅច្រើនអី ចេះតែពង្រីកធ្វើការធ្វើស្រែនេះហ្នឹង។ ដូច្នេះ កន្លែងហ្នឹងក៏ជាអង្គភាពមួយ។ ២០៤ហ្នឹង សម្រាប់រៀនផ្ការបង្កបង្កើនផលបាទ។ សូមអស់

យោបល់បាទ។

**ស៖** លោកសាក្សី តើមានសមាជិកគ្រួសារលោកណាម្នាក់ធ្លាប់ទៅជួប ខុម ដែលជាលេខាស្រុក ហើយជាកូនតាម៉ុក នុំង ដើម្បីជួយសុំឱ្យដោះលែងបងប្រុសរបស់លោកដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅលើសំណួរនាំមុខនេះ។ នៅពេលដែលខ្ញុំសួរអំពីទីរួមខេត្តតាកែវ ព្រះរាជអាជ្ញាគាត់ជំទាស់។ ប៉ុន្តែព្រោះថា គាត់និយាយថា អាហ្នឹងជាឯកសារមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងមិនអនុញ្ញាតឱ្យសួរអំពីឯកសារនេះ។ ប៉ុន្តែឥឡូវនេះ គាត់ខ្លួនឯងផ្ដល់គាត់ធ្វើបែបនេះ ហើយកាលពីព្រឹកមិញ គឺជំទាស់មិនឱ្យយើងធ្វើ។

[១៤:៣៨:២៩]

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញាផ្លាស់ប្ដូរសំណួរបាទ។ សូមអញ្ជើញ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើក្រុមគ្រួសាររបស់លោកមានស្វែងរកមធ្យោបាយអ្វីដើម្បីសុំឱ្យបងប្រុសរបស់លោកហ្នឹង គេដោះលែងគាត់ពី ២០៤ ដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** សូមឆ្លើយ នៅពេលដែលបងខ្ញុំទៅនៅ២០៤ បានរំលងមួយអាទិត្យ ខ្ញុំក៏ទៅតំបន់២៥។ ដូចនេះ អត់មានពីណាទៅទំនាក់ទំនងទេ ហើយខ្ញុំក៏មិនបដិសេធដែរ គឺមានម្ដាយខ្ញុំគាត់តាមទៅសួរសុខទុក្ខ ដែលធ្វើដំណើរដីជិត២០គីឡូនុំងបាទ គាត់ធ្វើដំណើរទៅ។ តាមរយៈហ្នឹង គេបានដឹងថា គ្រួសារខ្ញុំនេះ នៅជនបទនេះ គឺមានបងប្អូននៅរួមជាមួយនឹងបដិវត្តន៍។ អ៊ីចឹងហើយក៏ការសំណេះសំណាលនេះ ក៏ឃើញថា ការដោះលែងនេះ គឺអត់ទេ គ្រាន់តែថា ប្រពន្ធកូនទៅនៅជាមួយ នៅហ្នឹង ហើយដល់៧៩ បានគាត់ចេញពីមន្ទីរហ្នឹងមកវិញទេ។ បាទ សូមជម្រាបឱ្យបានជ្រាប។

[១៤:៤០:១០]

**ស៖** តើគេឃុំខ្លួនបងប្រុសរបស់លោកនៅ២០៤ហ្នឹង រហូតដល់ឆ្នាំ៧៩មែនទេ?

**ឆ៖** បាទ ខ្ញុំមិនៗដាក់ទម្ងន់ថាគេឃុំខ្លួនទេ ពីព្រោះទៅនៅហ្នឹង កូនគាត់ ប្រពន្ធគាត់ ខ្លួនគាត់ហ្នឹង ហើយរកស៊ីរស់នៅជាមួយគេឯងជួរទៅក្នុងហ្នឹង បាទ ទាំងអស់គ្នាហ្នឹង។ ហើយភាគច្រើននៅ

ហ្នឹង មិនមែនតែម្នាក់ពីរនាក់ទេ រាប់រយនាក់ដែរហ្នឹង បាទ។ ហើយដល់៧៩ ពេលស្រុកគេវាប្រែប្រួល ក្រឡាប់ចាក់ទៅ។ ចាស់ៗនិយាយថា ពាក្យក្រឡាប់ចាក់ហ្នឹង។ គាត់ដូច្នេះ គាត់ធ្វើដំណើរមក ដល់ផ្ទះវិញមក តែដល់តែពេលមកដល់ផ្ទះបានប៉ុន្មានថ្ងៃ៧៩ហ្នឹង ថ្ងៃ០៧ហ្នឹង -- ថ្ងៃ០៨, ០៩ វៀតកុងចៅហ្នឹងរត់ទៅនឹងគេនឹងឯង ឡើងភ្នំទៀតទៅ បាទ។ ហើយបានត្រឡប់មកស្រុកវិញ ក្រោយមក បានប៉ុន្មានខែបានមកស្រុក បាទ ដល់ស្រុកវិញ បាទ សូមធ្វើការបញ្ជាក់ និងជម្រាបប៉ុណ្ណឹង បាទ សូមអស់យោបល់។

**សៈ** តើបងប្រុសរបស់លោកធ្លាប់ថ្លែងអំណរគុណដល់លោក ឬក៏ដល់ក្រុមគ្រួសាររបស់លោកដែលបានជួយគាត់ដែរឬទេ?

**ប្រធានអង្គជំនុំៈ**

លោកសាក្សីឈប់អាលឆ្លើយ លោកសាក្សី។ អត់ទាន់មានចុចនេះផង សុំចុចសិន បាទ។

**លោក សៅ វ៉ន**៖

**ឆ៖** បាទ ក្នុងនាមជាគ្រួសារ គាត់មានការត្រេកអរ បាទ។ បងប្អូនមកជួបជុំគ្នាហ្នឹង អត់ -- ហើយឈ្មោះថាគាត់ថ្លែងអំណរអរគុណនោះ គឺថ្លែងហើយ បងប្អូន បាទ។ សូមអស់យោបល់ បាទ។

**សួរដោយលោក នីកូឡាស គូមជែន**៖

**សៈ** លោកសាក្សី ខ្ញុំនឹងបន្តទៅមុខទៀត ដោយសារខ្ញុំនៅសល់ពេលតិច។ ខ្ញុំនឹងពិភាក្សាពីសក្ខីកម្ម និងឯកសារមួយចំនួន។ ទី១ គឺ E3/ -- E3/5518 ហើយខ្ញុំសូមអានចាប់ពីសំណួរទី២នេះ គឺជាសក្ខីកម្មរបស់ សៅ ហេង នៅក្នុងខែមេសា គាត់រស់ -- ឆ្នាំ៧៥ គាត់រស់នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ តើលោកចាំ -- តើលោស្គាល់ឈ្មោះនេះទេ លោក?

[១៤:៤៣:០២]

**លោក សៅ វ៉ន**៖

**ឆ៖** សូមបញ្ជាក់សំណួរម្តងទៀត ខ្ញុំៗឮមិនច្បាស់។

**សៈ** ខ្ញុំសូមអានអ្វីដែល សៅ ហេង មកស្រុកត្រាំកក់ បាននិយាយនៅក្នុងឆ្នាំ២០០៩ ប្រាប់សហ -- ការិយាល័យសហចៅក្រមស៊ើបអង្កេត គេសួរគាត់ថា "ភ្លាមៗក្រោយពេលដែលពួកទាំងនោះមកដល់ តើគេមានធ្វើប្រវត្តិរូប ឬក៏តាមដានប្រវត្តិរូបដែរឬទេ? ហើយគាត់ឆ្លើយថា "គេធ្វើ គឺគេតាមរកមើលថាតើអ្នកណាជាគ្រូ អ្នកណាជាយោធា អ្នកណាជារដ្ឋការ។ ហើយអ្នកដែលគេរកឃើញថា ជាគ្រូ ឬក៏យោធា ត្រូវបានគេចាប់ខ្លួន ហើយយកទៅ។ ហើយពួកគេមិនដែលឃើញម្តងទៀតឡើងវិញនោះឡើយ។

ដូច្នេះ គឺមានន័យថាគេកំពុងតែ គឺចំពោះបងប្រុសរបស់លោក គេស៊ើបប្រវត្តិរូបដែរ" តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ បងប្រុសខ្ញុំគេស៊ើបប្រវត្តិរូបដែរ បាទ ប៉ុន្តែគាត់ពីមុនចូលទៅក្នុងការងារជំទប់ហ្នឹង គាត់ធ្វើកម្មករនៅរោងចក្រជិនកាន ធ្វើស្បែកជើង។ ហើយដល់ក្រោយមក បានគាត់ទៅចូលរួមក្នុងការងាររដ្ឋបាលសង្កាត់លេខ០៦ហ្នឹង បាទ សូមជ្រាប។ ត្រង់ប្រវត្តិរូប គឺគេដឹងតាមរយៈអ្នកស្រុក បាទ តែត្រង់សរសេរជាក្រដាសស្នាម មកសាកសួរផ្ទាល់គាត់ អត់ទេ បាទ។ សូមជ្រាប។

**ស៖** ខ្ញុំចង់បង្ហាញឯកសាររបស់លោកពីស្រុកត្រាំកក់ គឺ E3/2048។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះទៅសាក្សី។

**លោក នីកូឡាស គូមជែន៖**

ឯកឧត្តមប្រធាន តើខ្ញុំអាចប្រគល់ឯកសារជូនសាក្សីបានដែរឬទេ? ហើយខ្ញុំសូមការអនុញ្ញាតពីលោកប្រធានផងដែរបង្ហាញឯកសារហ្នឹងនៅលើអេក្រង់ទូរទស្សន៍។ សូមឯកឧត្តមប្រធានអនុញ្ញាត។

[១៤:៤៥:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំសូមជំទាស់ទៅលើចំណុចនេះ ព្រោះថាព្រះរាជអាជ្ញាគាត់ហាក់ដូចជាមានចេតនាបង្ហាញឯកសារដល់សាក្សី ដែលសាក្សីមិនមែនជាអ្នកសរសេរ ឬអ្នកបង្កើតឯកសារទាំងអស់នោះឡើយ។ ហើយប្រហែលជាគាត់មិនមានទំនាក់ទំនងអ្វីជាមួយឯកសារនេះទេ។ ហើយឯកសារនេះវាពាក់ព័ន្ធទៅនឹងឃុំដែលគាត់មិនដែលធ្វើការជាមួយ។ ដូច្នេះ ខ្ញុំគិតថាខ្ញុំមិនជំទាស់ទេ ប្រសិនបើបង្ហាញឯកសារដែលមានភាពពាក់ព័ន្ធជាមួយសាក្សី។ ប៉ុន្តែចំពោះសាក្សីនេះ គឺថានៅឆ្នាំហ្នឹង គឺគាត់បានចាកចេញពីភូមិតពេលបាត់ទៅហើយ គឺឆ្នាំ៧៧ហ្នឹង គាត់ចេញពីឃុំពេលបាត់ទៅហើយ។ ដូច្នេះប្រហែលជាគាត់មិនអាចមានដឹង ឬក៏មិនអាចព័ត៌មានអីច្បាស់លាស់នោះទេ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា នេះគឺពាក់ព័ន្ធយ៉ាងសំខាន់បំផុតទៅនឹងសក្ខីកម្មរបស់សាក្សី គឺទាក់ទងទៅនឹងគោលនយោបាយ ហើយវាស្ថិតនៅក្នុងស្រុកដែលសាក្សីគាត់ធ្វើការ ហើយស្រុកនេះគឺស្ថិតនៅក្នុងក្រោមការគ្រប់គ្រងរបស់តាម៉ុក ហើយនិងសោម។ ដូច្នេះ គឺប្រាកដណាស់ថាវាមានភាពពាក់ព័ន្ធ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាគាត់នៅក្នុងស្រុកពពេល ឆ្នាំ៧១ ប៉ុន្តែឯកសារនេះគឺឆ្នាំ៧៧ទេ។ ដូច្នេះ វាប្រាកដជាគ្មានភាព

ពាក់ព័ន្ធ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ដូច្នេះ ដំណោះស្រាយដែលល្អ គឺយើងសាកល្បងមើល តើសាក្សីគាត់មានអ្វីត្រូវឆ្លើយទេ ប្រសិនបើយើងធ្វើដូច្នេះ ប្រហែលជាយើងអាចដំណើរការទៅមុខបានលឿន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជូនសាក្សី។ ខ្មែរនៅលើ 0052808 (*ស៊ីក*), បារាំងមានលេខ 00611659 គឺទំព័រទី១ នៃឯកសារជាភាសាអង់គ្លេស គឺ 0276562 “គឺផ្ញើជូនអង្គការស្រុកត្រាំកក់ ជាទីស្រឡាញ់ ស្ថានភាពខ្មាំងនៅមូលដ្ឋាន បន្ទាប់ពីបានទទួលការបញ្ជាពីអង្គការឲ្យមានការប្រុងប្រយ័ត្នជាមួយខ្មាំង ហើយនិងបោសសម្អាតមន្ត្រីខ្មាំង គឺយើងបានតាមដាន ហើយបានរកឃើញដូចតទៅនេះ ទី១) ឈិត ពាល ជាទាហានបានចាកចេញពីភ្នំពេញ ទៅអង្គតាសោម”។ លោកសាក្សីជាដំបូងខ្ញុំចង់សួរថា របាយការណ៍នេះផ្ញើសេចក្ដីរាយការណ៍ជូនអង្គការស្រុកត្រាំកក់។ ដូច្នេះ ខ្ញុំចង់ដឹងថា តើពាក្យអង្គការស្រុកត្រាំកក់ហ្នឹងមានន័យថាយ៉ាងដូចម្ដេចដែរ តាមដែលលោកដឹង?

[១៤:៤៨:៤៩]

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមអភ័យទោស ក៏ប៉ុន្តែខ្ញុំគិតថាយើងស្ថិតនៅក្រៅវិសាលភាពហើយ។ ខ្ញុំសូមគាំទ្រទៅលើអ្វីដែលបានលើកឡើងដោយមេធាវី នួន ជា គឺថាសូមឲ្យអង្គជំនុំជម្រះជំទាស់ទៅនឹងសំណួរនេះ ពីព្រោះខ្ញុំឃើញថា ដូចជាមិនមានទំនាក់ទំនងរវាងការប្រព្រឹត្តចំពោះមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ នៅពេលជម្លៀសប្រជាជន ហើយនិងទួលពោធិ៍ជ្រៃ នៅឆ្នាំ៧៧នោះទេ គឺខ្ញុំសូមបន្ថែមទៅលើការកត់សម្គាល់ដែលលើកឡើងដោយមេធាវី កូប៉េ។ ខ្ញុំគិតថា សំណួរនេះគឺនៅក្រៅវិសាលភាពទាំងស្រុងតែម្ដង។

[១៤:៤៩:២៤]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ លោក លោកស្រីចៅក្រម ភាពទំនាក់ទំនងគឺថាមេធាវីការពារក្ដីបានលើកឡើងថានេះជាការសំខាន់ ហើយសាក្សីនេះគាត់ចាំអំពីហេតុការណ៍ដែលកើតឡើងតាំងពី៣០-៤០ឆ្នាំកន្លងមកហើយ ប៉ុន្តែក្នុងឯកសារនេះ គឺយើងមានឯកសារមកពីស្រុក មកពីភូមិភាគដែលគាត់បាននិយាយ ហើយ

ឯកសារនេះបានបញ្ជាក់ថា មានការបញ្ជាឱ្យមានការប្រុងប្រយ័ត្ន និងបោសសម្អាតអ្នករដ្ឋការរបស់ខ្មាំង ដូច្នេះ ប្រាកដណាស់ គឺវាពាក់ព័ន្ធ។

**លោក អាកឡូវ វែកគែន៖**

គឺក្រោយពី -- ពីរក្រោយមកទេលោកព្រះរាជអាជ្ញា។ ខ្ញុំគិតថាសហព្រះរាជអាជ្ញានៅតែព្យាយាមប្រើប្រាស់ភស្តុតាងនៅក្រោយប្រធានបទ ដើម្បីត្រឡប់ក្រោយមកវិញដើម្បីព្យាយាមបង្ហាញភស្តុតាង។ ដូច្នេះ យើងឃើញថាអ្វីដែលកំពុងតែកើតឡើងនេះ សហព្រះរាជអាជ្ញាគាត់បានប្រើឯកសារនៅឆ្នាំ ១៩៧៧ ដើម្បីជំទាស់ -- ផ្ទុយទៅនឹងសាក្សីដែលគាត់បានឆ្លើយនៅក្នុងឆ្នាំ៧៥។ ដូច្នេះ ខ្ញុំគិតថា វាត្រូវនៅក្រៅប្រធានបទហើយឯកឧត្តមប្រធាន។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា ខ្ញុំគិតថាសាក្សីគាត់អាចនិយាយអំពីការផ្លាស់ប្ដូរនយោបាយ។ ដូច្នេះវាជាការល្អណាស់ដែលយើងអាចស្ដាប់ការប្ដូរគោលនយោបាយ។

**លោក អាកឡូវ វែកគែន៖**

ក៏ប៉ុន្តែនៅឆ្នាំ៧៧ គាត់ក្លាយទៅជាប្រជាជនសាមញ្ញទៅហើយ គាត់មិនអាចឆ្លើយបានទេ។

[១៤:៥០:៥៩]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោក វែកគែន យើងបានសម្រេចរួចទៅហើយថា យើងឲ្យដាក់ឯកសារនេះដើម្បីយើងពិនិត្យមើលទាំងអស់គ្នា។ ដូច្នេះហើយ យើងនឹងសម្រេចថា តើសាក្សីហ្នឹងគាត់មានអ្វីដែលអាចឆ្លើយជាមួយនឹងឯកសារទាំងអស់នេះ។

**លោក នីកូឡាស គូមជែន៖**

ដូច្នេះ ខ្ញុំសូមសួរសំណួរទៅលោកដោយផ្ទាល់។ ឯកសារនេះគឺឯកសារមកពីឃុំពេលដែលបានបញ្ជាក់ថា បន្ទាប់ពីទទួលបានការបញ្ជាពីអង្គការឲ្យមានការប្រុងប្រយ័ត្នចំពោះខ្មាំង ហើយនិងបោសសម្អាតមន្ត្រីខ្មាំង។ យើងបានតាមដាន ហើយបានរកឃើញមនុស្សដូចតទៅនេះ ថាតើវាជាការត្រឹមត្រូវដែរឬទេថា វាគឺជាគោលនយោបាយ ឬក៏មួយលោកមិនដឹងទេថា មានគោលនយោបាយក្នុងការតាមដានហើយនិងបោសសម្អាតរដ្ឋការ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកសហព្រះរាជអាជ្ញា ខ្ញុំសូមបញ្ចេញមតិ ព្រោះថាយើងមិនអនុញ្ញាតឲ្យមានសំណួរបែបនេះទៅខាងមេធាវីការពារក្តី។ ដូច្នេះ គួរតែលោកសួរថា តើមានគោលនយោបាយអ្វីដែលគាត់ផ្តល់សក្ខីកម្ម ឬក៏អំពីបញ្ហាអីផ្សេងៗមានការផ្លាស់ប្តូរគោលនយោបាយច្រើន ឬមួយក៏ថាគាត់អាចពន្យល់អ្វីបានអំពីអង្គហេតុនៅក្នុងឯកសារនេះ ប្រសិនបើគាត់មាន។

[១៤:៥២:៣៧]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកអាចពន្យល់ ឬក៏លោកអាចបញ្ចេញមតិអ្វីទាក់ទងទៅនឹងឯកសារនេះបានទេ?

**លោក សៅ វ៉ន៖**

**ឆ៖** ខ្ញុំសូមធ្វើការបញ្ជាក់ ឆ្នាំ៧៧ ខ្ញុំចេញពីឃុំជាងទងទៅហើយបាទ ចេញផុតត្រាំកក់ហើយក៏ប៉ុន្តែរាល់ខ្លឹមសារជាទស្សនៈ និងមតិណែនាំ គេលើកឡើងថាក្រោយថ្ងៃ១៧ នេះយើង--

**ប្រធានអង្គជំនុំ៖**

លោកសាក្សីផ្អាកសិន អំមិញអត់ស្តាប់បានអ្នកបកប្រែទេ ហើយអ៊ីចឹងសូមលោកនិយាយម្តងទៀត ហើយចាំ រង់ចាំក្បាលមីក្រូសិន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសូមលោកនិយាយម្តងទៀត យើងស្តាប់អត់ឮលោកនិយាយទេមុននេះ។

**លោក សៅ វ៉ន៖**

**ឆ៖** ខ្ញុំសូមធ្វើការជម្រាប និងសូមឆ្លើយ។ ខ្ញុំនៅក្នុងឃុំជាងទង មិនមែននៅក្នុងឃុំពពេលទេបាទ ហើយឆ្នាំ៧៧ ខ្ញុំនៅឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង។ ដូច្នេះអ្វីទាំងអស់ក្នុងឋានៈខ្ញុំជាជនសាមញ្ញមួយរូបមិនអាចដឹងឯកសារ។ ហើយឯកសារធម្មតាគេឆ្លងទៅឆ្លងមកគឺគេមិនអនុញ្ញាតឲ្យអ្នកណាក្រៅពីអង្គការទទួលទេ។ បាទ សូមអស់យោបល់ប៉ុណ្ណឹងបាទ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ នេះគឺជាឯកសារមកពីឃុំជាងទងឈ្មោះ មន -- តើលោកស្គាល់ឈ្មោះ មឿន ដែរឬទេ?

[១៤:៥៤:៥៣]

**ឆ៖** បាទ សូមឆ្លើយ។ ជាទូទៅ គេស្គាល់ខ្ញុំ តែខ្ញុំមិនបានស្គាល់គេទេបាទ មិនដឹងនរណា មននរណា មឿន អត់ទេ។ សូមអស់យោបល់។

**ស៖** លោកដឹងទេ ថាមានអ្វីកើតឡើងចំពោះអ្នកដែលមិនគោរពតាមការបញ្ជារបស់អង្គការ។ ឧទាហរណ៍ដូចជាអ្នកថ្នាក់ភូមិ ថ្នាក់ឃុំ ដែលបដិសេធមិនគោរពតាមបញ្ជារបស់អង្គការ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ថាតើមានអ្វីកើតឡើង។ ដូច្នេះ គួរតែមានការសួរឲ្យច្បាស់ ថាតើមានអ្វីកើតឡើង។ ដូច្នេះការដែលសួរថា ប្រសិនបើមានអ្វីកើតឡើង វាជាការទាយស្មាន។

[១៤:៥៥:៤១]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តាមដែលខ្ញុំកត់សម្គាល់ គឺថាសាក្សីគាត់បាននិយាយថារួចហើយថា ការបញ្ជាហ្នឹងគឺអ្នកណាដែលបដិសេធមិនស្តាប់បញ្ជារបស់អង្គការ មានន័យថា អ្នកហ្នឹងកំពុងតែជីកផ្នូរកប់ខ្លួនឯង។ ដូច្នេះការដែលធ្វើប្រឆាំងនឹងអាជ្ញាធរ គឺមានន័យថា ជាការប្រថុយស្លាប់រស់ហើយ។ ដូច្នេះ តើលោកអាចសួរ -- តើលោកចង់អំពីនេះ ឬមួយក៏លោកសួរអំពីការបញ្ជាជាទូទៅ។

**លោក នីកូឡាស គូមជែន៖**

*(គ្មានការបកប្រែ)*

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកព្រះរាជអាជ្ញាគួរតែលោកសួរឲ្យជាក់ច្បាស់បន្តិច ដើម្បីឲ្យសាក្សីគាត់អាចឆ្លើយតប។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ព្រឹកនេះ លោកបានឆ្លើយថា តាម៉ុក បានប្រាប់លោក ថាអ្នកណាក៏ដោយដែលមិនគោរពតាមបញ្ជា។ សូមទោស ខ្ញុំភ្លេចពាក្យដែលលោកនិយាយព្រឹកមិញហើយ ប៉ុន្តែគឺថា គេនឹងទទួលរងនូវផល នូវលទ្ធផលយ៉ាងខ្លាំង យ៉ាងធ្ងន់ធ្ងរ តើលោកចាំអំពីចំណុចទាំងអស់នេះ? គឺមានន័យថា អ្នកដែលមិនគោរពតាមបញ្ជាហ្នឹង គឺកំពុងតែជីកផ្នូរកប់ខ្លួនឯងហើយ។ តើអ៊ីចឹងមែនទេ?

[១៤:៥៧:០៩]

**លោក សៅ វ៉ន៖**

**ឆ៖** បាទ ចម្លើយដែលខ្ញុំបានលើកឡើងបញ្ជាក់សម្តីតាម៉ុក។ គាត់ថា "បើអ្នកណាមិនអនុវត្ត

តាមមតិណែនាំ គឺអ្នកនោះត្រូវជីករណ្តៅកប់ខ្លួនឯង"។ អាហ្នឹងគឺពិតជាគាត់និយាយអ៊ីចឹងមែន ហើយខ្ញុំព្រឹកមិញ ក៏បានបញ្ជាក់អ៊ីចឹងដែរ។ សូមអស់យោបល់។

**ស៖** លោកធ្វើការនៅក្នុងតំបន់ដែលគ្រប់គ្រងដោយ តាម៉ុក អស់រយៈពេលច្រើនឆ្នាំ។ ដូច្នេះខ្ញុំចង់ដឹងថា តើមានអ្នកធ្លាប់ប្រឆាំងនឹង តាម៉ុក ដែរឬទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំអត់បានដឹងទេ បាទ។

**ស៖** តើលោកធ្លាប់ឃើញ ឬក៏ឮអំពីអ្នកណាម្នាក់ដែលមិនធ្លាប់ស្តាប់បញ្ជា តាម៉ុក ទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំសូមជំទាស់ ព្រោះថាព្រឹកមិញ សាក្សីគាត់និយាយអំពីឧទាហរណ៍ទាក់ទងទៅនឹងការជីករណ្តៅកប់ខ្លួនឯង ហើយគាត់លើកឧទាហរណ៍នៃសេចក្តីសម្រេចដែលជាសេចក្តីសម្រេចស្លាប់រស់ ហើយខ្ញុំបានកត់ត្រាថាអាជ្ញាធរបានសម្រេចអំពីបញ្ហាស្លាប់រស់ ហើយអ្នកណាដែលមិនគោរពគឺត្រូវជីករណ្តៅកប់ខ្លួនឯងនោះឡើយ។ គឺថាជីករណ្តៅកប់ខ្លួនឯងហ្នឹង មិនមែនមិនស្តាប់បញ្ជានោះទេ គឺនៅពេលដែលត្រូវធ្វើការសម្រេចជាលក្ខណៈស្លាប់រស់។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ដូច្នេះ លោកគួរតែសួរឲ្យច្បាស់ ជៀសវាងការជំទាស់។

[១៤:៥៨:៥៥]

**សួរដោយលោក នីកូឡាស គូមជែន៖**

គឺថាមេធាវីការពារក្តី គាត់ជំទាស់ទៅលើអ្វីដែលខ្ញុំសួរកន្លងមក។ ឥឡូវ ខ្ញុំសួរឡើងវិញ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ឃើញអ្នកណាម្នាក់ដែលធ្លាប់ប្រឆាំង ឬក៏មិនគោរពតាមបញ្ជា ឬក៏ការ--

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

--

**អ្នកបកប្រែ៖**

ឯកឧត្តមប្រធាន សូមឲ្យព្រះរាជអាជ្ញា និងចៅក្រម និយាយឲ្យបានយឺតបន្តិច។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ដឹងឮ អំពីអ្នកណាម្នាក់ដែលមិនគោរពបញ្ជារបស់ តាម៉ុក ដែរឬទេ?

**លោក គង់ សំអុន៖**

លោកប្រធាន សូមអធ្យាស្រ័យ សូមកាត់ដោយសារការមានប្រសាសន៍របស់លោកស្រីចៅក្រមអម្បាញ់មិញ អត់មានការបកប្រែ។ អ៊ីចឹង ខ្ញុំសូមឲ្យមានការបកប្រែ។ បាទ សូមអរគុណ។

[១៤:៥៩:៥៦]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមលោកស្រីចៅក្រម មីឡាត មានប្រសាសន៍ឡើងអំមិញអត់មានបកប្រែ បាទ។

សូមអញ្ជើញ!

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តាមការស្នើឡើង គឺថាលោកព្រះរាជអាជ្ញាសួរទៅសាក្សី ហើយគាត់បានបញ្ជាក់ថាគាត់សួរសាក្សី ថាតើសាក្សីបានដឹងឮអំពីអ្នកណាម្នាក់ដែលមិនគោរពបញ្ជាពី តាម៉ុក គឺបញ្ជាណាក៏ដោយ។ ប្រហែលជាសាក្សីស្ដាប់ខ្ញុំអត់ឮ គឺថាខ្ញុំអត់មានបិទមីក្រូហ្វូនអ្វីទេ ខ្ញុំមិនដឹងទេ ប្រហែលជាបញ្ហាបច្ចេកទេសឬមួយក៏យ៉ាងម៉េច។ ប៉ុន្តែឥឡូវនេះខ្ញុំព្យាយាមសួរម្ដងទៀត។ លោកសាក្សី -- អ្នកបកប្រែតើលោកអាចអនុញ្ញាតឲ្យសាក្សីឆ្លើយសំណួរបានដែរឬទេ គាត់មិនអាចឆ្លើយតបទៅនឹងសំណួរព្រះរាជអាជ្ញា ឬក៏សំណួររបស់យើងខ្ញុំ។

**លោក សៅ វ៉ន៖**

**ឆ៖** សូមធ្វើការជម្រាបខ្ញុំស្ដាប់សំណួរអត់បាន សូមម្ដងទៀត។

[១៥:០១:៤៩]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ដោយសារតែមានពេលវេលាខ្លី ខ្ញុំសូមបន្តទៅមុខ ដោយបង្ហាញឯកសារមួយទៀតជាសារតួរលេខ គឺក្នុងកំណត់ត្រា E32048 គឺជារបាយការណ៍បញ្ជាក់ ហើយស្នើសុំទៅអង្គការស្រុកជាទីស្រឡាញ់ គឺ ERN មានលេខ -- គឺឯកសារដដែល ដែលខ្ញុំបានផ្ដល់ពេលមុន គឺ ERN ដដែល។ នៅក្នុងរបាយការណ៍នេះ គឺរបាយការណ៍បញ្ជាក់ "ខ្មែរកម្ពុជាក្រោមនិងប្រជាជនយួន បានមកជួបយើងមាន

ចំនួន ៦៤នាក់ ហើយមានមនុស្ស ២៤០នាក់។ ចំណុចទី២ គ្រួសារយោធា១០៦ ត្រូវបានកម្ទេចដោយអង្គការ រួមបញ្ចូលទាំងអ្នកដែលស្លាប់ សរុបទៅមានចំនួន ៣៩៣នាក់។ ដូច្នេះលោកសាក្សី ជាដំបូងតើខ្ញុំអាចសួរលោកបានទេ ថាតើពាក្យ "*ស្លាស*" – តើពាក្យ "កម្ទេច"។ នៅក្នុងបរិបទ ហ្នឹងមានន័យថាយ៉ាងដូចម្តេចតាមបទពិសោធន៍របស់លោក? នៅពេលដែលគេនិយាយថា "គ្រួសារយោធា១០៦ ត្រូវបានកម្ទេចដោយសារអង្គការរួមបញ្ចូលទាំងអ្នកស្លាប់ហ្នឹង គឺវាមានចំនួន ៣៩៣នាក់"។ ដូច្នេះ ពាក្យថា "កម្ទេច" ហ្នឹង មានន័យថាដូចម្តេចដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន សំណួរនេះ មិនមែនជា -- អ្នកសាក្សី មិនមែនជាអ្នកនិពន្ធ ឬក៏ជាអ្នកសរសេររបាយការណ៍នេះឡើយ។ ដូច្នេះ ការបង្ហាញឯកសារហ្នឹងទៅសាក្សី គឺវាគ្មានភាពពាក់ព័ន្ធអ្វីទាល់តែសោះ។ ហើយវាគ្មានអ្វីពាក់ព័ន្ធទាល់តែសោះនៅពេលដែលលើកយកពាក្យ "កម្ទេច" នៅក្នុងបរិបទនៃលិខិតហ្នឹង មកសួរសាក្សីបែបនេះ។

[១៥:០៣:៥២]

**លោក នីកូឡាស គូមជែន៖**

ប្រសិនបើឯកសារហ្នឹង មិនមានភាពពាក់ព័ន្ធ ប្រាកដជាមេធាវីការពារក្តី គាត់មិនជំទាស់នោះទេ ព្រោះថា វាពាក់ព័ន្ធផ្ទាល់ទៅនឹងគោលនយោបាយសម្លាប់ទាហានលន់ នល់ និងអ្នករដ្ឋការលន់ នល់។

**លោក អាកទួរ វែកគែន៖**

យើងក៏និយាយថា ថ្ងៃទី១៨ ឧសភា ឆ្នាំ១៩៧៧។ អ៊ីចឹង វាក្រៅវិសាលភាពហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

តាមខ្ញុំពិនិត្យមើលសំណួរអំមិញនេះ គាត់បង្ហាញឯកសារហ្នឹង ហើយគាត់គ្រាន់តែសួរពាក្យទេ ដើម្បីឲ្យគាត់ដឹងថាពាក្យ "កម្ទេច"ហ្នឹង គឺមានន័យថាម៉េច។ នេះខាងព្រះរាជអាជ្ញាដែលគាត់សួរ។ ដូច្នេះ គឺសំណួរនេះអាចតាំងបាន។ បាទ សូមអញ្ជើញ។

**លោក សៅ វ៉ន៖**

**ឆ៖** បាន ខ្ញុំសូមធ្វើការបញ្ជាក់ពីចំនួនមនុស្សទាំងអស់ហ្នឹង ខ្ញុំសូមបដិសេធ ខ្ញុំអត់ដឹងទេ។ ក៏ប៉ុន្តែខ្ញុំសុំបញ្ជាក់អំពីពាក្យ "កម្ទេច" គឺថាធ្វើឲ្យខូច, ធ្វើឲ្យខាត បើជីវិតមនុស្សបានន័យថា "ស្លាប់"។ ហ្នឹងសូមមេធាវីជ្រាប។

[១៥:០៥:៣៤]

**សួរដោយលោក នីកូឡាស គូមជែនៈ**

**សៈ** សូមអរគុណ។ ឥឡូវនេះយើងមានចំណុចបន្តទៀតនៅក្នុងឯកសារនេះ ដែលខ្ញុំចង់ពិភាក្សា។ គឺនិយាយអំពីគ្រួសារយោធា មិនមែនអ្នករដ្ឋការ -- មិនមែនជាទាហានដែលផ្ទាល់នោះទេ ប៉ុន្តែគ្រួសារទាហាន។ លោកនិយាយខ្លួនលោកផ្ទាល់ថា បងប្រុសរបស់លោកមានបញ្ហាដោយសារតែតួនាទីរបស់គាត់។ ដូច្នេះថាតើទាហាន លន់ នល់ មានបញ្ហាអ្វីទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆៈ** បាទ ខ្ញុំសូមធ្វើការជម្រាប និង ឆ្លើយ។ គោលនយោបាយកម្ពុជាប្រជាធិបតេយ្យពេលនោះក៏អត់មានអីចង្អុលបង្ហាញគួសវាស។ មានដែលថាឲ្យប្រុងប្រយ័ត្នចំពោះអ្នកចេញពីទីក្រុង ព្រោះមកនេះមានមនុស្សល្អ មនុស្សអាក្រក់។ ប៉ុន្តែបើគេធ្វើសកម្មភាព អានោះបានយើងកសាង។ មានប្រើពាក្យនេះ។ ខ្ញុំមិនបដិសេធទេ ខ្ញុំនៅចងចាំអ៊ីចឹងបាទ។ ដូច្នេះ គ្រួសារទូទៅមិនបាច់តែទាហានគឺទូទៅទាំងអស់សូមជម្រាប។ បើសិនជាជានិយាយថា ចំពោះតែគ្រួសារទាហាន គ្រួសារប៉ូលិស គ្រួសារអី ហាក់ដូចជានៅសង្កត់ នៅតែនេះ។ ហើយចំពោះដោយឡែក អ្នកដែលគេអនុវត្ត អាហ្នឹងជារឿងរបស់គេ តែខ្ញុំ -- សម្រាប់ខ្ញុំ ចាំច្បាស់ តាម៉ុកថា “បើមានសកម្មភាព ធ្វើសកម្មភាព ចាំយើងហៅគេអប់រំកសាង”។ នេះសូមលោកមេធាវីជ្រាប។

[១៥:០៧:២០]

**សៈ** លោកដូចជាមិនទាន់ឆ្លើយសំណួរនៅឡើយទេ ព្រោះថា ឥឡូវគ្រាន់តែថាអ្នកណាម្នាក់ដែលមានសាច់ញាតិជាយោធា។ អ៊ីចឹងមានន័យថាពួកគេប្រព្រឹត្តកំហុស ហើយគេត្រូវទទួលរងនៅការប្រព្រឹត្តផ្ទុយខុសពីអ្នកដទៃ។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ ហ្នឹងហើយប្រព្រឹត្តខុសពីអ្នកដទៃហ្នឹង មិនចូលរួមក្នុងសហករណ៍ ធ្វើការ មានសកម្មភាពប្រឆាំងច្រាស អាហ្នឹងគឺគេមានផែនការអប់រំ កសាង។ សូមអស់យោបល់។

**សៈ** តើជាការត្រឹមត្រូវដែរឬទេដែលថាបក្សមានទស្សនៈផ្សេងទាក់ទងទៅនឹងយោធា លន់ នល់? ថាតើបក្សហ្នឹងយល់ឃើញផ្សេងចំពោះទាហាន លន់ នល់ ដែរទេ?

**ឆៈ** សំណួរនេះ ខ្ញុំឆ្លើយ ដូចឆ្លើយតាំងពីព្រឹកមក បែងចែកថាគ្រួសារយោធាហ្នឹងលន់ នល់ អ៊ីចេះ យោធានោះ គឺអត់។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា បើមានសកម្មភាពអាហ្នឹងត្រូវតែកសាង ត្រូវតែអប់រំហើយ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** លោកសាក្សី តើព្រឹកនេះលោកបាននិយាយថា អង្គការបាននិយាយថា តាម៉ុក ឬក៏មេដឹកនាំបាននិយាយអំពីទាហានៗជាមនុស្សមិនល្អ។ អ៊ីចឹងមែនទេ?

**ឆ៖** សូមឆ្លើយពីព្រឹកមិញ ខ្ញុំដូចអត់មានបាននិយាយថា ទាហានជាមនុស្សមិនល្អ។ ខ្ញុំអត់មាននិយាយទេបាទ។

[១៥:០៩:២៩]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញា លោកនៅមានសល់សំណួរច្រើនទេ? ឥឡូវនេះគឺខាងផ្នែក ឌី.វី.ឌី គឺអស់ហើយ។ បើអ៊ីចឹងសុំឱ្យសម្រាក់មួយនាទីដើម្បីដាក់ ឌី.វី.ឌី បន្ត។

**លោក នីកូឡាស គូមជែន៖**

ឯកឧត្តមប្រធាន ខ្ញុំនៅសល់ប្រហែលជា៣០នាទីទៀត។

*(សម្រាករយៈពេលខ្លី)*

**លោក នីកូឡាស គូមជែន៖**

គឺថា មានការជំទាស់ដដែលៗទៅមកៗ។ ដូច្នេះ យើងខាតពេល១៤នាទីទៅហើយ។ ខ្ញុំរាប់ទៅគឺថាមានការជំទាស់២២ដង។ គឺគេជំទាស់យើងអស់ ២៤នាទី និង២៧វិនាទី។

[១៥:១១:១៨]

**ប្រធានអង្គជំនុំ៖**

តាមការពិភាក្សារបស់ចៅក្រមនៅទីនេះ គឺឃើញថាមានការជំទាស់ច្រើន។ អ៊ីចឹងគឺអាចបន្ថែមពេលវេលាទៅដល់លោកសហព្រះរាជអាជ្ញាបន្ថែមទៀត ប៉ុន្តែគឺអាចត្រឹម១៥នាទីបានទេ? អ៊ីចឹង ១៥នាទីទៀត សូមលោកព្រះរាជអាជ្ញាសួរសំណួរបន្ថែមទៀត។ ប៉ុន្តែសំណួរណាដែលមិនសូវមានភាពពាក់ព័ន្ធហ្នឹងកុំសួរ សួរតែសំណួរណាដែលមានភាពពាក់ព័ន្ធច្រើនជាង។ បាទ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

ឯកឧត្តមប្រធាន ថាតើខ្ញុំបន្តទៀត ឬក៏យើងសម្រាកបន្តិចសិន?

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តបាទ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** គឺមានការបញ្ជាមួយទៀត ពីឯកសារ E3/2048 ខ្មែរមានលេខ 0007909, អង់គ្លេសមានលេខ 00--, បារាំងមានលេខ 00611661។ ហើយឯកសារនេះ គឺថា "ផ្ញើជូនអង្គការជាទីគោរព ស្នើសុំដល់អង្គការដូចតទៅនេះ៖ យើង គឺជាដៃគូរបស់សហករណ៍ ហើយយើងបានពិនិត្យតាមដាន និងបោសសម្អាតខ្មាំងដែលមានឋានៈ បន្ទាប់ពីទទួលបានបញ្ជាពីអង្គការ"។ លោកសាក្សី តើលោកយល់ទេថា តើពាក្យថា "ឋានៈ" ឬក៏ "ឋានន្តរសក្តិ" ហ្នឹង គឺមានន័យថា មន្ត្រី -- ថាតើអ្នកដែលមានឋានន្តរសក្តិហ្នឹងចាប់ពីវរៈឡើងទៅ ឬមួយក៏យ៉ាងម៉េច?

[១៥:១៣:៣៨]

**លោក សៅ វ៉ន៖**

**ឆ៖** សូមធ្វើការជម្រាបជូន ពាក្យ "ឋានន្តរសក្តិ" ខ្ញុំមិនសូវច្បាស់ ហើយមិនសូវយល់ដែរ មិនដឹងផង ព្រោះអត់មានជំនាញ ហើយក៏មិនដែលបានសាកសួរអ្នកចេះដែរ បាទ។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង មិនឆ្លើយអីឲ្យហួសពីហ្នឹងទៀតទេបាទ។ ហួសសមត្ថភាពខ្ញុំ ខ្ញុំមិនឆ្លើយទេ។

**ស៖** ឯកសារមួយទៀត E3/5918, បារាំងមានលេខ ERN00416524 និងអង់គ្លេសមានលេខ 00384400។ លោកសាក្សី -- សាក្សី វ៉ាន់ ផាន ត្រូវបានគេសួរថា "មានការចាប់ខ្លួនដែរឬទេ? ថាតើមានការចាប់ខ្លួនអ្នកប្រជាជន ១៧មេសា ដែរទេ?" ហើយគាត់ឆ្លើយថា "ដំបូងគេសួរអំពីការងារផ្ទាល់ខ្លួន។ គេប្រាប់ដល់ប្រជាជនទាំងអស់នោះ ថានឹងត្រឡប់ទៅធ្វើការងារដូចដើមវិញ ហើយអ្នកដែលមានបទពិសោធន៍ការងារមកជួបជាមួយមេឃុំ ហើយមេឃុំជាអ្នកកត់ត្រា បន្ទាប់ពីប្រមូលប្រជាជនទាំងអស់នោះហើយ លេខាឃុំរាយការណ៍ទៅថ្នាក់លើ ហើយថ្នាក់លើបញ្ជូនឡានមកដឹកមនុស្សទាំងអស់នោះយកទៅ។ អ្នកដែលមកដឹកប្រជាជនទាំងអស់នេះ គឺជាយោធា គឺជាកងទ័ពដែលមានឋានៈចាប់ពីវរៈឡើងទៅ។ ហើយឯកសារបានបន្តទៀតថា គេឲ្យយកគ្រួសារទាំងអស់តែម្តង មិនមែនត្រឹមតែអ្នកមានបណ្តាស័ក្តិប៉ុណ្ណោះ។ ថាតើគេយកទៅប៉ុន្មានដែរ? ចម្លើយ៖ ខ្ញុំមិនដឹងអំពីចំនួនជាក់ស្តែងនោះទេ ប៉ុន្តែខ្ញុំចាំថា គឺដឹកពេញៗឡានតែម្តង ហើយខ្ញុំមិនដឹងថាគេយកទៅសម្លាប់ ឬអត់នោះទេ។ ខ្ញុំគិតថា គេយកទៅធ្វើការដូចអ្វីដែលគេបានប្រាប់អ៊ីចឹង។ ខ្ញុំស្គាល់ម្នាក់ឈ្មោះ ស៊ឹម នៅក្នុងឆ្នាំ៧៥ គាត់ជាប៉ូលិសនៅស្រុកទ្រាំង ហើយគាត់ឡើងឡាន ព្រោះថាថ្នាក់លើបញ្ជាៗឲ្យយកតែអ្នកមានបណ្តាស័ក្តិតែប៉ុណ្ណោះ។ ហើយអ្នកដែលគេយកទៅហ្នឹង មិនដែលឃើញត្រឡប់មកវិញទេ ហើយខ្ញុំមិនដែលឃើញ

ត្រឡប់ គឺបាត់ខ្លួនជារៀងរហូត។ នៅពេលនោះខ្ញុំសង្ស័យថា ប្រហែលជាគេយកទៅសម្លាប់នៅអង្គរជ័យហើយមើលទៅ។ សំណួរៈ តើលោកដឹងថា មានគុកនៅអង្គរជ័យដែរឬទេ? ខ្ញុំដឹងថា ជាមន្ទីររបស់ តាមន។" តើលោកសាក្សី លោកដឹងទេ ថាមានមន្ទីរសន្តិសុខនៅតាមន ដែលនៅជិតភ្នំមួយដែលលោកនិយាយពីព្រឹកមិញនេះ គឺភ្នំដែលលោកទៅចូលរួមការប្រជុំ គឺភ្នំត្រែងនោះដែរឬទេ?

[១៥:១៧:០០]

**ផៈ** បាទ ខ្ញុំសូមធ្វើការជម្រាប ចំពោះសំណួរនិងឯកសារទាំងអស់នេះ គឺមិនមែនស្ថិតនៅក្នុងដៃខ្ញុំ ហើយក្នុងឃុំរបស់ខ្ញុំផងទេ។ អ៊ីចឹងអ្វីដែលខ្ញុំឆ្លើយ គ្មានការពិត ខ្ញុំមិនៗនិយាយទេ បាទសូមសិទ្ធិមិនឆ្លើយ តែខ្ញុំសូមឆ្លើយថាមន្ទីរអីសម្លាប់មនុស្សអីនៅក្នុងឃុំ ស្រុក១០៦នោះ បច្ចុប្បន្នអង្គរជ័យនោះ ក៏ខ្ញុំអត់ដឹងដែរ ព្រោះអានេះខ្ញុំហួសក្របខ័ណ្ឌដែលៗខ្ញុំ -- ខ្ញុំមានតួនាទីត្រឹមតែមេឃុំ។ អ៊ីចឹងរាល់ការងារអ្វីៗទាំងអស់ ខ្ញុំក្ដោបក្ដាប់ចំពោះតែឃុំរបស់ខ្ញុំបាទ។ ហើយចំពោះភ្នំត្រែលហ្នឹងតែម្ដងទេ ទៅហ្នឹងដោយសារចប់សង្គ្រាមទៅ អង្គការ -- តាសោម គាត់ហៅទៅជួបជុំគ្នាហ្នឹង តាំងពីអ្នកក្នុងស្រុកអង្គរជ័យស្រុក១០៨, ១០៩ ហ្នឹង។ អ៊ីចឹងខ្ញុំសូមជម្រាបហ្នឹងបាទ សូមៗសិទ្ធិឆ្លើយប៉ុណ្ណឹង បាទ។

**សៈ** ហើយលោកនិយាយថា ការប្រជុំហ្នឹង គឺមានទាំងយោធា ទាំងអ្នករដ្ឋការ លន់ នល់ ត្រូវបានគេអញ្ជើញ។ គឺថាលោក គឺថាមានការនិយាយថា -- ប៉ុន្តែលោកក៏និយាយថាៗ អ្នកដែលមានបណ្ដាស័ក្តិរហូតដល់ស័ក្តិ៥ គេអត់ទទួល អត់ត្រូវប៉ះពាល់ទេ។ តើមួយណាដែលត្រឹមត្រូវ?

**ផៈ** ចំពោះខ្លឹមសារនិងទ្រឹស្តី ខ្ញុំសូមឆ្លើយ ច្បាប់គឺត្រឹមត្រូវ ក៏ប៉ុន្តែអ្នកអនុវត្តដោយឡែក អាហ្នឹងខ្ញុំមិនដឹងទេ តែចំពោះខ្ញុំ ខ្ញុំនៅតែអនុវត្តក្រឹត្យក្រមហ្នឹង សម្រាប់ជីវិតមនុស្សទូទៅ បាទ មនុស្សនៅក្នុងឃុំខុសឆ្គងបន្តិចបន្តួច ខ្សឹបប្រាប់អប់រំណែនាំ បាទ ហើយក៏មិនមែនជាអ្នកតាមដានចាប់គំនុំអីអត់ទេ។ ខ្ញុំៗសូមជម្រាបបាទ ចំពោះលោកអ្នកសំណួរ ម្ចាស់សំណួរ សូម បាទ សូមសម្រួលឡើងវិញផងដែរ។ ការសួរនេះហាក់ដូចជាដដឹក បាទ សូមអធ្យាស្រ័យ សូមអស់យោបល់។

[១៥:១៩:២៩]

**សៈ** សូមអរគុណលោក ប៉ុន្តែនេះមិនមែនជាអ្វីដែលខ្ញុំចង់សួរទេ ប៉ុន្តែយើងជិតៗចប់ហើយលោក ប៉ុន្តែថាលោកមិនដឹងអំពីការអនុវត្តដែរឬទេ ខ្ញុំដឹងថាលោកមិនដឹងថាមានអ្វីកើតឡើងចំពោះមនុស្សទាំងអស់នេះ ប៉ុន្តែលោកដឹង ព្រោះលោកបានប្រាប់យើងព្រឹកមិញនេះថា ទាហាន ហើយនិងអ្នករដ្ឋការ ត្រូវបានគេអញ្ជើញទៅកិច្ចប្រជុំ គឺគេកំណត់អត្តសញ្ញាណ ហើយគេប្រមូលយកទៅទីនោះ។ តើអ៊ីចឹងមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំមិនយល់ ហើយខ្ញុំហាក់ដូចជាតាមមិនទាន់ថា ព្រះរាជអាជ្ញាគាត់និយាយពីអ្វីនោះទេ។ គឺថាសាក្សីគាត់និយាយអំពីការប្រជុំនៅភ្នំ ប៉ុន្តែភ្នំហ្នឹងគឺការប្រជុំរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាទេ មិនមែនជាការប្រជុំរបស់យោធា ឬក៏រដ្ឋការលន់នល់នោះទេ ហើយសាក្សីគាត់មិនបាននិយាយអំពីចំណុចនេះទេ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាអាចសម្រួលសំណួរឡើងវិញ!

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម បើតាមដែលខ្ញុំចាំ គឺថាគេនិយាយអំពីយោធា ហើយនេះជាចំណុចសំខាន់ ហើយខ្ញុំប្រហែលជាត្រូវនិយាយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី នៅក្នុងភាសាខ្មែរ គឺថា "ទាហានត្រូវបានគេយក"។ ហើយនៅពេលដែលគេនិយាយថាពាក្យថា "ទាហាន" នៅពេលនោះ ថាតើគឺមានន័យថា គេសំដៅទៅលើទាហានលន់នល់ ព្រោះពាក្យ "កងទ័ព" គឺគេនិយាយអំពីខ្មែរក្រហម។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមធ្វើការជម្រាបជូន ហើយនិងសូមឆ្លើយ ពេលប្រជុំនៅភ្នំត្រែលហ្នឹង គឺអញ្ជើញតែកងទ័ពខាងខ្មែរក្រហមទេបាទ អត់មានអញ្ជើញកងទ័ពណាទេ អញ្ជើញហ្នឹងទៅផ្សាយឲ្យទូលាយដើម្បីឲ្យបងប្អូនគេ ដែលធ្វើកងទ័ពហ្នឹង ដែលមានបងប្អូនគេចេញពីទីក្រុងភ្នំពេញអី គេសប្បាយ គេរីករាយ បាទ អាហ្នឹងគឺការផ្សាយ ការលើកឡើង គឺបញ្ជាក់ប៉ុណ្ណឹង បាទ សូមអស់យោបល់។

**ស៖** នៅក្នុងការប្រជុំ គឺមានការជំរុញឲ្យអ្នករដ្ឋការចេញមកបង្ហាញខ្លួន។ តើអ៊ីចឹងមែនទេ?

[១៥:២២:០១]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

គឺថាសាក្សីមិនបាននិយាយបែបនេះទេ គឺគាត់និយាយអំពីកងទ័ពដែលមកចូលរួម។ ដូច្នេះអ្វីដែលយើងអាចនិយាយបែបនេះបាន ប៉ុន្តែគឺថា សាក្សីគាត់មិនបាននិយាយថា ឲ្យមានការជំរុញឲ្យកងទ័ព ឬក៏ទាហានបង្ហាញខ្លួននោះឡើយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ឯកសារដែលខ្ញុំបង្ហាញ និងចម្លើយរបស់សាក្សីបាននិយាយអំពីការអនុវត្តឬក៏ការស្វែងរក និងចាប់ខ្លួន ព្រមទាំងបោសសំអាតទាហាន ឬក៏អ្នករដ្ឋការ។ ថាតើលោកដឹងដែរឬទេថាតើមានគោលនយោបាយបែបនេះ ហើយមានការអនុវត្តគោលនយោបាយបែបនេះដែរឬទេ គឺគោលនយោបាយរបស់ តាម៉ុក និងថ្នាក់លើឬក៏អត់? ឬក៏លោកអត់ដឹងថាមានគោលនយោបាយបែបនេះទេ?

**លោក សៅ វ៉ន៖**

**ឆ៖** សូមឆ្លើយ ដូចជាមិនសូវយល់ប្រាកដពីសំណួរបាទ ប៉ុន្តែអ្វីទាំងអស់ដូចជាខ្ញុំឆ្លើយបានគ្រប់គ្រាន់ហើយ សូមអស់យោបល់ហើយ។ ខ្ញុំស្តាប់សំណួរអត់បានអំមិញ។

**ស៖** តើលោកធ្លាប់ដែរឃើញខ្មែរក្រហមប្រើវិធីសាស្ត្របោកបញ្ឆោតមនុស្សដែរឬទេ? ហើយដែលបោកបញ្ឆោតឲ្យប្រជាជននិយាយថា ពួកគេយកគាត់ទៅជួបស្តេច ឬក៏យកទៅការងារកន្លងមក ឬក៏យករៀនសូត្របន្ថែម ដើម្បីឲ្យប្រជាជនបង្ហាញខ្លួន ហើយបន្ទាប់មកទៀត គឺត្រូវបានគេចាប់ខ្លួន។ តើលោកធ្លាប់ឃើញវិធីសាស្ត្រហ្នឹងដែរទេ?

**ឆ៖** បាទ សូមធ្វើការជម្រាប គឺវិធីសាស្ត្ររបៀបហ្នឹង ខ្ញុំអត់ដែលបានទទួល ហើយអត់ដែលបានដឹងទេបាទ។ ក៏ប៉ុន្តែសូមធ្វើការបញ្ជាក់ជម្រាបថា ការអនុវត្តរបស់មាគ៌ាកម្ពុជាប្រជាធិបតេយ្យធ្វើកិច្ចការអ្វីៗហ្នឹង គឺកិច្ចការណាហ្នឹងគឺថាទៅតាមថ្នាក់ ថ្នាក់ខេត្តដឹងតាមថ្នាក់ខេត្តអ៊ីចឹងទៅ ឯថ្នាក់ឃុំអប់រំទៅតាម ដឹងយល់ទៅធ្វើនេះទេ ហើយចំពោះទាក់ទងទៅបញ្ជូនមនុស្សម្នាផងទាំងពួងហ្នឹង គឺអត់ទេ អត់បានផ្សព្វផ្សាយឲ្យដឹងទេ បាទ។ មូលហេតុហ្នឹង ខ្ញុំសូមបញ្ជាក់ខ្លឹមសារ គឺលាក់ការណ៍ លាក់ត្រង់ណា បើការដឹងទូទៅ ខ្លាចក្រែងមិនជិត ដូចថាការងារហ្នឹងធ្វើទៅវាទុលុងទុងទាំង ម្ល៉ោះហើយវាកើតចលាចលក្នុងភូមិ ឃុំ ស្រុក។ បាទ អានេះគ្រាន់បញ្ជាក់ប៉ុណ្ណឹង ការយល់របស់ខ្ញុំទេ។ ចំពោះនៅឃុំខ្ញុំអត់ដែលមានមកបញ្ជូន ឬក៏មកអូសទាញ ឬក៏ស្រង់យកទៅអ៊ីចេះអ៊ីចុះ តាម៉ុក មកចង្អុលបង្ហាញ ឬមានមតិណែនាំសារាចរអត់ទេ។ បាទ សូមជម្រាប និងអស់យោបល់ប៉ុណ្ណឹងបាទ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន តើខ្ញុំនៅសល់ពេលប៉ុន្មានទៀត ដើម្បី--

**ប្រធានអង្គជំនុំ៖**

សល់បីនាទីទៀតបាទ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ក្នុងករណីនេះលោកសាក្សីៗ លោកបាននិយាយថា លោកធ្លាប់ទៅក្រាំងតាចាន់ ហើយឃើញបានលលាដ៍ក្បាលខ្មោច។ តើមាន -- គឺថាក្បាល -- ឆ្អឹងខ្លះត្រូវបានបាត់បង់ពីទួលស្លែង និងក្រាំងតាចាន់។ ហើយទាហានលន់ នល់ ជាច្រើនត្រូវបានគេយកទៅសម្លាប់ទីនោះ។ លោកមានមូលហេតុថាហេតុអីបានជាគេយកអ្នកទាំងនោះទៅសម្លាប់នៅក្រាំងតាចាន់ដែរទេ?

[១៥:២៦:២៥]

**លោក សៅ វ៉ន៖**

**ឆ៖** បាទ ខ្ញុំសូមធ្វើការជ្រាបពិត។ ពីឆ្នាំ៧១ ទល់នឹង ៧៥ គឺអត់ដែលបានទៅដឹងយល់មានក្រាំងតាចាន់ទេបាទ។ ហើយដល់ ៧៦-៧៧ ខ្ញុំក៏ចេញពីស្រុកត្រាំកក់ហ្នឹងទៅ ចេញពីភូមិជាងទងទៅ តែដល់ត្រឡប់ចូលមកវិញនៅឆ្នាំប៉ែតប្លាយ កៅប្លាយនេះ ដែលអង្គការ និងព្រះសង្ឃបបួលបងប្អូនទៅបង្សុកូល ហើយខ្ញុំក៏បានទៅ បានខ្ញុំដឹងឃើញនៅក្រាំងតាចាន់ហ្នឹងមានលលាដ៍ ព្រះកេស បងប្អូនដែលបានស្លាប់នៅទីនោះ។ បាទ ខ្ញុំសូមធ្វើការបញ្ជាក់ជម្រាបប៉ុណ្ណឹង។

**ស៖** លោកសាក្សីតាមដែលលោកដឹង គោលនយោបាយដែលលោកបានស្តាប់ឮពី សោម ហើយនិងពី ម៉ុក តើមានអ្វីកើតឡើងចំពោះឧត្តមសេនីយ៍មួយចំនួននៃរបប លន់ នល់?

**ឆ៖** បាទ ខ្ញុំសូមធ្វើការឆ្លើយជម្រាបដោយខ្ញុំមិនបានតាមដានល្អិតល្អន់ខាងហ្នឹងទេបាទ។ ដូច្នេះខ្ញុំមិនអាចសន្និដ្ឋានឲ្យខុសពីការពិតដែលខ្ញុំមិនដឹងទេបាទ សូមអស់យោបល់។

[១៥:២៨:០១]

**ស៖** នៅពេលដែលលោកស្តាប់ឮ ខៀវ សំផន គាត់និយាយនៅលើវិទ្យុ និយាយអំពី ឡុង បូរ៉េត, សិរិមតៈ ហើយនិងបុគ្គលប្រាំពីរនាក់ទៀតដែលជាគោលដៅ។ តើលោកស្តាប់ឮហ្នឹងមុន ឬក្រោយពេលទីក្រុងភ្នំពេញដួលរលំនៅថ្ងៃ១៧ មេសា ១៩៧៥?

**ឆ៖** បាទ ខ្ញុំសូមធ្វើការជម្រាបជូន នៅពេលនោះ អត់សូវមានវិទ្យុទេ។ ដូច្នេះ ខ្ញុំផ្ទៀងត្រចៀកមានវិទ្យុមួយផ្ទៀង។ មុនរំដោះទូទាំងប្រទេស ពេលនោះខ្ញុំស្តាប់បាននៅខាងក្នុងគ្រវែងចេញ ចរចាសន្តិភាព។ ហើយខាងក្រៅខ្ញុំស្តាប់ថា--

**ស៖** ពេលវេលាខ្ញុំខ្លីណាស់លោកសាក្សី សូមឆ្លើយឲ្យចំនឹងសំណួររបស់ខ្ញុំ។ តាមការផ្សាយតាមវិទ្យុផ្សាយសំឡេងមុនរំដោះហ្នឹង តើ ខៀវ សំផន ជំរុញឲ្យកងទ័ពយកជ័យជម្នះ ឬក៏ តើបង្ខំឲ្យទាហាន

ខ្មែរក្រហមហ្នឹងណ៎ា យកជ័យជម្នះដើម្បីខាងខ្មែរក្រហម ឬដើម្បីខាងសម្ដេច សីហនុ?

**ឆ៖** សូមធ្វើការបញ្ជាក់ជម្រាបជូនក្នុងខ្លឹមសារនោះគឺ ខ្ញុំស្ដាប់អ៊ំ ខៀវ សំផន គាត់លើកឡើងហ្នឹងមុនរំដោះទូទាំងប្រទេសបាទ។ ឯអ្នកជំរុញឲ្យកងរំដោះជាតិ និងសម្រុករំដោះទីក្រុងភ្នំពេញគឺ តាម៉ុក បាទ។ ពេលហ្នឹងគាត់ធ្វើ គេហៅថាសន្និបាតកងទ័ពមួយខេត្តចូលរួមធ្វើជាមីទ្ទីង ហើយគាត់ប្រកាសនៅភូមិអូរសារ៉ាយក្នុងព្រៃ -- មិនព្រៃទេ វេលាយប់។ គាត់ប្រកាសសុំឲ្យកងទ័ពទាំងអស់ចូលរំដោះទីក្រុងភ្នំពេញ។ អាហ្នឹងគឺសម្ដី តាម៉ុក បាទ។ ហើយចំពោះអ៊ំ ខៀវ សំផន គាត់និយាយមុន --

[១៥:៣០:២៣]

**ស៖** លោកមិនទាន់ឆ្លើយសំណួរខ្ញុំនៅឡើយទេ ប៉ុន្តែខ្ញុំសូមបន្តទៅសំណួរចុងក្រោយ ដោយសារតែពេលវេលា។ តើលោកស្ដាប់ឮ ខៀវ សំផន ប្រើពាក្យយ៉ាងម៉េច ដើម្បីរៀបរាប់សំដៅទៅលើទាហាន លន់ នល់ ដូចជាពាក្យថា "ទាហានស៊ីឈ្នួល" អ៊ីចឹង?

**ឆ៖** ខ្ញុំសូមធ្វើការជម្រាប និងឆ្លើយនៅម្ចាស់សំណួរ បាទ។ ពេលនោះ អ៊ំ ខៀវ សំផន គាត់អត់មានប្រកាសថាទាហានស៊ីឈ្នួលអីទេ បាទ។ គាត់ថា សុំអំពាវនាវឲ្យប្រជាជនទាំងអស់ ទាំងសិស្សទាហាន ប៉ូលិស គ្រូបង្រៀន ទាហាន ប៉ូលិស អ្នករដ្ឋការ នៅទីក្រុងភ្នំពេញ -- ទូទាំងប្រទេស ចូលរួមក្នុងរណសិរ្សរួមរួបជាតិកម្ពុជា។ រណសិរ្សរួមរួបជាតិកម្ពុជាលើកលែងទោស។ ឯរណសិរ្សរួមរួបជាតិកម្ពុជាវិនិច្ឆ័យ និងកាត់ទោសប្រហារជីវិត តែលន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, អ៊ិន តាំ, សុស្តែន, ឡុង បូរ៉េត តែប្រាំពីររូបហ្នឹងទេ បាទ។ នេះជាការពិត ហើយខ្ញុំពេលហ្នឹង ខ្ញុំស្ដាប់នៅកន្លែងទំនប់ ដែលខ្ញុំជីកទំនប់ លើកទំនប់នៅលើផ្លូវលំ។ បាទ ខ្ញុំសូមអស់យោបល់ហើយ បាទ។

**ឆ៖** លោកសាក្សី បើមានគោលនយោបាយអនុគ្រោះទោសទៅដល់កូនទាហាន តើហេតុអ្វីចាំបាច់ត្រូវធ្វើសរសេរប្រវត្តិរូបឲ្យទាហានទាំងនោះបញ្ជាក់អំពីអត្តសញ្ញាណ និងបុណ្យស័ក្តិរបស់ខ្លួន។ តើមានតម្រូវការអីដែលតម្រូវឲ្យធ្វើ ឲ្យធ្វើប្រវត្តិរូប?

[១៥:៣១:៥៦]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំសូមជំទាស់។ នេះជាការសំណួរមួយដែលមានការចម្រូងចម្រាស។ ប្រវត្តិរូបនេះ គឺថាវាមិនមែនមានតែទាហាន អតីតទាហានលន់ នល់ ទេ ទាំងកម្មាភិបាលរបស់ខ្មែរក្រហមខ្លួនឯងក៏ត្រូវតែធ្វើប្រវត្តិរូប។ ម្នាក់ៗត្រូវតែសរសេរប្រវត្តិរូបទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា ឥឡូវនេះ គឺយើងដល់ម៉ោង ហួសពីការបន្ថែមទៀតទៅហើយ។ អ៊ីចឹងលោកនៅមានសំណួរប៉ុន្មានទៀត ឬក៏អស់ហើយ?

[១៥:៣៣:០៥]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន នៅលើប្រធានបទនេះ ខ្ញុំអាចចប់នៅពេលនេះ។ តាមពិតទៅមានសំណួរច្រើនដែលត្រូវសួរ។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី ដោយសារតែពេលវេលា គឺថាខ្ញុំឈប់ត្រឹមប្រធានបទនេះប៉ុណ្ណេះទៅចុះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ហើយនៅវេលាម៉ោងដប់ប្រាំ និងហាសិបនាទី នឹងចូលមកបន្តសវនាការទៅទៀត។

**ក្រឡាបញ្ជី៖**

អញ្ជើញក្រោកឈរ បាទ!

*(សវនាការសម្រាកពីម៉ោង ១៥:៣៣ នាទី ដល់ម៉ោង ១៦:០០ នាទី)*

[១៦:០១:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ! អង្គជំនុំជម្រះសូមប្រកាស បន្តសវនាការ។ ជាបន្តនេះ គឺសូមអញ្ជើញលោកចៅក្រម ម៉ុង មុន្នីចរិយាគឺ តាំងសំណួរដល់សាក្សី។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

បាទ ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តមប្រធាន ក្រុមប្រឹក្សាជំនុំជម្រះ ហើយក្នុងឱកាសនេះក៏សូមបញ្ជាក់ជូនដល់លោកសាក្សីដែរ ប្រហែលជាអាចហត់នឿយបន្តិចហើយថ្ងៃនេះ។ ប៉ុន្តែសូមមេត្តាទ្រាំបន្តិចណ៎ះ!ជិតចប់ហើយ។

**សួរដោយចៅក្រម ម៉ុង មុន្នីចរិយា៖**

**ស៖** អ៊ីចឹងតាមការស្តាប់នូវការផ្តល់សក្ខីកម្ម អម្បាញ់មិញរបស់សាក្សី គឺថាយើងមានបញ្ហា

មួយចំនួន ដែលហាក់បីដូចជាមិនទាន់មានភាពច្បាស់លាស់។ អ៊ីចឹង សំណួរនៅទីនេះ ជាសំណួរទី១ របស់ខ្ញុំ។ ខ្ញុំចង់ឱ្យសាក្សី លោកបានបញ្ជាក់អម្បាញ់មិញ ឱ្យបានច្បាស់បន្តិចនៅពេលដែលពាក្យថា លោកទៅចូលរួមប្រជុំក៏ដោយ ក៏ដូចជានៅក្នុងការដែលលោកអនុវត្តការងារប្រចាំថ្ងៃ ក្នុងនាមជាលេខាឃុំ ថាតើពាក្យថា "ខ្មាំង" ហ្នឹង ដែលបានប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ជាពិសេសនៅកន្លែងដែលលោកអនុវត្តផ្ទាល់ តើពាក្យថា "ខ្មាំង" ហ្នឹង លោកផ្តល់អត្ថន័យយ៉ាងម៉េចហើយ? តើមានការបែងចែក តើមនុស្សប្រភេទណាចាត់ទុកថាជាខ្មាំងបាន? សូមអញ្ជើញ!

**លោក សៅ វ័ន៖**

**ឆ៖** បាទ ខ្ញុំសូមធ្វើការបញ្ជាក់ និងឆ្លើយជាសំណួររបស់លោកមេធាវី។ បញ្ជាក់នូវពាក្យថា "ខ្មាំង" សម្រាប់ខ្ញុំ ហើយនិងគេកំណត់ជាទុកថាខ្មាំងហ្នឹងគឺ អ្នកប្រឆាំងនឹងបដិវត្ត ប្រឆាំងនឹងសហ-ករណ៍។ ប៉ុន្តែដោយឡែក ខ្ញុំសូមលើកឧទាហរណ៍សម្រាប់ខ្ញុំ ពាក្យ "ខ្មាំង" នេះមិនៗដែលយកមកលើកឡើងនៅចំពោះមុខអង្គប្រជុំទេ ឧទាហរណ៍ –ខ្ញុំសូមលម្អិតបន្តិចចុះពាក្យហ្នឹង– ដែលអ្នកខ្លះគេប្រើពាក្យ "ខ្មាំង" ឧទាហរណ៍ សមាជិកទៅក្នុងសហករណ៍ហ្នឹងគាត់ព្បួរ ក្រុមព្បួរអ៊ីចឹងទៅ បាក់ជន្លួញទន្ល័លហ្នឹង អ៊ីចឹងនិយាយលើកឡើងថា "ខ្មាំង" ហើយៗគេចោទប្រកាន់ជាចំណោទ ចោទប្រកាន់ថា គាត់ហ្នឹងបំផ្លាញសម្ភារៈដើម្បីធ្វើឱ្យខាតបង់ ក្នុងកិច្ចការបង្កបង្កើនផល ហ្នឹងសូមជម្រាបប៉ុណ្ណឹង។ មួយទៀតចំពោះគ្នាដែលធ្វើការទៅមានសុខភាពឈឺថ្កាត់ ឬធ្វើមិនទាន់ មិនទៅដល់កន្លែងការដ្ឋាន ឧទាហរណ៍ម៉ោងមួយ ឬម៉ោងប្រាំពីរព្រឹក ប៉ុនគ្នាបើទៅមិនទាន់ដល់ នោះក៏ អ្នកដែលមិនយល់ពាក្យទាំងអស់នោះក៏បានលើកឡើងថាខ្មាំង។ ពាក្យ "ខ្មាំង"មួយម៉ាត់នេះ ហាក់ដូចជាសង្កត់ ដើម្បីឱ្យសមាជិកទាំងអស់មានការរួញខ្លាច ដាក់ -- ខ្លាច សូម្បីតែខ្ញុំហ្នឹងក៏ខ្លាចដែរ ខ្លាចគេថាខ្មាំង។ បាទ សូមអស់យោបល់បញ្ជាក់ប៉ុណ្ណេះ។

[១៦:០៥:០០]

**ស៖** តែឥឡូវខ្ញុំចង់សួរបញ្ជាក់បន្ថែមលក្ខណៈពិសេសបន្តិចចំពោះអត្ថន័យនេះ។ ឧទាហរណ៍ថា ឥឡូវជាទាហាននៃរបបហៅថារបបមុន ខ្ញុំថារបប លន់ នល់ ចុះ។ តើអ្នកទាំងនោះបើសិនជាមានរស់នៅក្នុងមូលដ្ឋានរបស់លោក ដែលក្នុងនាមលោកជាមេឃុំហ្នឹង តើហ្នឹងទាំងនោះយើងចាត់ទុកជាខ្មាំងទូទៅ ឬក៏លុះត្រាតែអ្នកនោះធ្វើសកម្មភាពប្រឆាំង បានយើងចាត់ទុកជាខ្មាំង?

**ឆ៖** បាទសូមឆ្លើយ សម្រាប់ខ្ញុំមិនមែនចាត់អ្នកទាំងនោះជាខ្មាំងទេ ខ្ញុំកត់សម្គាល់ថាជាកូន

អ្នកស្រុក ប៉ុន្តែដោយបញ្ជាក់នឹងខ្លឹមសារ ខ្ញុំប្រាប់ទៅដល់រាល់កម្មាភិបាលក្រោមថ្នាក់ថាពាក្យ “ខ្មាំង” មួយម៉ាត់នេះ ចំពោះទាហាន ប៉ូលិស ឬអ្នករដ្ឋការអ្វីដ៏ដោយ នេះបុគ្គលទូទៅបើគេធ្វើសកម្មភាពប្រឆាំង បំផ្លិចបំផ្លាញ ឬចលនាបំផុសបំផុល បង្កើតជាកុបកម្ម បាតុកម្ម អាណោះចាំយើងលើកឡើងថា ខ្មាំង។ នេះការលើកឡើងបញ្ជាក់របស់ខ្ញុំ។ សូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** បាទ សូមអរគុណ។ មួយទៀតទាក់ទងទៅនឹងបញ្ហាដែលលោកលើកឡើងអំពីកិច្ចប្រជុំចំនួនពីរ។ ពេលខ្លះលោកប្រើពាក្យថា “កិច្ចប្រជុំរៀនសូត្រ” ហើយពេលខ្លះបានប្រើពាក្យថាជា “សន្និបាត”។ ហើយក៏តាមការសង្កេតរបស់ខ្ញុំ ក៏ឃើញថា ក្នុងកិច្ចជំនុំជម្រះនេះមានការច្រឡំអំពីពេលវេលាផងដែរ។ អ៊ីចឹងទាំងពីរកិច្ចប្រជុំនេះដែលលោកបានចូលរួម។ មានន័យថា កិច្ចប្រជុំបានធ្វើនៅមុនឆ្នាំ -- មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥? ឬក៏កិច្ចប្រជុំទាំងពីរនេះ ធ្វើនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៥? បាទ សូមបញ្ជាក់អំពីពេលវេលា។

[១៦:០៧:២២]

**ប្រធានអង្គជំនុំ៖**

លោកៗសាក្សីកុំអាលឆ្លើយ មិនទាន់មានភ្លើង។

**លោក សៅ វ៉ាន់៖**

**ឆ៖** បាទខ្ញុំសូមធ្វើការបញ្ជាក់ជម្រាបជូន។ ពាក្យថា “សន្និបាត” និង “រៀនសូត្រ”។ អ៊ីចឹង ពី ៧១ ទៅនឹង ៧៥ នៅក្នុងសង្គ្រាម គឺពាក្យ “សន្និបាត”ហ្នឹង ចូលទៅហ្នឹងគឺរៀនសូត្រផង សន្និបាតផង។ ពេលនោះសន្និបាត គឺបូកសរុបលទ្ធផលនៃការបង្ករបង្កើនផលនៅតាមស្រុកមួយៗ ឃុំមួយៗ លើកក្នុងអង្គក្នុងសន្និបាត ហ្នឹងមួយ។ ឯមួយទៀត លើកអំពីការរាយការណ៍អំពីការជ័យជម្នះ នៅខេត្តតាកែវថាតំបន់នេះរំដោះបានៗ។ ហ្នឹងអំពីសន្និបាតបូកសរុបសេដ្ឋកិច្ចអ៊ីចឹងបាទ។ ហើយខ្ញុំសូមបន្តអំពីការរៀនសូត្រ ក្នុងនោះក៏មានការរៀនសូត្រដែរ។ ការរៀនសូត្រមានឯកសាររណសិរ្សរួបរួមជាតិកម្ពុជា បាទ ហើយនិងរណសិរ្សក្រុមប្រវាស់ដៃហ្នឹង។ ក្រុមប្រវាស់ និងកងបង្កើនផលហ្នឹង បាទ។ អ៊ីចឹងសូមលើកឡើងបញ្ជាក់ប៉ុណ្ណឹង។ ឬមួយក៏លោកឲ្យ អនុញ្ញាតឲ្យខ្ញុំលម្អិតអំពីលក្ខណៈរៀនសូត្រហ្នឹង បាទ? សូមអស់យោបល់។

**ស៖** អ៊ីចេះ សូមលោកសាក្សីស្តាប់សំណួរខ្ញុំឲ្យច្បាស់ ទីនេះខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់អំពីបញ្ហាពេលវេលា។ ថាតើកិច្ចប្រជុំទាំងពីរហ្នឹង ធ្វើឡើងក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥? ឬក៏ក្រោយ?

**ឆ៖** បាទ សូមឆ្លើយ ចំពោះសន្និបាតបូកសរុប គឺធ្វើមុនឆ្នាំ១៩៧៥ គឺមួយឆ្នាំធ្វើម្ដងៗ បាទ នៅក្នុងព្រៃ។ មួយឆ្នាំបូកសរុបម្ដង បាទ។ អាហ្នឹងសន្និបាត។ ឯរៀនសូត្រនៅក្រោយឆ្នាំ៧៥ហ្នឹង រៀនសូត្រនៅភ្នំត្រែលហ្នឹង គឺទៅរៀនសូត្រតែមួយព្រឹកទេ។ បាទហ្នឹងរៀនសូត្រ គឺផ្សព្វផ្សាយពីមាគ៌ាអប់រំប្រជាជនដើម្បីសម្រាលកំហឹងរវាងអ្នកទីក្រុង និង អ្នកជនបទបាទ។ សូមលើកឡើងបញ្ជាក់ ជម្រាប។ អស់យោបល់បាទ។

[១៦:១០:២៨]

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់សម្ដីរបស់លោកបន្តិចថា ដែលលោកចាំអំពីកិច្ចប្រជុំទាំងពីរ កាលពីព្រឹកមិញ គឺលោកបានលើកឡើងថា កិច្ចប្រជុំទី១ នៅខេត្តតាកែវ។ កិច្ចប្រជុំទី២ នៅភ្នំត្រែង។ អ៊ីចឹងបើសិនជាតាមខ្ញុំយល់ លោកថា ប្រជុំមុនពី៧១ រហូតដល់៧៥ ក៏មានដែរ ប៉ុន្តែដូចជាមិនទាន់បានបញ្ជាក់បានច្បាស់លាស់ ថាតើលោកសំដៅលើនៃប្រជុំមួយណា ដែលលោកបានឡើងថាប្រជុំតែពីរដងនោះ។ អ៊ីចឹងភ្នំត្រែងខ្ញុំយល់ហើយ លោកបញ្ជាក់អម្បាញ់មិញថា ប្រជុំនៅភ្នំត្រែង គឺជាប្រជុំរៀនសូត្រក្រោយឆ្នាំ៧៥ ប៉ុន្តែប្រជុំមួយទៀតនៅតាកែវ តើធ្វើនៅក្នុងឆ្នាំណា?

**ឆ៖** បាទ សូមជម្រាប ប្រជុំនៅតាកែវ ក្រោយឆ្នាំ១៩៧៥ បាទ សូមលោកជ្រាប។ សូមអស់យោបល់។

**ស៖** តាមការលើកឡើងរបស់លោកកាលពីព្រឹកមិញថា នៅក្នុងកិច្ចប្រជុំមួយនោះ គឺថាមានការចូលរួមរបស់ តាម៉ុក ហើយពេលនោះ គឺថាលោកមិនបានឮ តាម៉ុក និយាយទេ ប៉ុន្តែឮថា ពួតាសោម បាននិយាយអំពីការហាមមិនឲ្យមានការប៉ះពាល់ទាហាន លន់ នល់។ ថាតើនៅពេលដែលលោក តាម៉ុក ដែលបានឮនូវការ សេចក្ដីថ្លែងការណ៍ ឬក៏ការនិយាយរបស់តាសោមហើយ ថាតើប្រតិកម្មរបស់តាម៉ុក នៅពេលនោះយ៉ាងម៉េចដែរ គាត់ហាម ឬក៏គាត់យល់ព្រមចំពោះការលើកឡើងនេះ?

**ឆ៖** បាទ ខ្ញុំសូមធ្វើការជម្រាបជូន។ ពេលដែល តាសោម គាត់ប្រកាស ពេលនោះតាម៉ុក អត់មានប្រតិកម្មអីដែរទេបាទ ព្រោះមាគ៌ាពេលនោះ គឺថ្នាក់ក្រោមគោរពថ្នាក់លើ។ អ៊ីចឹងខ្ញុំទទួលស្គាល់ថា តាសោម បានសម្ដីនេះយកមកប្រកាស គឺបានពី តាម៉ុក ពីគណៈភូមិភាគហ្នឹងផងដែរ បាទ។ សូមអស់យោបល់។

[១៦:១៣:២៣]

**ស៖** សូមមួយទៀត។ កាលពីព្រឹកមិញក៏លោកបានផ្ដល់សក្ខីកម្មដែរថា អំណាចទាក់ទងការ

វិនិច្ឆ័យជីវិតមនុស្សហ្នឹង គឺថាមានតែថ្នាក់មជ្ឈិម រីឯថ្នាក់ក្រោមពីខេត្តដល់ឃុំហ្នឹង មិនមានអំណាចទេ ប៉ុន្តែមានអំណាចមួយធ្វើរបាយការណ៍។ នៅក្នុងបទពិសោធន៍ជាមេឃុំថាតើធ្លាប់រាយការណ៍ហ្នឹង តើរបៀបនៃការរាយការណ៍បែបណា? សូមផ្តល់ជាបទពិសោធន៍។

សូមៗកុំអាល់ឆ្លើយ សឹមនេះសិន!

**ឆ៖** បាទ សូមធ្វើការជម្រាបជូន។ មុននឹងធ្វើរបាយការណ៍ឡើងទៅថ្នាក់ស្រុក គឺឯកភាពគ្នាក្នុងគណៈដឹកនាំក្នុងឃុំហ្នឹង បាទ ឃុំខ្លះមានប្រាំនាក់ ខ្លះមានបី ប៉ុន្តែសំខាន់ គឺឯកភាពបីមុនហើយបានអញ្ជើញពីរនាក់ទៀតមកចូលរួម។ បាទ ក្នុងនោះ គឺលេខា គឺប្រធានហ្នឹងហើយ អនុលេខា និងសមាជិកអចិន្ត្រៃយ៍បានពិគ្រោះពិភាក្សាតស៊ូមតិថា ឥឡូវការងារនៅក្នុងឃុំវាមានរឿងបាតុភាពអីចេះមួយៗ ថាតើគួរយើងដោះស្រាយរបៀបណា? យើងរាយការណ៍ឡើងទៅលើ ឬមួយក៏យើងចុះទៅអប់រំផ្ទាល់តាមរយៈមេភូមិ និងប្រជាជន។ បាទ ដូច្នេះ សូមធ្វើការបញ្ជាក់នីតិវិធីមុននឹងរាយការណ៍គេធ្វើរបៀបនេះកន្លងមកបាទ សម្រាប់ខ្លួនខ្ញុំផ្ទាល់។ សូមអស់យោបល់។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

បាទ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តសូមអញ្ជើញលោកស្រី លោកស្រីចៅក្រម មីឡាត។ បាទ សូមអញ្ជើញ!

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណឯកឧត្តមប្រធាន។

[១៦:១៥:៣២]

**សួរដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**ស៖** លោកសាក្សី ខ្ញុំសូមនិយាយ ចូលនិយាយអំពីកិច្ចប្រជុំនៅទីរួមខេត្តតាកែវ។ តើលោកអាចនឹកឃើញទេ កិច្ចប្រជុំហ្នឹងធ្វើឡើងរយៈពេលប្រហែលជាប៉ុន្មានដែរក្រោយថ្ងៃរំដោះ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមធ្វើការជម្រាប គឺធ្វើទៅក្នុងរយៈកាលពេលហ្នឹង គឺប្រាំថ្ងៃបាទ។ ហើយរូបភាពធំដែរ មួយគណៈភូមិភាគ គឺខេត្តកំពង់ស្ពឺ កម្មាភិបាលកំពង់ស្ពឺ ហើយនិងតាកែវ កំពត ហើយនិងតំបន់២៥ ពេលនុ៎ងទៅរៀន បាទ នៅតាកែវហ្នឹង។ សូមអស់យោបល់ បាទ។

**សៈ** តើៗតើរយៈពេលប៉ុន្មានថ្ងៃឲ្យច្បាស់លាស់ ខ្ញុំស្ដាប់ឮ បី ឬប្រាំថ្ងៃ?

**ធៈ** បាទ ពីព្រឹកមិញ ខ្ញុំនឹកឃើញថា រំឭកខ្ញុំនិយាយច្រឡំបីថ្ងៃ ប៉ុន្តែថ្ងៃពេលនេះ គឺប្រាំថ្ងៃ បាទ ប្រាំថ្ងៃ។ សូមលោកមេធាវីជ្រាប បាទ។

**សៈ** តើសូមឲ្យលោកពន្យល់បន្តិចមើល តើការបញ្ជាឲ្យមកចូលរួមប្រជុំហ្នឹង វាមានសារៈសំខាន់បែបម៉េច? ហើយសូមលោករៀបរាប់មើល អំពីគោលនយោបាយនៃការទុកអាយុជីវិតទៅឲ្យទាហាន លន់ នល់ ហ្នឹង?

**ធៈ** បាទ ខ្ញុំសូមធ្វើការជម្រាបជូន ការទៅរៀនហ្នឹងខ្លឹមសារប្រាំថ្ងៃហ្នឹង គឺរៀនបីថ្ងៃ និងធ្វើជីវទស្សន៍ពីរថ្ងៃ។ ឯរៀនក្នុងរយៈបីថ្ងៃហ្នឹង ថ្ងៃទី១ រៀនពីមាគ៌ាសេដ្ឋកិច្ច។ ថ្ងៃទី២ រៀនពីមាគ៌ាសាមគ្គីឯកភាពផ្ទៃក្នុងបក្ស ពេលនុ៎ងប្រើពាក្យ"បក្ស"ហើយ បាទ។ ហើយចំណុចទី៣ គឺពង្រឹងសហករណ៍នៅតាមមូលដ្ឋានហ្នឹងបាទ។ ហើយដល់ពីរថ្ងៃក្រោយនេះ គឺសម្រាប់ធ្វើជីវទស្សន៍ ឲ្យម្នាក់ៗឡើងសម្ដែងហើយមានសមាជិក មានអ្នកចូលរៀនហ្នឹង ដាក់សំណួរ បាទ។ អ៊ីចឹង ការលើកឡើងបញ្ជាក់ហេតុផលសកម្មភាពពេលនោះ គឺអ៊ីចឹង។ សូមៗជម្រាប និងសូមអស់យោបល់ បាទ។

[១៦:១៨:០២]

**សៈ** ក៏ប៉ុន្តែតាមចម្លើយរបស់លោកនោះ និងចម្លើយពីមុនៗរបស់លោក គឺបញ្ជាក់ថា ទាហាន លន់ នល់ ចាប់ពីស័ក្តិ៥ចុះមក គឺថាមិនត្រូវប៉ះពាល់ពួកគេទេ។ តើនេះ គឺថាវាកើតឡើងនៅមុនកិច្ចប្រជុំនេះ ឬក៏យ៉ាងណា? ហើយចំពោះលោកវិញ សូមលោកពន្យល់អង្គជំនុំជម្រះបន្តិចមើល តើការបញ្ជាមិនឲ្យប៉ះពាល់ដល់ទាហាន លន់ នល់ ពីស័ក្តិ៥ ចុះមកហ្នឹង គឺចង់មានន័យថាម៉េច?

**ធៈ** បាទ សូមធ្វើការជម្រាបជូន ចម្លើយទី១ គឺការណែនាំ គឺនៅលើភ្នំត្រែលហ្នឹង គឺក្រោយឆ្នាំ ១៩៧៥ គឺរំដោះទូទាំងប្រទេសហើយ បាទ។ ឯចំណុចទី២ ការយល់របស់ខ្ញុំនេះ គឺការលើកឡើងហ្នឹងដូចធ្វើការបញ្ជាក់ហើយចំពោះ -- ក្នុងនោះគឺដើម្បីរក្សាកម្លាំង ជំហរសាមគ្គី និងធ្វើឲ្យអ្នកស្រុក ព្រោះទាហានទាំងអស់ហ្នឹងជាកូនអ្នកស្រុក ក្នុងឃុំនីមួយៗគឺពិតជាមាន។ អ៊ីចឹងការលើកឡើងបញ្ជាក់ហ្នឹងការយល់របស់ខ្ញុំគឺថាធ្វើដើម្បីឲ្យប្រជាជន អ្នកនៅមូលដ្ឋាន និងអ្នកដែលចេញពីក្រុងភ្នំពេញមានការស្ងប់ចិត្តរាប់អានគ្នា ចាត់ទុកទំនាក់ទំនងជាមនុស្សក្នុងស្រុក ក្នុងភូមិ ព្រោះទាហាននៅខាងក្នុងនោះ ពិតមែនអ្នកបម្រើ លន់ នល់ ក៏ប៉ុន្តែឪពុកម្ដាយដែលនៅខាងតំបន់រំដោះបានរួមចំណែកក្នុងចលនា ឲ្យជាគោឲ្យជាអង្ករ ឲ្យជាទ្រព្យបន្លែបង្កា និងចូលរួមចំណែកឲ្យកូនទៅធ្វើយុទ្ធជនបាទ ដើម្បីបម្រើការងារពេល

នោះបាទ។ អ៊ីចឹងធ្វើការពេលនោះគឺដើម្បី--

**ស៖** លោកសាក្សី ខ្ញុំយល់អំពីមនោគមន៍វិជ្ជាទូទៅហើយ ដែលលោកបានបញ្ជាក់មកនេះ ប៉ុន្តែមានការអនុវត្តជាក់ស្តែងណាមួយអីទេ តើដែលមានៗការគំរាមកំហែងនាំឲ្យមានការសម្លាប់មនុស្សដែរ ឬក៏យ៉ាងណា បានជានាំឲ្យមានការចេញបញ្ជាបែបហ្នឹងទៅដល់អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះ អង្គជំនុំជម្រះចង់ដឹងថាវាមានមូលហេតុអ្វីដែលនាំឲ្យមានការចេញបញ្ជាបែបហ្នឹង ថាៗកុំឲ្យប៉ះពាល់ដល់ទាហានលន់ នល់ពីស័ក្តិ៥ចុះមកហ្នឹង មូលហេតុស្អី?

[១៦:២១:៥១]

**ឆ៖** បាទ សូមឆ្លើយ។ អ្វីដែលខ្ញុំមិនបានដឹងថារឿងច្របូកច្របល់យ៉ាងម៉េចនោះទេបាទ ដោយមានគោលការណ៍ហ្នឹង។ ឯសម្រាប់ឃុំខ្ញុំ នៅឃុំជាងទង ដូចអត់មានតួនាទីអ្នកទាំងអស់ហ្នឹងផងបាទ អ៊ីចឹង គេទាំងឡាយដែលបានទៅរស់នៅ គ្នាបុណ្យស័ក្តិបន្តិចបន្តួចនៅបាទ តែត្រង់បាត់បង់នៅកន្លែងណាៗ ខ្ញុំមិនបានដឹងទេ សូមសម្តែងការស្មោះត្រង់ នេះហើយនិងការពិតជម្រាបលោកពេលនេះឲ្យអស់បាទ សូមអស់យោបល់បាទ។

**ស៖** ខ្ញុំចង់សួរបន្ថែមទៀត ព្រោះលោកអត់ឆ្លើយនៅឡើយទេ។ តើការបញ្ជានេះ ត្រូវបានឃុំរបស់លោកអនុវត្តដែរឬទេ?

**ឆ៖** សូមជម្រាប ចំពោះឃុំរបស់ខ្ញុំគឺគ្រាន់តែបានអប់រំជាទ្រឹស្តី តែចំពោះអនុវត្ត ចំពោះទាហានប៉ូលិសអី គឺអត់ទេបាទ។ ការជ្រុលជ្រួសក្រោយពីការប្រកាសហើយហ្នឹង ពីមុននោះក៏គ្មានដែរបាទ សូមអស់យោបល់។

**ស៖** ខ្ញុំសូមសួរម្តងទៀត តើថាតើ -- សួរអំពីការបកប្រែអំមិញហ្នឹង ឮសួរ "អនុវត្តអ្វី"។ តើចង់និយាយពីការអនុវត្តស្អី?

**ឆ៖** អនុវត្តនូវខ្លឹមសារដែលថាបញ្ជូនទាហាន ប៉ូលិសហ្នឹងបាទ អត់ទេបាទ ដូច--

[១៦:២៤:១១]

**ស៖** តើសេចក្តីណែនាំ ឬក៏ការបញ្ជានេះគឺត្រូវបានគេមិនគោរព ឬក៏ច្រានចោលអីដែរឬទេ?

**ឆ៖** បាទ សូមឆ្លើយ។ ចំពោះការណែនាំនេះ ខ្ញុំសម្រាប់មូលដ្ឋាន ហើយក្នុងស្រុក គឺក្របខ័ណ្ឌឃុំ គឺបានអនុវត្តបាទ ប៉ុន្តែត្រង់អ្នកណាអនុវត្តបានប៉ុនណាៗ អាហ្នឹងគឺខ្ញុំមិនអាចយល់បានទេបាទ ប៉ុន្តែខ្ញុំសូមជម្រាបពាក្យមួយ -- សកម្មភាពមួយឃ្លាដែលខ្ញុំមិនសូវយល់ ពេលនោះខ្ញុំទៅប្រជុំនៅស្រុក តាញ៉ៀវ

ៗគាត់បានលើកឡើងថា "យើងនៅមូលដ្ឋាន បើកាលណាឃើញឃោធាគេទៅបោះទីតាំងនៅមូលដ្ឋាន គឺយើងអនុញ្ញាតឱ្យគេអនុវត្តទៅ"។ បាទ ហើយខ្ញុំ ពាក្យហ្នឹង គេផ្សាយជាទូទៅក្នុងស្រុក១០៥ហ្នឹង តែសម្រាប់ឃុំខ្ញុំ អត់មានឃើញឃោធាទៅអនុវត្តនៅកន្លែងហ្នឹងទេបាទ។

**ស៖** ខ្ញុំត្រឡប់ទៅសំណួរខាងដើមវិញ តើការបញ្ហានេះ ឬក៏ណែនាំនេះធ្លាប់ត្រូវបានកែប្រែ ឬក៏ផ្លាស់ប្តូរដែរទេ?

**ឆ៖** បាទ សូមធ្វើការជម្រាប ការណែនាំនេះអត់មានការកែប្រែទេ បាទក្រោយមក។ ប៉ុន្តែសូមជម្រាបនៅឆ្នាំ៧៧ ចុង៧៧នេះ ដើម៧៨ ក្រែងគេមានមតិណែខាងលើ ខាងលេខាអីគាត់ទទួល ក៏ខ្ញុំមកជាសមាជិកសាខាសាមញ្ញហើយ។ ដូច្នេះក្រែងគេអត់ប្រាប់ឱ្យដឹង។ អ៊ីចឹងសូមអស់យោបល់។

**ស៖** ហើយនិយាយជាទូទៅ តើការណែនាំនេះ គឺគេនិយាយអំពីអ្វី? លោកប្រហែលជាមិនចាំភាពលម្អិតទេ ប៉ុន្តែតាមដែលលោកបានចាំខ្លះៗ ថាតើគេនិយាយអំពីអ្វីដែរចំពោះសេចក្តីណែនាំនេះ?

**ឆ៖** ចំពោះសេចក្តីណែនាំនេះ គឺគេ -- ការយល់របស់ខ្ញុំ គឺគេនិយាយដើម្បីប្រមូលកម្លាំងទាំងអស់ឱ្យរួមរស់នៅក្នុងសង្គមជាតិទាំងមូល ព្រោះតាម៉ុក បានបញ្ជាក់ថា តាម៉ុក យើងនៅបន្តការបង្កបង្កើន ហើយនិងការពារទឹកដីយើងតទៅទៀត។ បាទ សូមអស់យោបល់។

[១៦:២៧:៥១]

**ស៖** តើសេចក្តីណែនាំនេះ គិតថាគឺជាការកែប្រែខុសពីមុនៗក្នុងការហាមឃាត់មិនឱ្យប៉ះពាល់ដល់ទាហានលន់នល់ហ្នឹង លោកគិតថាហ្នឹងគឺជាការកែប្រែអ្វីដែលខុសពីមុនទេ?

**ឆ៖** សូមធ្វើការជម្រាបជូន អ្វីដែលខ្ញុំបានឃើញនៅក្រាំងតាចាន់ ហើយនិងនៅទួលស្តែង ខ្ញុំសន្និដ្ឋានថា ប្រហែលជាមានការកែប្រែក្នុងករណីដែលខ្ញុំបានឃើញលលាដ៍ និងគំនរទាំងអស់នេះ។ នេះសូមធ្វើការបញ្ជាក់អំពីការសន្និដ្ឋាននិងការយល់របស់ខ្ញុំ។ បាទ សូមជម្រាបប៉ុណ្ណេះ សូមអស់យោបល់។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកសាក្សី។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ខ្ញុំសូមឱ្យលោកសាក្សីឆ្លើយបន្តិចទាក់ទងនឹងបញ្ហាអំមិញហ្នឹង គឺលោកសាក្សីបានបង្ហាញថា ការប្រជុំនៅក្រោយពេលរំដោះហ្នឹង គឺមួយនៅភ្នំត្រែង ហើយមួយទៀតនៅតាកែវ។ តើនៅតាកែវហ្នឹង គឺក្រោយពេលរំដោះហ្នឹងប៉ុន្មានខែ?

**លោក សៅ វ៉ន៖**

**ឆ៖** បាទ សូមធ្វើការជម្រាបលោកចៅក្រម ប្រជុំនៅភ្នំត្រែល គឺក្រោយពីរំដោះទូទាំងប្រទេស ប្រហែលពីរខែៗបាទ ហើយប្រជុំនៅតាកែវនោះ គឺចុងឆ្នាំ៧៦ ចូលជិតខ្ទង់ខែ១២ ៧៦ នៅតាកែវ។ បាទ សូមធ្វើការជម្រាបប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ យើងអស់មានសំណួរហើយ អ៊ីចឹងសូមអរគុណសាក្សីដែលបានផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃនេះ។ ហើយលោកអាចអញ្ជើញត្រឡប់ទៅវិញបានពេលនេះបាទ។

អង្គជំនុំជម្រះប្រកាសជម្រាបដល់ភាគីទាំងអស់ថានៅ -- និងមេធាវីផងដែរ គឺសវនាការនៅថ្ងៃនេះគឺផ្អាកត្រឹមពេលនេះ ហើយសវនាការនឹងបន្តនៅថ្ងៃស្អែកដែលដើម្បីស្តាប់សាក្សី SCW-3 ហើយចាប់ផ្តើមនៅពេលវេលាម៉ោងប្រាំបួនគត់។ ដូច្នេះ គឺសូមអញ្ជើញមន្ត្រីពន្ធនាគារនាំជនជាប់ចោទទៅពន្ធនាគារវិញ ហើយស្អែកមុនពេលចាប់ផ្តើមសវនាការត្រូវនាំជនជាប់ចោទមកទីនេះដើម្បីធ្វើសវនាការបន្តទៀតបាទ។

តុលាការប្រកាសផ្អាកសវនាការរសៀលនេះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:៣១ នាទី)*